សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មេសា ឆ្នាំ ២០១៩

# លីអាហូណា




សារលិខិតនៃសេចក្ដីសង្ឃឹម និងការដោះលែងឲ្យរួចរបស់ព្រះអង្គសង្គ្រោះ ទំព័រ ១៨

ពេលយើងមានអារម្មណ៍ថា គេបំភ្លេចយើង សូមចងចាំពីស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន ទំព័រ ១២

តន្ត្រីបុណ្យអ៊ីស្ទើរ ៖ « នៅក្នុងសួនច្បារដ៏ពិសិដ្ឋ » ទំព័រ ២៤

របៀបស្វែងរកភាពសុខសាន្ត និងចៀសវាងពីការបោកបញ្ឆោត ទំព័រ ២៦

សាសនាចក្រ
នៅទីនេះ

# ទីក្រុងរីយ៉ាវីក ប្រទេសអៀកឡង់





ជាមួយនឹងព្រិលគ្របដណ្ដប់លើភ្នំអ៊ីចានៅរូបថ្មខាងក្រោយ នោះទីក្រុងរីយ៉ាវីក ប្រទេសអៀកឡង់ដែលជារដ្ឋធានីពោរពេញដោយទេសភាពស្រស់បំព្រង ផ្ដល់នូវការស្វាគមន៍ដល់ប្រទេសនៅលើកោះមួយដែលមានចម្ងាយជាង ១៦០៩ គីឡូម៉ែត្រពីប្រទេសនៅលើដីគោកនៃសហព័ន្ធអឺរ៉ុប ។ ក្រុមវីឃីងបានតាំងទីលំនៅដំបូងគេនៅឆ្នាំ ៨៧៤ គ. ស ទីក្រុងរីយ៉ាវីកគឺជាចំណុចសំខាន់នៃវប្បធម៌ សេដ្ឋកិច្ច និងសកម្មភាពផ្នែករដ្ឋាភិបាលរបស់ប្រទេសអៀកឡង់ ព្រមទាំងជាទីក្រុងមួយដែលមានភាពស្អាតបាតមានពណ៌ចៃតង និងមានសុវត្ថិភាពបំផុតនៅលើពិភពលោក ។

ជនជាតិអៀកឡង់ពីរនាក់ដំបូងបានទទួលបុណ្យជ្រមុជទឹកនៅប្រទេសដាណឺម៉ាក់ក្នុងឆ្នាំ ១៨៥១ ។ មិនយូរប៉ុន្មានក្រោយមក ពួកគេបានត្រឡប់ទៅប្រទេសអៀកឡង់វិញ ហើយក្នុងឆ្នាំ ១៨៥៣ សាខាដំបូងមួយត្រូវបានបង្កើតឡើង ។ សព្វថ្ងៃនេះមានសមាជិកជិត ៣០០ នាក់នៅក្នុងប្រទេសអៀកឡង់នៅក្នុងបីសាខា នៅទីក្រុងរីយ៉ាវីក ទីក្រុងអាគូរ៉េរី និងទីក្រុងសេហ្វូស ។ ព្រះវិហារបរិសុទ្ធដែលជិតបំផុតគឺនៅក្នុងទីក្រុងឡុងដ៍ ប្រទេសអង់គ្លេសដែលមានចំណាយ ១៨៩៤ គីឡូម៉ែត្រពីទីក្រុងរីយ៉ាវីក ។

ទោះបីជាមានសមាជិកតិចតួចក្តី សាសនាចក្របន្តរីកចម្រើន ។ ទោះបីនៅដាច់ឆ្ងាយពីគេ ទោះបីមានឧបសគ្គក្នុងការបកប្រែឯកសារសាសនាចក្រ អាកាសធាតុមិនអំណោយផល និងមានរបាំងផ្នែកវប្បធម៌ក្ដី ក៏ថ្នាក់ដឹកនាំសាសនាចក្របានសន្យាថា ថ្ងៃណាមួយប្រទេសអៀកឡង់នឹងក្លាយជាសើនបញ្ជាំងពន្លឺដល់ប្រទេសដទៃទៀត ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) បានធ្វើទស្សនកិច្ចទៅប្រទេសអៀកឡង់ ហើយរំឭកសមាជិកទាំងនោះថា ពួកគេគឺជា « ប្រជាជននៃ ‹ កម្លាំង និងថាមពល និងមានសមត្ថភាព › ដើម្បីធ្វើកិច្ចការដ៏អស្ចារ្យ » ( « Wonderful to Have Sweet, Good Land » *Church News* ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០២ ទំព័រ ១០ ) ។

- បេសកកម្មអៀកឡង់ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៨៩៤ ប៉ុន្តែការផ្សព្វផ្សាយត្រូវបានឈប់នៅក្នុងឆ្នាំ ១៩១៤ ។ ប្រទេសអៀកឡង់បានក្លាយជាផ្នែកមួយនៃបេសកកម្មដាណឺម៉ាក់ កូភេនហាហ្គេន ក្នុងឆ្នាំ ១៩៧៥ ។
- ក្នុងឆ្នាំ ១៩៧៧ អែលឌើរ យ៉ូសែប ប៊ី វ៉ឺតលីន ( ១៩១៧–២០០៨ ) កាលនោះជាសមាជិកនៃពួកចិតសិបនាក់ក្នុងកូរ៉ុមទីមួយ បានឧទ្ទិសឆ្លងប្រទេសអៀកឡង់សម្រាប់ការផ្សព្វផ្សាយដំណឹងល្អជាផ្លូវការ ។
- ក្នុងឆ្នាំ ១៩៨១ ព្រះគម្ពីរមរមនត្រូវបានបោះពុម្ពជាភាសាអៀកឡង់—ភាសាមួយដែលគ្មានប្រទេសណាផ្សេងទៀតនៅលើពិភពលោកនិយាយឡើយ ។



នៅក្នុងគ្រានៃការបាក់ទឹកចិត្ត សូមចងចាំអំពីស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន
*ខេស្ស ជេ វីលសុន*
១២



ការធ្វើឲ្យការងារបម្រើពោរពេញដោយអំណរ
៨





ចូរទុកចិត្តលើការដោះលែងឲ្យរួចរបស់ព្រះអង្គសង្គ្រោះ
*ប្រធាន ហិនរី ប៊ី អាវរិង*
១៨



មេរៀនបីស្ដីពី សេចក្ដីស្រឡាញ់ អំណរ និងភាពសុខសាន្ត
*ប្រែអិន ខេ អាស្តុន*
២៦

# ពេលអ្នកបាក់ទឹកចិត្ត

ជីវិតមានមួយថ្ងៃមួយថ្ងៃកោរ ។ ជួនកាលពេលយើងមានបញ្ហា យើងឆ្ងល់ថា តើព្រះកំពុងធ្វើអ្វី—មេហតុអ្វីព្រះវរបិតាដែលពោរពេញដោយក្តីស្រឡាញ់ទុកឲ្យរឿងនេះកើតឡើងទៅវិញ ? ស្ថានភាពលំបាកនេះអាចឲ្យយើងសួរថា « តើព្រះខ្វាយខ្វល់នឹងខ្ញុំពិតដែរឬអត់ ? »

ក្នុងស្ថានការបែបនេះ ខ្ញុំបានរកឃើញខគម្ពីរទាំងនេះដែលមានប្រយោជន៍ ៖

- **ទំនុកតម្កើង ៨:៤–៥** ៖ « នោះតើមនុស្សជាអ្វី ដែលទ្រង់នឹករឭកដល់គេ ?. . . ដ្បិតទ្រង់បានធ្វើឲ្យគេទាបជាងពួកទេវតាតែបន្តិចទេ ក៏បានបំពាក់សិរីល្អ និងកេរ្តិ៍ឈ្មោះឲ្យទុកជាមកុដ » ។
- **យ៉ូហាន ១០:១៤** ៖ អំឡុងពេលនៅលើផែនដី ព្រះយេស៊ូវពិពណ៌នាអំពីអង្គទ្រង់ថាជា « អ្នកគង្វាលល្អ » ហើយបន្ថែមថា « [ ខ្ញុំ ] ស្គាល់ចៀមរបស់ខ្ញុំ » ។
- **ម៉ូសេ ១:៣៩** ៖ នេះគឺជាខគម្ពីរមួយដែលខ្ញុំពេញចិត្ត ពេលព្រះអម្ចាស់បានបើកសម្តែងព្រះរាជបំណងទ្រង់ដល់ព្យាការី យ៉ូសែប ស្ម៊ីធ « ដ្បិតមើលចុះ នេះហើយជាកិច្ចការរបស់យើង និងសិរីល្អរបស់យើង—គឺដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស »—ដូច្នេះខគម្ពីរនេះគូសបញ្ជាក់ពីចំណាប់អារម្មណ៍របស់ទ្រង់លើយើងម្នាក់ៗ ។
- **លូកា ៧:១១–១៦** ៖ ខគម្ពីរនេះពុំគ្រាន់តែបង្រៀនយើងអំពីព្រះចេស្ដារបស់ព្រះអង្គសង្គ្រោះឈ្នះលើសេចក្ដីស្លាប់ប៉ុណ្ណោះទេ—ជាពេលដែលពួកយើងនារដូវបុណ្យអ៊ីស្ទើរនេះ—សម្រាប់ខ្ញុំ ខគម្ពីរនេះថែមទាំងបានតំណាងឲ្យគំរូនៃការស្គាល់យើងម្នាក់ៗយ៉ាងច្បាស់ពីទ្រង់ ។ ក្នុងចំណោមអព្ភូតហេតុទាំងអស់របស់ព្រះយេស៊ូវ មានអព្ភូតហេតុមួយចំនួនគឺទន់ភ្លន់ និងមានចិត្តអាណិតអាសូរដូចជាការប្រទានការងារបម្រើរបស់ទ្រង់ដល់ស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន ។ ដូចខ្ញុំចែកចាយនៅក្នុងអត្ថបទរបស់ខ្ញុំ ( សូមមើលទំព័រទី ១២ ) ដំណើររឿងនេះបង្ហាញអំពីចំណាប់អារម្មណ៍ និងសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះសម្រាប់យើងម្នាក់ៗ ។

ខេស្ស វីលសុន
សាស្ត្រាចារ្យរង សាកលវិទ្យាល័យព្រិកហាំ យ៉ង់



# មាតិកា


៥ **ទ្រង់រស់ឡើងវិញ !**
« មនុស្សមានសេរីលើក្ដីស្លាប់ ។ ព្រះគ្រីស្ទទ្រង់មានជ័យជម្នះ » ។

៦ **ការបង្ហាញអំពីសេចក្ដីជំនឿ:** ប៊ប និង ឡូរី ស៊ើរស្ដុន—បេសកកម្មភ្នំពេញកម្ពុជា
បេសកកម្មរបស់ពួកគេពុំមែនជាអ្វីដែលពួកគេរំពឹងទុកឡើយ ប៉ុន្តែវាក៏បានផ្ដល់ពរដល់ពួកគេក្នុងរបៀបដែលនឹកស្មានមិនដល់ ។

៨ **គោលការណ៍នៃការងារបម្រើ:** ការធ្វើឲ្យការងារបម្រើពោរពេញដោយអំណរ
ប្រភពដ៏អស្ចារ្យបំផុតមួយនៃអំណរដ៏ពិតនោះគឺរកឃើញនៅក្នុងការបម្រើ ។

១២ **នៅក្នុងគ្រានៃការបាក់ទឹកចិត្ត សូមចងចាំអំពីស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន**
*ដោយ ខេស្ស ជេ វីលសុន*
ដូចអ្វីដែលទ្រង់បានធ្វើដល់ស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន នោះព្រះអង្គសង្គ្រោះនឹងយាងមករកយើងក្នុងគ្រាដ៏អាសន្នបំផុតរបស់យើង ។

១៨ **ចូរទុកចិត្តលើការដោះលែងឲ្យរួចរបស់ព្រះអង្គសង្គ្រោះ**
*ដោយប្រធាន ហិនរី ប៊ី អាវរិង*
ព្រះអម្ចាស់នឹងដឹកនាំយើងទៅរកការដោះលែងឲ្យរួចពីការសាកល្បងរបស់យើង ពេលយើងប្រែកាន់តែសុចរិត ។

២៤ **តន្ត្រី:** នៅក្នុងសួនច្បារដ៏ពិសិដ្ឋ
*ដោយ ថាមមី ស៊ីមីស្ទើរ រ៉ូប៊ីនសុន*
ព្រះអង្គសង្គ្រោះបានរស់នៅ ហើយបានសុគតសម្រាប់យើង ។

២៦ **មេរៀនបីស្ដីពី សេចក្ដីស្រឡាញ់ អំណរ និងភាពសុខសាន្ត**
*ដោយ ប្រែអិន ខេ អាស្តុន*
អ្នកអាចស្វែងរកសុភមង្គលបាន ទោះបីអ្នកមានកាលៈទេសៈបែបណាក្តី ។

៣២ **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**
ខ្យល់ព្យុះសង្ឃរាបានបំផ្លាញគម្រោងរៀបការ, អត្ថន័យពិតប្រាកដនៃជីវិតរមែងស្លាប់, ចម្រៀងដែលផ្ដល់សេចក្ដីសង្ឃឹម, ការអញ្ជើញដែលត្រូវបានទទួលយក ។

៣៦ **ពរជ័យនៃភាពខ្លួនទីពឹងខ្លួន:** អាជីវកម្មកំពុងដំណើរការល្អ
*ដោយ យូស្វេ ជេ ផាកកឺ*
មេធាវីម្នាក់បាត់បង់ការងាររបស់គាត់ ប៉ុន្តែគាត់រកឃើញការបំផុសគំនិតនៅក្នុងថ្នាក់ភាពខ្លួនទីពឹងខ្លួនរបស់ព្រះវិហារ ។

៣៨ **គេហដ្ឋានរបស់យើង ក្រុមគ្រួសាររបស់យើង:** កូនប្រុសយើងគឺជាបុត្ររបស់ព្រះវរបិតាសួគ៌
*ដោយ ដើលីន មើហ្វី*
មិនថា យើងស្រឡាញ់កូនៗរបស់យើងប៉ុន្មាននោះទេ ព្រះស្រឡាញ់ពួកគេជាងយើងទៅទៀត ។

៤០ **ការបង្រៀនយុវវ័យ និងកុមារតូចៗ:** ការដោះស្រាយជាមួយនឹងសោកនាដកម្ម
យោបល់គន្លឹះដើម្បីជួយកូនៗរបស់អ្នកទទួលអារម្មណ៍សុខសាន្ត ។


ការអានខ្លីៗ



**នៅលើក្របមុខ**
*នៅតាមផ្លូវទៅទីក្រុងអេម៉ោស*
ដោយ វីនឌី ខេលើរ

## កថាកណ្ឌ


**យុវមជ្ឈិមវ័យ**

៤២
ជាមួយនឹងជម្រើសទាំងអស់ដែលយើងជួប និង **ការសម្រេចចិត្តនានាដែលផ្លាស់ប្ដូរជីវិត** ដែលយើងធ្វើ, របៀបយើងអាចដឹងថា យើងកំពុង **ធ្វើតាមផែនការរបស់ព្រះ** សម្រាប់យើង ? សូមអានអត្ថបទខែនេះស្ដីពី **ការទទួលវិវរណៈ** ។





**យុវវ័យ**

៥០
សូមរៀនរបៀបប្រើពររបស់លោកអយ្យកោអ្នក, សូមទទួលការបំផុសគំនិតដើម្បីចាប់ផ្ដើម **ប្រពៃណីថ្មីនៃបុណ្យអ៊ីស្ទើរ** និង **ស្វែងរកភាពសុខសាន្ត** សម្រាប់ខ្លួនឯង និងមនុស្សដទៃ ពេលអ្នកអានអត្ថបទចេញផ្សាយខែនេះ ។





**កុមារ**
សូមរៀនបន្ថែមទៀតអំពី **មូលហេតុដែលយើងសាទរដល់បុណ្យអ៊ីស្ទើរ** តាមរយៈការអានអំពីព្រះយេស៊ូវគ្រីស្ទ ដង្វាយធួន និងការមានព្រះជន្មរស់ឡើងវិញ និងអត្ថន័យរបស់វាសម្រាប់ពួកយើង ។




## អត្ថបទដែលមានលក្ខណៈសម្រាប់តែឌីជីថលប៉ុណ្ណោះ



**ការហ្វឹកហាត់សាច់ដុំខាងវិញ្ញាណរបស់អ្នក**

*ដោយ អាស្តែន ស្ទែនឌើរ*

ដើម្បីការពារការរិចរិលទីបន្ទាល់របស់យើង យើងត្រូវស្ថាបនាសាច់ដុំខាងវិញ្ញាណរបស់យើងជាប្រចាំ ។



**តើអ្នកកំពុងរស់នៅតាមដំណឹងល្អមិនអស់ពីចិត្តឬ ?**

*ដោយ ឆាខែល វូដលែញ*

តើអ្វីទៅជាភាពខុសគ្នារវាងការរស់នៅក្នុងសាសនាចក្រ និងការសកម្មនៅក្នុងដំណឹងល្អ ?

## ស្វែងរកបន្ថែមទៀត

នៅក្នុងកម្មវិធី Gospel Library និងនៅគេហទំព័រ liahona.lds.org អ្នកអាច ៖

- ស្វែងរកច្បាប់ចេញផ្សាយបច្ចុប្បន្ន ។
- មើលមាតិកាមានតែឌីជីថល ។
- ស្វែងរកលេខចេញផ្សាយមុនៗ ។
- ដាក់បញ្ជូនរឿង និងមតិកែលម្អរបស់អ្នក ។
- ជាវ ឬជាវដើម្បីផ្ដល់ជាអំណោយ ។
- ពង្រីកការសិក្សាជាមួយឧបករណ៍ឌីជីថល ។
- ចែកចាយអត្ថបទ និងវីដេអូដែលចូលចិត្ត ។
- ទាញយក ឬបោះពុម្ពអត្ថបទ ។
- ស្ដាប់អត្ថបទដែលអ្នកចូលចិត្ត ។

## ទំនាក់ទំនងមកកាន់យើងខ្ញុំ

សូមអ៊ីម៉ែលសំណួរ និងមតិកែលម្អរបស់អ្នកទៅកាន់ liahona@ldschurch.org ។

សូមដាក់បញ្ជូនរឿងដែលបំផុសឲ្យមានសេចក្ដីជំនឿទាំងឡាយរបស់អ្នកនៅគេហទំព័រ liahona.lds.org ឬផ្ញើសំបុត្រទៅកាន់ ៖
*Liahona*, flr. 23
50 E. North Temple Street
Salt Lake City, UT 84150-0023, USA


**ខែ មេ សា ឆ្នាំ ២០១៩ វ៉ុល ១៨ លេខ ២**
**លីអាហូណា ១៨៦០៤ ២៥៨**

ទស្សនាវដ្ដីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី អាវរិង

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម រ័សុល បាឡឺដ, ជែហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវ៉ែនសុន, ឌេល ជី បេនឡាន់, ជើរិត ដបុលយូ ហ្គង, អ៊ូលីសេស សូរ៉េស

**អ្នកនិពន្ធ ៖** រ៉ាន់ឌី ឌី ហ្វាំង

**អ្នកប្រឹក្សា ៖** ប្រាយអែន ខេ អាស្តុន, រ៉ានដល ខេ បិនណែត, ប៊ែកឃី ក្រាវិន, ស្សារ៉ុន អ៊ូបែង, គ្រីស្ទីណា ប៊ី ហ្វ្រាន់កូ, ដូណាល់ អិល ហលស្ត្រម, ឡារី អេស ខាឈើរ, អេរិក ដបុយូ កូពីឆ្កេ, លីន ជី រ៉ូប៊ីន

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន

**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ ឡយបិហ្គ

**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់

**និពន្ធនាយកគ្រប់គ្រង ៖** អ័ដាម ស៊ី អូសុន

**ជំនួយការនិពន្ធនាយកគ្រប់គ្រង ៖** រ៉ាយអិន ខារ

**ជំនួយការបោះពុម្ពផ្សាយ ៖** កាមីឡា ខាស្ត្រីលលុន

**និពន្ធ និង បោះពុម្ព ៖** ម៉ារីស្សា ឌែននីស, ដេវីឌ ឌិកសុន, ដេវីដ អេ អ៊ែតវើត, ម៉ាធ្យូ ឌី ហ្វ៊ីតុន, ហ្គាប៉ែត អេច ហ្គាហ្វ, ឡូរី ហ្វូលើរ សូសា, ចន រ៉ាយអិន ជិនសិន, ឆាលឡុត ឡាកាបាល់, ម៉ែយល អរ ម៉ូរីស, អេរិក ប៊ី ម៉ដុក, សាលី ចនសុន អូដេឃីក, យ៉ូស្វេ ជេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឆាក់ខែល វូដឡេ, ម៉ារីសា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កុត នូដសិន

**នាយកផ្នែកសិល្បៈ ៖** ចែដ អ័រ ភីធើរសុន

**រចនាប្លង់ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនធ្លី, ស៊ី ឃីមប៊ីល បុត, ថូម៉ាស ឆាល, ចូស្វ៉ា ដេននីស ដេវីឌ ហ្វ្រើន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រើន, ស្កុត អិម ម៉ូយ, អ៊ីមីលី ឆៀកូ ប៉េមីងតុន, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ឆៀរ, យេ នីកូល វ៉កឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី

**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍

**ផលិតកម្ម ៖** អ៊ីវ៉ា ហ្វែន អាឌៀ, ជូលី ប៊ីដេត, ថូម៉ាស ជី ខ្រូនីន, ប្រាយអែន ដ័បុលយូ ហ្គីជី, ជីននី ជេ នីលសុន, ម៉ារីសា អិម ស្មីធ

**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស

**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស

**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាយើរ

សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona*, Rm. ២៤២០, ៥០ E. North Temple St., Salt Lake City, UT ៨៤១៥០–០០២៤, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសាអាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាល, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់មានផ្សេងៗគ្នាទៅតាមភាសា ) ។



© 2019 by Intellectual Reserve, Inc. All rights reserved. បោះពុម្ពនៅសហរដ្ឋអាមេរិក ។



**For Readers in the United States and Canada:** April 2019 Vol. 18 No. 2. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.50 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



*ទ្រង់រស់ឡើងវិញ !*
*ទ្រង់រស់ឡើងវិញ !*
*យើងប្រាប់ដោយអំណរសាទរ*
*ក្នុងបីថ្ងៃទ្រង់បានរស់ឡើងវិញ*
*ចូរឲ្យលោកាអរសាទរ ។*
*មនុស្សមានសេរីលើក្ដីស្លាប់ ។*
*ព្រះគ្រីស្ទទ្រង់មានជ័យជម្នះ ។*

*( « ទ្រង់រស់ឡើងវិញ ! » ទំនុកតម្កើង លេខ ១២១ ) ។*

ពេលអ្នកចងចាំអំពីព្រះអង្គសង្គ្រោះនាបុណ្យអ៊ីស្ទើរឆ្នាំនេះ អ្នកអាចមើលគេហទំព័រ **lds.org/go/4195** ដើម្បីមើលរូបគំនូរដ៏ស្រស់ស្អាត និងទីបន្ទាល់មកពីពួកសាវកអំពីគុណសម្បត្តិរបស់ព្រះអង្គសង្គ្រោះដែលបានធ្វើឲ្យដង្វាយធួន និងការរស់ឡើងវិញរបស់ទ្រង់អាចកើតឡើងបាន ។

# ប៊ប និង ឡូរី សៀវស៊ុន

*បានបម្រើនៅបេសកកម្មភ្នំពេញកម្ពុជា*



*នៅក្នុងបេសកកម្មជាមួយគ្នាជាដំបូងរបស់ពួកគេ ប៊ប និង ឡូរី សៀវស៊ុន បានរៀនថា ការងារបម្រើប្រកបដោយអត្ថន័យអាចកើតមានឡើង ទោះបីជាមានរនាំងនៃភាសា និងវប្បធម៌ខុសគ្នាក្ដី ដោយសារយើងទាំងអស់គ្នាគឺជាបុត្រាបុត្រីរបស់ព្រះ ។*

ឡេសលី នីលសុន ជាងថតរូប

**ប៊ប ៖**

ថ្ងៃមួយយើងបានឮភ្លេងយ៉ាងខ្លាំងៗ ហើយយើងបានកត់សម្គាល់ឃើញថា មានគេសង់រោងមួយឡើង ។ នៅប្រទេសកម្ពុជា ពេលឮភ្លេងបែបនោះ វាមានន័យថា អាចមានមនុស្សរៀបការ ឬមានមនុស្សស្លាប់ ។

**ឡូរី ៖**

យើងបានដឹងថា មានម្ដាយម្នាក់ដែលមានកូនប្រាំ ឬប្រាំមួយនាក់ទើបតែស្លាប់ ។ ពុំឃើញមានស្វាមីនៅទីនោះឡើយ ។ កូនៗទើបតែក្រោកពីដេកឡើង ហើយបានដឹងថាម្ដាយរបស់ពួកគេបានស្លាប់ ។

កូនស្រីម្នាក់បានស្រែកយំយ៉ាងខ្លាំង ។ តាមរយៈអ្នកបកប្រែ នាងបាននិយាយថា « ខ្ញុំជាកូនច្បងគេ ។ ខ្ញុំត្រូវមើលថែបងប្អូនបង្កើតរបស់ខ្ញុំទាំងអស់នេះ ។ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីនោះទេ » ។

ខ្ញុំបានឱបនាងក្នុងរង្វង់ដៃខ្ញុំយ៉ាងណែន ។ តើខ្ញុំអាចមិនឱបនាងយ៉ាងដូចម្ដេចទៅ ? ក្មេងស្រីនេះទើបតែបាត់បង់ម្ដាយនាង ។ ខ្ញុំបាននិយាយជាភាសាអង់គ្លេសទៅកាន់នាងថា « មីងដឹងថា ក្មួយមិនយល់មីងនិយាយអ្វីទេ តែមីងសន្យាថា ក្មួយនឹងឃើញម្ដាយក្មួយម្ដងទៀត ។ ក្មួយនឹងពុំកើតអីទេ ។ យើងនឹងពុំទុកក្មួយឲ្យនៅឯកោឡើយ » ។

បទពិសោធន៍ជាច្រើនបែបនេះបានភ្ជាប់ទំនាក់ទំនងពិសេសរវាងយើងជាមួយនឹងប្រជាជនកម្ពុជា ។



**ស្វែងរកបន្ថែម**

ស្វែងរកការបង្ហាញអំពីសេចក្ដីជំនឿបន្ថែមទៀតនៅគេហទំព័រ **lds.org/go/18** ។


SISTER THURSTON

### គោលការណ៍នៃការងារបម្រើ

# ការធ្វើឲ្យការងារបម្រើពោរពេញដោយអំណរ

ការបម្រើដោយសេចក្ដីស្រឡាញ់នាំមកនូវអំណរដល់ទាំងអ្នកផ្ដល់ឲ្យ និងអ្នកទទួល ។

ជួនកាលការស្វែងរកសុភមង្គលរបស់យើងក្នុងជីវិតនេះ អាចទំនងជាដូចជាការរត់នៅមួយកន្លែង ។ យើងរត់ ហើយរត់ទៀត ហើយនៅតែមានអារម្មណ៍ថា យើងពុំបានទៅដល់កន្លែងណាឡើយ ។ សម្រាប់មនុស្សមួយចំនួន គំនិតនៃការផ្ដល់ការងារបម្រើដល់មនុស្សដទៃ ហាក់ដូចជាការបន្ថែមកិច្ចការដើម្បីធ្វើ ។

ប៉ុន្តែព្រះវរបិតាសួគ៌របស់យើងសព្វព្រះទ័យឲ្យយើងទទួលបទពិសោធន៍នៃអំណរ ហើយបានមានបន្ទូលប្រាប់យើងថា « មានមនុស្សលោក ដើម្បីឲ្យគេអាចមានសេចក្ដីអំណរ » ( នីហ្វៃទី ២ ២:២៥ ) ។ ហើយព្រះអង្គសង្គ្រោះបានបង្រៀនថា ការផ្ដល់ការងារបម្រើដល់មនុស្សដទៃគឺជាផ្នែកចាំបាច់មួយនៃរបៀបដែលយើងនាំអំណរដល់ជីវិតយើង និងមនុស្សដទៃ ។

## តើអំណរជាអ្វី ?

អំណរត្រូវបានផ្ដល់និយមន័យថា « អារម្មណ៍មួយនៃការពេញចិត្ត និងសុភមង្គលដ៏អស្ចារ្យ » ។[១] ពួកព្យាការីថ្ងៃចុងក្រោយបានផ្ដល់ការបញ្ជាក់ច្បាស់លាស់ស្ដីពីប្រភពដែលអំណរកើតមាន និងរបៀបស្វែងរកអំណរ ។ ប្រធាន រ័សុល អិម ណិលសុន បានមានប្រសាសន៍ថា « អំណរដែលយើងទទួលវាមានទំនាក់ទំនងតែបន្តិចបន្តួចជាមួយកាលៈទេសៈនៃជីវិតយើង និងអ្វីគ្រប់យ៉ាងដែលយើងធ្វើជាមួយនឹងការផ្ដោតយកចិត្តទុកដាក់នឹងជីវិតរបស់យើង . . . អំណរកើតឡើង និងដោយសារតែ [ ព្រះយេស៊ូវគ្រីស្ទ ] ។ ទ្រង់គឺជាប្រភពនៃអំណរទាំងអស់ » ។[២]



មនុស្សឃ្លង់ដែលបានថ្លែងអំណរគុណលោក ដោយ ចន ស្ដា

## ការផ្ដល់ការងារបម្រើនាំមកនូវអំណរ

ពេលលីហៃបានទទួលទានផ្លែឈើជីវិត នោះព្រលឹងវិញ្ញាណលោកក៏បានពោរពេញទៅ « ដោយសេចក្ដីអំណរជាខ្លាំង » ( នីហ្វៃទី ១ ៨:១២ ) ។ បំណងប្រាថ្នាដំបូងរបស់លោកគឺចែកចាយផ្លែឈើនោះជាមួយអស់អ្នកដែលលោកស្រឡាញ់ ។

បំណងប្រាថ្នារបស់យើងដើម្បីផ្ដល់ការងារបម្រើដល់មនុស្សដទៃ អាចនាំអំណរបែបនោះដល់យើង និងដល់ពួកគេ ។ ព្រះអង្គសង្គ្រោះបានបង្រៀនពួកសិស្សរបស់ទ្រង់ថា ផលផ្លែដែលយើងនាំមក ពេលយើងភ្ជាប់ទៅនឹងទ្រង់ ជួយនាំភាពពេញលេញនៃសេចក្ដីអំណរដល់យើង ( សូមមើល យ៉ូហាន ១៥:១–១១ ) ។ ការធ្វើកិច្ចការរបស់ទ្រង់ដោយការបម្រើ និងការនាំមនុស្សដទៃទៅកាន់ទ្រង់ អាចជាបទពិសោធន៍នៃអំណរមួយ ( សូមមើល លូកា ១៥:៧; អាលម៉ា ២៩:៩; គោលលទ្ធិ និងសេចក្ដីសញ្ញា ១៨:១៦; ៥០:២២ ) ។ យើងអាចទទួលបទពិសោធន៍នៃអំណរនេះ ទោះបីយើងប្រឈមមុខនឹងការប្រឆាំង និងការរងទុក្ខក្ដី ( សូមមើល កូរិនថូសទី ២ ៧:៤; កូល៉ុស ១:១១ ) ។

### ប្រភពនៃអំណរដ៏ពិតប្រាកដ

ព្រះអង្គសង្គ្រោះបានបង្ហាញយើងនូវគំរូដ៏ល្អឥតខ្ចោះ ដែលជាប្រភពនៃអំណរដ៏ពិតប្រាកដនៅក្នុងជីវិតរមែងស្លាប់នេះ គឺអាចរកឃើញតាមរយៈការបម្រើ ។

ព្រះអង្គសង្គ្រោះបានបង្ហាញយើងនូវគំរូដ៏ល្អឥតខ្ចោះ ដែលជាប្រភពដ៏អស្ចារ្យបំផុតមួយនៃអំណរដ៏ពិតប្រាកដនៅក្នុងជីវិតរមែងស្លាប់នេះ គឺរកឃើញតាមរយៈការបម្រើ ។ ពេលយើងផ្ដល់ការងារបម្រើដល់បងប្អូនប្រុសស្រីរបស់យើងដូចព្រះអង្គសង្គ្រោះបានធ្វើ ដោយសេចក្ដីសប្បុរស និងសេចក្ដីស្រឡាញ់ក្នុងដួងចិត្តយើង នោះយើងអាចទទួលបទពិសោធន៍នៃអំណរដែលមានលើសពីសុភមង្គលធម្មតាទៅទៀត ។

ស៊ីស្ទើរ ជីន បី ប៊ីងហាំ ប្រធានសមាគមសង្គ្រោះទូទៅបានបង្រៀនថា « ពេលយើងទទួលយក [ ការផ្ដល់ការងារបម្រើ ] ដោយដួងចិត្តប្រកបដោយឆន្ទៈ នោះយើងនឹងនឹងកាន់តែជិតប្រែក្លាយទៅជារាស្ត្រនៃស៊ីយ៉ូន ហើយនឹងទទួលអំណរដ៏មហិមាជាមួយនឹងអស់អ្នកដែលយើងបានជួយនៅតាមផ្លូវនៃភាពជាសិស្ស » ។[៣]


ប្រោសកូនស្រីរបស់យ៉ៃរ៉ុសឲ្យរស់ឡើងវិញ ដោយ ជែហ្វ ហៀន

៣. ធ្វើឲ្យការងារបម្រើជារឿងសាមញ្ញ ។ ប្រធាន អិម រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ប្រាប់យើងថា ៖ « រឿងដ៏អស្ចារ្យកើតឡើងតាមរយៈរឿងដ៏សាមញ្ញ និងតូចតាច ។ . . . ទង្វើតូចតាច និងសាមញ្ញប្រកបដោយសន្ដានចិត្តរបស់យើង និងការបម្រើនឹងរួមផ្សំទៅជាជីវិតមួយដែលពោរពេញដោយក្ដីស្រឡាញ់ចំពោះព្រះវរបិតាសួគ៌ ការប្ដូរចិត្តចំពោះកិច្ចការរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ អារម្មណ៍នៃក្ដីសុខសាន្ត និងអំណរគ្រប់ពេលដែលយើងជួយគ្នា » ។[៦]

៤. ដកយកការតានតឹងផ្លូវចិត្តពីការងារបម្រើ ។ វាពុំមែនជាការទទួលខុសត្រូវរបស់អ្នក ដើម្បីធ្វើឲ្យមានសេចក្ដីសង្គ្រោះសម្រាប់នរណាម្នាក់ឡើយ ។ នោះគឺជារឿងរវាងបុគ្គលម្នាក់ៗ និងព្រះអម្ចាស់ ។ ការទទួលខុសត្រូវរបស់យើងគឺស្រឡាញ់ពួកគេ ហើយជួយពួកគេឲ្យបែរទៅរកព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះអង្គសង្គ្រោះរបស់ពួកគេ ។

## តើយើងអាចធ្វើឲ្យការផ្ដល់ការងារបម្រើកាន់តែពោរពេញដោយអំណរយ៉ាងដូចម្ដេច ?

មានរបៀបជាច្រើនដែលនាំអំណរកាន់តែអស្ចារ្យមកកាន់ការងារបម្រើរបស់យើង ។ នេះគឺជាយោបល់មួយចំនួន ៖

១. យល់ដឹងពីគោលបំណងរបស់អ្នកក្នុងការផ្ដល់ការងារបម្រើ ។ មានហេតុផលជាច្រើនដើម្បីផ្ដល់ការងារបម្រើ ។ សំខាន់បំផុត កិច្ចខិតខំរបស់យើងគួរតែស្របទៅនឹងព្រះរាជបំណងរបស់ព្រះគឺ « ដើម្បីនាំឲ្យមានអមតភាព និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ ១:៣៩ ) ។ ពេលយើងទទួលយកការអញ្ជើញរបស់ប្រធានណិនសុន ដើម្បីជួយមនុស្សដទៃនៅលើផ្លូវនៃសេចក្ដីសញ្ញា នោះយើងអាចរកឃើញអំណរក្នុងការចូលរួមក្នុងកិច្ចការរបស់ព្រះ ។[៤] ( សម្រាប់គោលបំណងបន្ថែមស្ដីពីការផ្ដល់ការងារបម្រើ សូមមើល « គោលការណ៍នៃការងារបម្រើ ៖ គោលបំណងដែលនឹងផ្លាស់ប្ដូរការងារបម្រើរបស់អ្នក » នៅក្នុងទស្សនាវដ្ដី *លីអាហូណា* ខែ មករា ឆ្នាំ ២០១៩ ) ។

២. ធ្វើឲ្យការងារបម្រើផ្ដោតទៅលើមនុស្ស មិនមែនទៅលើកិច្ចការឡើយ ។ ជារឿយៗ ប្រធាន ថូម៉ាស អេស ម៉នសុន បានរំឭកយើងថា « ចូរកុំឲ្យបញ្ហាមួយដែលត្រូវដោះស្រាយ ក្លាយជារឿងសំខាន់ជាងមនុស្សម្នាក់ដែលត្រូវស្រឡាញ់ » ។[៥] ការងារបម្រើគឺស្ដីពីការស្រឡាញ់មនុស្ស ពុំមែនជាការធ្វើកិច្ចការអ្វីមួយនោះទេ ។ នៅពេលយើងស្រឡាញ់កាន់តែច្រើនដូចព្រះអង្គសង្គ្រោះស្រឡាញ់ នោះយើងនឹងកាន់តែបើកផ្លូវឆ្ពោះទៅរកអំណរដែលកើតមកពីការបម្រើមនុស្សដទៃ ។

### កុំពន្យារពេលនៃអំណរក្នុងការបម្រើ

ជួនកាលមនុស្សមានចិត្តរារែកក្នុងការសូមជំនួយដែលពួកគេត្រូវការ ដូច្នេះការផ្ដល់ការបម្រើរបស់យើងអាចក្លាយជាអ្វីដែលពួកគេត្រូវការ ។ ប៉ុន្តែការបង្ខំខ្លួនយើងទៅលើមនុស្សក៏ពុំមែនជាចម្លើយផងដែរ ។ ការសូមការអនុញ្ញាតពីមុនផ្ដល់ការងារបម្រើគឺជាគំនិតល្អមួយ ។

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានប្រាប់អំពីម្ដាយទោលម្នាក់ដែលមានជំងឺអុតស្វាយ—ហើយក្រោយមកកូនៗរបស់គាត់ក៏ឈឺផងដែរ ។ ផ្ទះដែលធ្លាប់តែមានសណ្ដាប់ធ្នាប់ បែរជាមានភាពរាយប៉ាយ និងរញ៉េរញ៉ៃ ។ ចានក្បាន និងសម្លៀកបំពាក់ប្រឡាក់គរដូចភ្នំ ។

នៅគ្រាដែលគាត់មានអារម្មណ៍ស្មុគស្មាញពេញទំហឹង នោះមានបងប្អូនស្ត្រីខាងសមាគមសង្គ្រោះបានគោះទ្វារផ្ទះគាត់ ។ ពួកគេពុំបាននិយាយថា « សូមប្រាប់យើង បើមានអ្វីឲ្យពួកយើងជួយ » ឡើយ ។ ពេលពួកគេបានឃើញស្ថានភាពនោះ ពួកគេបានធ្វើវាតែម្ដង ។

« ពួកគេបានរៀបចំភាពរញ៉េរញ៉ៃនោះ បានបោសសម្អាតផ្ទះ ហើយបានទូរសព្ទទៅមិត្តម្នាក់ឲ្យយកអាហារដែលត្រូវការចាំបាច់មក ។ នៅទីបំផុត កាលពួកគេបានបញ្ចប់កិច្ចការខ្លួន ហើយបានលាចេញទៅវិញ នោះពួកគេបានបន្សល់ទុកឲ្យម្ដាយវ័យក្មេងនោះនូវទឹកភ្នែក—ជាទឹកភ្នែកនៃអំណរគុណ និងក្ដីស្រឡាញ់ » ។[៧]

ទាំងអ្នកផ្ដល់ឲ្យ និងអ្នកទទួលបានទទួលអារម្មណ៍កក់ក្ដៅនៃអំណរ ។

## បណ្ដុះអំណរនៅក្នុងជីវិតរបស់អ្នក

ដរាបណាយើងបណ្ដុះឲ្យមាន អំណរ ភាពសុខសាន្ត និងក្ដីរីករាយចិត្តក្នុងជីវិតយើង ដរាបនោះយើងនឹងអាចចែកចាយវាជាមួយមនុស្សដទៃ ពេលយើងផ្ដល់ការងារបម្រើ ។ អំណរកើតមកតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល កាឡាទី ៥:២២ និង គោលលទ្ធិ និង សេចក្ដីសញ្ញា ១១:១៣ ) ។ វាជាអ្វីដែលយើងអាចអធិស្ឋានទូលសូមបាន ( សូមមើល គោលលទ្ធិ និងសេ់ ១៣៦:២៩ ) ហើយនាំវាមកក្នុងជីវិតរបស់យើង ។ នេះជាគំនិតយោបល់មួយចំនួន ដើម្បីបណ្ដុះឲ្យមានអំណរនៅក្នុងជីវិតយើងផ្ទាល់ ៖

១. ចូររាប់ព្រះពររបស់អ្នក ។ ពេលអ្នកពិនិត្យមើលជីវិតរបស់អ្នក សូមសរសេរសៀវភៅកំណត់ហេតុរបស់អ្នក នូវអ្វីៗដែលព្រះបានប្រទានពរដល់អ្នក ។[8] សូមកត់ចំណាំអំពីរឿងល្អដែលមាននៅជុំវិញអ្នក ។[9] សូមផ្ដោតចិត្តទុកដាក់លើអ្វីដែលអាចរារាំងអ្នកពីការទទួលអារម្មណ៍អំណរ ហើយកត់ត្រារបៀបនានា ដើម្បីដោះស្រាយ ឬយល់ពីរបៀបនោះកាន់តែប្រសើរឡើង ។ អំឡុងពេលរដូវកាលបុណ្យអ៊ីស្ទើរនេះ សូមឆ្លៀតពេលស្រាវជ្រាវរកទំនាក់ទំនងកាន់តែប្រសើរឡើងជាមួយព្រះអង្គសង្គ្រោះ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ១០១:៣៦ ) ។

២. អនុវត្តនូវស្ថានភាពផ្លូវចិត្ត ។ អ្នកអាចរកឃើញអំណរកាន់តែងាយស្រួលក្នុងគ្រានៃការស្ញឹងស្ញាធដ៏ស្ងប់ស្ងាត់ ។[10] សូមស្ដាប់ឲ្យហ្មត់ចត់នូវអ្វីដែលនាំអ្នកឲ្យមានអំណរ ( សូមមើល របាក្សត្រទី ១ ១៦:១៥ ) ។ ជួនកាល ការចំណាយពេលងាកចេញពីប្រព័ន្ធសង្គមអាចជារឿងចាំបាច់ ដើម្បីអនុវត្តនូវស្ថានភាពផ្លូវចិត្ត ។[11]

៣. ចៀសវាងការប្រៀបធៀបខ្លួនឯង ។ មានពាក្យនិយាយថា ការប្រៀបធៀបគឺជាចោរប្លន់អំណរ ។ ប៉ុលបានព្រមានអស់អ្នកដែល « គេវាស់ ហើយផ្ទឹមខ្លួននឹងខ្លួនគេនោះគ្មានប្រាជ្ញាទេ » ( កូរិនថូសទី ២ ១០:១២ ) ។

៤. ស្វែងរកវិវរណៈផ្ទាល់ខ្លួន ។ ព្រះអង្គសង្គ្រោះបានបង្រៀនថា ៖ « បើសិនជាអ្នកសូម នោះអ្នកនឹងបានទទួលវិវរណៈថែមទៅលើវិវរណៈ តម្រិះថែមទៅលើតម្រិះ ដើម្បីឲ្យអ្នកអាចបានស្គាល់សេចក្ដីអាថ៌កំបាំងទាំងឡាយ និងរបស់ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្ត—ដែលនឹងនាំឲ្យមានសេចក្ដីអំណរ ជាអ្វីដែលនាំឲ្យមានជីវិតដ៏នៅអស់កល្បជានិច្ច » ( គ. និង ស. ៤២:៦១ ) ។

## ការអញ្ជើញឲ្យអនុវត្ត

តើអ្នកអាចបង្កើនអំណរដែលអ្នករកឃើញនៅក្នុងជីវិតរបស់អ្នក តាមរយៈការងារបម្រើដោយរបៀបណា ? ■

គោលការណ៍នានានៅក្នុងអត្ថបទនេះអាចត្រូវបានអនុវត្តនៅក្នុងទំនាក់ទំនងប្រចាំថ្ងៃរបស់យើង ប៉ុន្តែមានគោលបំណងជួយដល់បងប្អូនប្រុសស្រីដែលផ្ដល់ការងារបម្រើ នៅក្នុងកិច្ចខិតខំរបស់ពួកគេឲ្យផ្ដល់ពរដល់បុគ្គលម្នាក់ៗ និងគ្រួសារដែលពួកគេត្រូវបានចាត់ទៅ ។

កំណត់ចំណាំ


១. « Joy » en.oxforddictionaries.com
២. រ័សុល អិម ណិលសុន « អំណរនិង ការរស់រានខាងវិញ្ញាណ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៨២ ។
៣. ជីន ប៊ី ប៊ីងហាំ « ការងារបម្រើដូចដែលព្រះអង្គសង្គ្រោះបានធ្វើ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៧ ។
៤. សូមមើល រ័សុល អិម ណិលសុន « As We Go Forward Together » *Liahona* ខែ មេសា ឆ្នាំ ២០១៨ ទំព័រ ៤–៧ ។
៥. ថូម៉ាស អេស ម៉នសុន « Finding Joy in the Journey » *Liahona* ខែ វិច្ឆកា ឆ្នាំ ២០០៨ ទំព័រ ៨៦ ។
៦. អិម រ័សុល បាឡឺដ « Finding Joy through Loving Service » *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៤៩ ។
៧. សូមមើល ឌៀថើរ អេស្វ អុជដូហ្វ « Living the Gospel Joyful » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ ១២០–១២៣ ។
៨. សូមមើល ហិនរី ប៊ី អាវរីង « O Remember, Remember » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៦៧ ។
៩. សូមមើល ជីន ប៊ី ប៊ីងហាំ « ដើម្បីឲ្យអំណរបងប្អូនបានពេញលេញ » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៨៧ ។
១០. សូមមើល ឌៀថើរ អេស្វ អុជដូហ្វ « Of Things That Matter Most » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ២១ ។
១១. សូមមើល ហ្គែរី អ៊ី ស្ទីវ៉ែនសុន « Spiritual Eclipse » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ៤៦ ។




ព្រះគ្រីស្ទ និងកុមារនៅក្នុងព្រះគម្ពីរមរមន ដោយ ដេល ភៀសុន





*នៅក្នុងគ្រានៃការបាក់ទឹកចិត្ត សូមចងចាំអំពី*

# ស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន

ជាពិសេស ពេលយើងមានអារម្មណ៍ថា គេបំភ្លេចយើង ឬព្រងើយកន្តើយដាក់យើង យើងត្រូវតែចងចាំថា ៖ ព្រះយេស៊ូវបានយាងទៅប្រទានជំនួយដល់ស្ត្រីមេម៉ាយម្នាក់ ក្នុងគ្រាដែលនាងមានអាសន្ន ហើយទ្រង់ក៏នឹងយាងមកជួយយើងផងដែរ ។

**ដោយ ខេស្សូ ជេ វ៉ុលសុន**
សាស្ត្រាចារ្យរងនៃព្រះគម្ពីរបុរាណ សាកលវិទ្យាល័យព្រិកហាំ យ៉ង់

ជូនកាលនៅក្នុងគ្រានៃភាពមួយថ្ងៃកាត់មួយថ្ងៃកោនៃជីវិត យើងអាចមានអារម្មណ៍ថា ព្រះពុំសូវសកម្មក្នុងជីវិតប្រចាំថ្ងៃរបស់យើងឡើយ ។ លំនាំរបស់យើងហាក់ដូចជានឿយណាយ និងគួរឲ្យធុញទ្រាន់ ។ គ្មានការផ្លាស់ប្ដូរច្រើនឡើយ ហើយជូនកាលវាពិបាករកឃើញចំណុចមួយដែលព្រះបានធ្វើអន្តរាគមន៍ដោយផ្ទាល់នៅក្នុងស្ថានភាពរបស់យើង ។ នៅពេលណាដែលខ្ញុំមានអារម្មណ៍ថា ជីវិតខ្ញុំផ្ទាល់គ្មានអ្វីសំខាន់ ជារឿយ ៗខ្ញុំគិតអំពីស្ត្រីម្នាក់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដែលអាចមានអារម្មណ៍បែបនេះ ។ នៅក្នុងព្រះគម្ពីរពុំបានបង្ហាញឈ្មោះរបស់គាត់ទេ ប៉ុន្តែយើងស្គាល់គាត់ដោយសាមញ្ញតាមរយៈឈ្មោះភូមិរបស់គាត់ និងស្ថានភាពអាពាហ៍ពិពាហ៍របស់គាត់ ។

ស្ត្រីនោះគឺជាស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន ហើយមានតែលូកាតែប៉ុណ្ណោះដែលកត់ត្រាអំពីដំណើររឿងដ៏អស្ចារ្យរបស់គាត់ ។ សម្រាប់ខ្ញុំ ស្ត្រីនោះតំណាងឲ្យភាពដ៏ចាំបាច់នៃការងារបម្រើផ្ទាល់ខ្លួនរបស់ព្រះអង្គសង្គ្រោះ និងរបៀបដែលទ្រង់បានឈោងទៅជួយអ្នកបាក់ទឹកចិត្ត ជាមនុស្សទូទៅនៅក្នុងសង្គមរបស់ទ្រង់ ។ ដំណើររឿងនោះប្រាប់យ៉ាងច្បាស់ថា តើព្រះជ្រាបដឹង និងខ្វល់ព្រះទ័យពីយើងដែរឬអត់ ។

សេចក្ដីសង្ខេបខ្លីមួយអំពីអព្ភូតហេតុមកពីលូកាជំពូកទី ៧ បង្ហាញថា ព្រះយេស៊ូវបានយាងទៅទាន់ ក្បួនដង្ហែសពយកទៅបញ្ចុះមួយ ហើយបានប្រោសយុវជនម្នាក់ឲ្យរស់រានមានជីវិតឡើងវិញប្រកបដោយអព្ភូតហេតុ ។ ប៉ុន្តែមានចំណុចជាច្រើនទៀតដែលត្រូវយល់អំពីរឿងនេះ ។ ដូចជាអព្ភូតហេតុទាំងអស់ដែរ ការយល់ពីបរិបទនៃព្រឹត្តិការណ៍នេះគឺជារឿងសំខាន់ជាពិសេសជាមួយនឹងអព្ភូតហេតុនេះ ។ ដោយបានបង្រៀននៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ នៅមជ្ឈមណ្ឌលទីក្រុងយេរូសាឡិម នោះខ្ញុំនឹងចែកចាយជាមួយអ្នកនូវការយល់ដឹងផ្ទាល់ខ្លួនមួយចំនួនអំពីអព្ភូតហេតុនេះ ។

ណាអ៊ីនគឺជាភូមិស្រុកស្រែតូចមួយនៅជំនាន់ព្រះយេស៊ូវ ដែលមានទីតាំងនៅជាប់នឹងភ្នំម៉ូរេ ដែលជាព្រំដែននៅផ្នែកខាង

កើតនៃជ្រលងភ្នំជេស្រៀល ។ ភូមិនោះនៅដាច់ស្រយាលពីគេ ។ មានតែផ្លូវមួយគត់ដែលអាចនាំទៅដល់ភូមិនោះបាន ។ នៅជំនាន់របស់ព្រះយេស៊ូវ ភូមិនេះមានទំហំតូច ហើយក្រខ្សត់ ហើយវានៅតែមានសភាពដូចនេះតាំងពីគ្រានោះមក ។ នៅគ្រាជាច្រើននៅក្នុងប្រវត្តិសាស្ត្រ ទីក្រុងនេះមានផ្ទះ ៣៤ ខ្នង និង មានប្រជាជនតែ ១៨៩ នាក់ប៉ុណ្ណោះ ។[1] សព្វថ្ងៃនេះ ភូមិនេះមានប្រជាជនរស់នៅប្រហែល ១៥០០ នាក់ ។

លូកាបានចាប់ផ្តើមដំណើររឿងរបស់លោក ដោយកត់សម្គាល់ថា ព្រះយេស៊ូវនៅក្រុងកាពើណិមមួយថ្ងៃមុន ហើយបានព្យាបាលបាវរបស់មេទ័ព ( សូមមើល លូកា ៧:១–១០ ) ។ បន្ទាប់មក យើងរៀនថា « *ដល់ថ្ងៃក្រោយមក* » ( ខទី ១១ ការគូសបញ្ជាក់បានបន្ថែម ) ព្រះអង្គសង្គ្រោះបានយាងចូលទៅទីក្រុងមួយហៅថាណាអ៊ីន ដោយមានសិស្សមួយក្រុមធំទៅជាមួយផងដែរ ។ ព្រឹត្តិការណ៍តាមលំដាប់លំដោយនេះគឺសំខាន់ណាស់ ។ ក្រុងកាពើណិមមានទីតាំងនៅភាគខាងជើងនៃឆ្នេរសមុទ្រកាលីឡេ មានកម្ពស់ ១៨៣ ម៉ែត្រក្រោមរយៈកម្ពស់ទឹកសមុទ្រ ។ ណាអ៊ីនមានចម្ងាយ ៤៨ គីឡូម៉ែត្រនៅទិសនីរតីនៃក្រុងកាពើណិម ដែលមានកម្ពស់ ២១៣ ម៉ែត្រលើរយៈកម្ពស់ទឹកសមុទ្រ ដែលតម្រូវឲ្យមានការឡើងទួលដ៏លំបាកទៅកាន់ភូមិណាអ៊ីន ។ ដើម្បីដើរពីក្រុងកាពើណិមទៅភូមិណាអ៊ីន យ៉ាងហោចណាស់ត្រូវចំណាយពេលពីមួយ ឬពីរថ្ងៃ ។ ថ្មីៗនេះ ក្រុមសិស្សយុវវ័យនៅមជ្ឈមណ្ឌល ប៊ី. វ៉ា. យូ. យេរូសាឡិម ត្រូវចំណាយពេល ១០ ម៉ោង ដើម្បីដើរលើផ្លូវនេះដែលបានចាក់សាបហើយ ។ នេះមានន័យថា ព្រះយេស៊ូវប្រហែលជាបានក្រោកពីព្រលឹមអុល ឬប្រហែលជាយាងដើរអំឡុងពេលយប់ ដើម្បីទៅឲ្យទាន់ក្បួនដង្ហែសពយកទៅបញ្ចុះនោះ « នៅថ្ងៃបន្ទាប់ » ។[2]

ពេលព្រះគ្រីស្ទយាងទៅដល់ទីក្រុង បន្ទាប់ពីការធ្វើដំណើរដ៏ឆ្ងាយ យុវជនម្នាក់មានអាយុប្រហែលជា ២០ ឆ្នាំជាង[3] ត្រូវបានគេសែងនៅលើបន្ទះក្តារសពមួយ ។ លូកាប្រាប់យើងថា យុវជននេះគឺជាកូនប្រុសតែម្នាក់គត់របស់ស្ត្រីមេម៉ាយម្នាក់ ហើយអ្នកប្រាជ្ញមួយចំនួនបកប្រែអត្ថបទភាសាក្រិកដើម្បីបញ្ជាក់ថា ស្ត្រីនោះគ្មានកូនណាផ្សេងទៀតទេ ។[4] អ្នកភូមិមួយក្រុមធំបានហែរហមគាត់នៅក្នុងគ្រាដ៏សោកនាដកម្មនៃអពមង្គលបំផុតក្នុងគ្រួសារនេះ ។

ប្រាកដណាស់ មរណភាពរបស់កូនប្រុសម្នាក់គឺជាសោកនាដកម្មមួយសម្រាប់ម្តាយម្នាក់ ប៉ុន្តែសូមពិចារណាអំពីផលវិបាកសម្រាប់ស្ត្រីមេម៉ាយនេះ ។ តើវាមានសភាពបែបណាទាំងក្នុងផ្នែកសង្គម ខាងវិញ្ញាណ និងហិរញ្ញវត្ថុ ដែលស្ត្រីមេម៉ាយម្នាក់គ្មានអ្នកស្នងមរតកនៅក្នុង






ពួកសាសន៍អ៊ីស្រាអែលជំនាន់បុរាណនោះ ? នៅក្នុងវប្បធម៌នៃព្រះគម្ពីរសញ្ញាចាស់ គេជឿថា ពេលស្វាមីស្លាប់ពីមុនចាស់ជរា វាជាទីសម្គាល់មួយស្ដីពីការជំនុំជម្រះរបស់ព្រះទៅលើអំពើបាប ។ ដូច្នេះហើយ មានមនុស្សមួយចំនួនជឿថា ព្រះបានដាក់ទារុណកម្មលើស្ត្រីមេម៉ាយដែលនៅរស់រានមានជីវិតនេះ ។ នៅក្នុងគម្ពីរនាងរស់ ពេលណាអូមីក្លាយជាស្ត្រីមេម៉ាយទាំងវ័យក្មេង គាត់បានសោកសៅ « លើសពីអ្វីៗទាំងអស់ ព្រះអម្ចាស់បានធ្វើបន្ទាល់ទាស់នឹងខ្ញុំ ហើយព្រះដ៏មានគ្រប់ទាំងព្រះចេស្ដាបានធ្វើឲ្យខ្ញុំខូចចិត្ត » ( នាងរស់ ១:២១ កំណែ International Standard ) ។[៥]

ពុំគ្រាន់តែមានការឈឺចាប់ខាងវិញ្ញាណ និងផ្លូវចិត្តប៉ុណ្ណោះទេ ស្ត្រីមេម៉ាយនៃស្រុកណាអ៊ីនក៏ជួបនឹងការវិនាសហិចហោចហិរញ្ញវត្ថុ—ដែលអាចប្រឈមមុខនឹងភាពអត់ឃ្លានផងដែរ ។[៦] តាមរយៈការរៀបការ ស្ត្រីម្នាក់ត្រូវបានចាត់ឲ្យទទួលបានហិរញ្ញវត្ថុខាងគ្រួសាររបស់ស្វាមីនាង ។ ប្រសិនបើស្វាមីនោះស្លាប់ នោះគេត្រូវផ្ទេរឲ្យទៅកូនប្រុសដែលមានអំណាចកូនច្បងរបស់នាង ។ ឥឡូវនេះ កូនប្រុសដែលមានអំណាចកូនច្បងរបស់ស្ត្រីមេម៉ាយនេះបានស្លាប់ នោះស្ត្រីមេម៉ាយនេះពុំទទួលបានហិរញ្ញវត្ថុអ្វីឡើយ ។ ប្រសិនបើកូនប្រុសគាត់មានអាយុ ២០ ឆ្នាំជាង នោះស្ត្រីមេម៉ាយនេះប្រហែលជាមានអាយុពាក់កណ្ដាលអាយុស្ត្រី រស់នៅក្នុងភូមិស្រុកស្រែតូចមួយដែលនៅដាច់ស្រយាលពីគេ ហើយឥឡូវនេះឃើញថា ខ្លួនគាត់គ្មានសល់អ្វីសោះទាំងខាងវិញ្ញាណ សង្គម និងហិរញ្ញវត្ថុ ។

ប្រាកដណាស់ នៅក្នុងរយៈពេលដ៏ខ្លី ពេលអ្នកភូមិបានសែងសពកូនប្រុសរបស់ស្ត្រីនេះយកទៅបញ្ចុះ ព្រះយេស៊ូវបានជួបនឹងក្បួនដង្ហែសព ហើយមាន « ព្រះហឫទ័យក្តួលអាណិតអាសូរដល់គាត់ណាស់ » ( លូកា ៧:១៣ ) ។ ប្រាកដណាស់ នេះអាចជាការវាយតម្លៃទាបបំផុតរបស់លូកា ។ យ៉ាងហោចណាស់ ព្រះយេស៊ូវបានដឹងពីស្ថានភាព





អស់សង្ឃឹមដ៏ខ្លាំងបំផុតនៃស្ត្រីមេម៉ាយនេះ ។ ប្រហែលជាគាត់បានចំណាយពេលមួយយប់ដេកលើកម្រាលដីផ្ទះគាត់ ទូលអង្វរព្រះវរបិតាសួគ៌ចង់ដឹងពីមូលហេតុ ។ ប្រហែលជាគាត់បានសួរសំណួរដោយបើកចំហរពីមូលហេតុដែលទ្រង់ តម្រូវឲ្យគាត់រស់នៅតបន្តទៀតនៅលើផែនដីនេះធ្វើអ្វី ។
ឬប្រហែលគាត់មានអារម្មណ៍ភ័យខ្លាចនឹងការបន្តនៅឯកោដែលគាត់នឹងជួបប្រទះ ។ យើងពុំដឹងទេ ។ ប៉ុន្តែយើងដឹងថា ព្រះអង្គសង្គ្រោះជ្រើសចាកចេញពីក្រុងកាពើណិមភ្លាម ដែលអាចតម្រូវឲ្យទ្រង់ធ្វើដំណើរទាំងយប់ ដើម្បីទៅឲ្យទាន់ក្បួនដង្ហែសពយកទៅបញ្ចុះពីមុនពួកគេដាក់សពនោះទៅក្នុងដី ។

មែនហើយ ពេលទ្រង់បានឃើញទឹកភ្នែកដក់នៅមុខគាត់ ពេលស្ត្រីនោះដើរពីក្រោយក្បួនដង្ហែសព ព្រះយេស៊ូវមានព្រះទ័យក្តួលអាណិតអាសូរដល់ស្ត្រីនេះ—ប៉ុន្តែវាបង្ហាញថា សេចក្តីអាណិតអាសូររបស់ទ្រង់កើតមកពីព្រះទ័យដែលទ្រង់បានមានយូរមកហើយពីមុនទ្រង់ « បាន » ទៅទាន់ក្បួនដង្ហែសពយកទៅបញ្ចុះនោះ ។ ទ្រង់បានយាងទៅដល់ទីនោះតែម្តង នៅគ្រាដែលស្ត្រីនោះត្រូវការ ។

ព្រះយេស៊ូវបានប្រាប់ស្ត្រីមេម៉ាយនោះ « កុំឲ្យយំ » ( ខទី ១៣ ) ។
ដោយពុំខ្លាចពីក្បួនវិត៍មិនស្អាតស្អំ នោះទ្រង់ « បានពាល់ក្តារមឈូស » ហើយក្បួនដង្ហែ « ក៏ឈប់ » ។ បន្ទាប់មកទ្រង់បានត្រាស់បង្គាប់ថា « អ្នកកំឡោះអើយ ខ្ញុំបង្គាប់អ្នកថា ចូរក្រោកឡើង

អ្នកដែលស្លាប់នោះ ក៏ក្រោកឡើងអង្គុយ ហើយចាប់តាំងនិយាយ ។ រួច [ ព្រះយេស៊ូវ ] ប្រគល់ដល់ម្តាយវិញ ( ខទី ១៤–១៥ ) ។ ជាធម្មតាទេ ហ្វូងអ្នកភូមិ និងអ្នកដើរតាមព្រះយេស៊ូវប្រាកដជាបានភ្ញាក់ផ្អើល ខណៈដែលទុក្ខសោករបស់ពួកគេបានបែរទៅរកអំណរដ៏បរិសុទ្ធ ។ ពួកគេទាំងអស់គ្នា « បានសរសើរតម្កើងដល់ព្រះដោយពាក្យថា មានហោរាមួយធំបានកើតឡើងក្នុងពួកយើង » ( ខទី ១៦ ) ។ ប៉ុន្តែអព្ភូតហេតនេះក៏បានសង្គ្រោះព្រលឹងមួយដែលអស់សង្ឃឹម ។ ព្រះយេស៊ូវបានជ្រាបថា មានអ្វីមួយមិនប្រក្រតីបានកើតឡើងចំពោះស្ត្រីនេះ—ជាបុគ្គលម្នាក់ដែលត្រូវបានគេចាត់ទុកមិនសូវសំខាន់នៅក្នុងវប្បធម៌របស់ពួកគេ ។ ស្ថានភាពរបស់គាត់ត្រូវការយកចិត្តទុកដាក់ពីទ្រង់ភ្លាម ទោះបីជាទ្រង់បានធ្វើដំណើរផ្លូវឆ្ងាយដើម្បីទៅដល់ទីនោះចំពេលនោះតែម្តង ។ ទ្រង់ជ្រាបដឹងពីស្ថានភាពអស់សង្ឃឹមរបស់គាត់ ហើយទ្រង់បានយាងទៅយ៉ាងលឿន ។ ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) បានថ្លែងពីសេចក្តីពិតដែលពុំអាចបដិសេធ « ថ្ងៃមួយ ពេលយើងមើលទៅព្រឹត្តិការណ៍ដែលហាក់ដូចជាចៃដន្យក្នុងជីវិតយើង យើងនឹងទទួលស្គាល់ថា ព្រឹត្តិការណ៍ទាំងនោះមិនដូចជាចៃដន្យទៀតឡើយ » ។[៧]

ឥឡូវនេះ វាត្រូវតែក្លាយជាដំណើររឿងកាន់តែអស្ចារ្យក្នុងព្រះគម្ពីរប៊ីបចំពោះយើង គឺលើកស្ទួយចិត្តយើងដូចព្រឹត្តិការណ៍នេះ ។ វាបញ្ជាក់យ៉ាងច្បាស់ថា ព្រះយេស៊ូវបានដឹងអំពីស្ត្រីមេម៉ាយក្រខ្សត់ ដែលគេបំភ្លេចចោល និងទុរគត៌នេះ ។ ជាពិសេស ពេល

យើងមានអារម្មណ៍ថា គេបំភ្លេចយើង ឬព្រងើយកន្តើយដាក់យើង ឬយើងពុំសូវសំខាន់ យើងត្រូវតែចងចាំថា ៖ ព្រះយេស៊ូវបានយាងទៅប្រទានជំនួយដល់ស្ត្រីមេម៉ាយម្នាក់ក្នុងគ្រាដែលនាងមានអាសន្ន ហើយទ្រង់ក៏នឹងយាងមកជួយយើងផងដែរ ។ លើសពីនេះទៀត មេរៀនទីពីរដែលយើងអាចទទួលបានពីគំរូរបស់ព្រះអង្គសង្គ្រោះយើងគឺ សារៈសំខាន់នៃការឈោងទៅផ្តល់ពរដល់មនុស្សដទៃដែលនៅជុំវិញយើង ។ មនុស្សជាច្រើនដែលយើងស្គាល់នឹងបាក់ទឹកចិត្តយូរម្តងៗ ។ ប្រសិនបើអ្នកអាចប្រាប់ពួកគេអំពី « បងស្រីណាអ៊ីន » និងរបៀបដែលព្រះអម្ចាស់ជ្រាបដឹងច្បាស់ពីការបាក់ទឹកចិត្ត និងវិបត្តិផ្ទាល់ខ្លួនដ៏ធំរបស់គាត់ នោះវាអាចប្រែយប់ឲ្យទៅជាថ្ងៃបាន ។ សូមចាំពីការអង្កេតដ៏រំជួលចិត្តមួយរបស់ ប្រធាន ស្ពែនសើរ ដបុលយូ឴ឃីមបឹល ( ១៨៩៥–១៩៨៥ ) ៖ « ព្រះស្គាល់យើង ហើយទ្រង់មើលថែយើង ។ ប៉ុន្តែជាធម្មតាទ្រង់ធ្វើដូចនោះតាមរយៈមនុស្សផ្សេងទៀតដែលបំពេញតម្រូវការរបស់យើង » ។[៨]

សម្រាប់ខ្ញុំអំឡុងពេលទ្រង់គង់នៅលើផែនដី ក្នុងចំណោមអព្ភូតហេតុទាំងអស់របស់ព្រះយេស៊ូវ មានអព្ភូតហេតុមួយចំនួនគឺទន់ភ្លន់ និងមានចិត្តអាណិតអាសូរដូចជាការប្រទានការងារបម្រើរបស់ទ្រង់ដល់ស្ត្រីមេម៉ាយនៃស្រុកណាអ៊ីន ។ វារំឭកយើងថា យើងសំខាន់ចំពោះទ្រង់ ហើយថាទ្រង់មិនដែលបំភ្លេចយើងឡើយ ។ យើងពុំអាចបំភ្លេចរឿងនោះបានឡើយ ។ ■

កំណត់ចំណាំ
១. សូមមើល E. Mills *Census of Palestine 1931: Population of Villages, Towns, and Administrative Areas* ( ឆ្នាំ ១៩៣២ ) ទំព័រ ៧៥ ។
២. សូមមើល S. Kent Brown *The Testimony of Luke* ( ឆ្នាំ ២០១៥ ) ទំព័រ ៣៦៤ ។
៣. សូមមើល Brown *The Testimony of Luke* ទំព័រ ៣៦៥ ។
៤. សូមមើល Brown *The Testimony of Luke* ទំព័រ ៣៦៥ ។
៥. នៅក្នុងអេសាយ ៥៤:៤ ព្រះអម្ចាស់ប្រាប់ស្ត្រីមេម៉ាយសាសន៍អ៊ីស្រាអែលថា ស្ត្រីនោះនឹង « មិននឹកចាំពីសេចក្តីដែលគេត្មះតិះដៀលនៃការបោះបង់ [ របស់គាត់ ] តទៅទៀតដែរ » ( ការបកប្រែថ្មីនៃភាសាអង់គ្លេស ) ។
៦. សូមមើល Brown *The Testimony of Luke* ទំព័រ ៣៦៥ ។
៧. ថូម៉ាស អេស ម៉នសុន នៅក្នុង យ៉ូសែប ប៊ី វ៉ឺតលីន « Lessons Learned in the Journey of Life » *Liahona* ខែ ឧសភា ឆ្នាំ ២០០១ ទំព័រ ៣៨ ។
៨. *Teachings of Presidents of the Church: Spencer W. Kimball* ( ឆ្នាំ ២០០៦ ) ទំព័រ ៨២ ។



ដើម្បីមើលវីដេអូព្រះគម្ពីរប៊ីប « Widow of Nain » សូមមើលគេហទំព័រ **lds.org/go/041917** ។





**ដោយប្រធាន ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ

# ចូរទុកចិត្តលើការដោះលែងឲ្យរួចរបស់ព្រះអង្គសង្គ្រោះ

ដង្វាយធួន និងការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះផ្ដល់ព្រះចេស្ដារដល់ទ្រង់ឲ្យពង្រឹងយើងនៅក្នុងការសាកល្បងរបស់យើង ឬដោះលែងយើងចេញពីការសាកល្បងទាំងនោះ ។

សម្រាប់ពួកយើងដែលបានបាត់បង់មនុស្សជាទីស្រឡាញ់ នោះពេលវេលាបន្ទាប់ពីពួកគេស្លាប់អាចនឹងមានទុក្ខ និងឯកោ—ហើយភាពកើតទុក្ខ និងឯកោនេះកើតមានកាន់តែខ្លាំងលើអស់អ្នកដែលគ្មានចំណេះដឹង និងទីបន្ទាល់អំពីដង្វាយធួន និងការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។ អ្នកចាំពីសិស្សពីរនាក់របស់ទ្រង់ដែលមានចិត្តសង្ស័យនៅលើផ្លូវទៅក្រុងអេម៉ោស ។ ព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញបាននៅក្បែរនឹងពួកគេ ហើយសួរពីមូលហេតុដែលពួកគេកើតទុក្ខ ។ លូកាផ្ដល់ចម្លើយនោះដល់យើង ៖

« នោះគេឆ្លើយថា គឺពីដំណើរលោកយេស៊ូវ ពីស្រុកណាសារ៉ែត ជាហោរា ដែលការលោកធ្វើ និងពាក្យសម្ដីរបស់លោកសុទ្ធតែមានឫទ្ធិនៅចំពោះព្រះ និងបណ្ដាជនទាំងឡាយផង ៖

ហើយពីបែបយ៉ាងណាដែលពួកសង្គ្រាជ និងពួកនាម៉ឺនយើងខ្ញុំ បានបញ្ជូនលោកទៅឲ្យជាប់ទោសដល់ជីវិត ហើយឆ្កាងលោកផង ។

តែយើងខ្ញុំបានសង្ឃឹមថា គឺលោកនេះហើយជាព្រះដែលរៀបនឹងប្រោសលោះសាសន៍អ៊ីស្រាអែលទាំងប៉ុន្មាន » ( លូកា ២៤:១៩–២១ ) ។

យើងទទួលបានការលួងលោមចេញពីចំណេះដឹង និងទីបន្ទាល់របស់យើងថា នោះ *គឺជា* ទ្រង់ដែលបានប្រោសលោះពួកសាសន៍អ៊ីស្រាអែល ។ គឺ *ជា* ទ្រង់ដែល « [ ផ្ដាច់ ] ចំណងនៃសេចក្ដីស្លាប់ » ( ម៉ូសាយ ១៥:២៣ ) ។ គឺ *ជា* ទ្រង់ដែលបានក្លាយជា « ផលដំបូងពីពួកអ្នកដែលបានដេកលក់ទៅហើយ » ( កូរិនថូសទី ១ ១៥:២០ ) ។ គឺ *ជា* ទ្រង់ដែលអាចធ្វើឲ្យសេចក្ដីសញ្ញានៃព្រះវិហារបរិសុទ្ធ ចងភ្ជាប់យើងជារៀងរហូតជាមួយអស់អ្នកដែលយើង « ស្រឡាញ់ដែលលាចាកទៅជាយូរ ! » [១]

នៅក្នុងរដូវការបុណ្យអ៊ីស្ទើរនេះ ខ្ញុំចង់ចែកចាយផ្នែកមួយនៃសារលិខិតការប្រជុំធម្មនិដ្ឋានរបស់ខ្ញុំ ដែលខ្ញុំបានថ្លែងកាលពីពីរបីឆ្នាំកន្លងទៅ អំពីព្រះចេស្ដានៃការដោះលែងឲ្យរួចរបស់ព្រះអង្គសង្គ្រោះ ។

រូបភាពលម្អិតមកពី សម្រាប់គោលបំណងនេះ ដោយ យ៉ុងសាំង ទទួលបានសិទ្ធិអនុញ្ញាតពី ហេរិន ឡាយ

វាបានពង្រឹងដល់ខ្ញុំ ពេលខ្ញុំបានរៀបចំសារលិខិតនេះ ហើយចែកចាយវា ។ ខ្ញុំសូមអធិស្ឋានថា សារលិខិតនេះនឹងពង្រឹងដល់អ្នកពេលអ្នកអានវា ។

ព្រះអង្គសង្គ្រោះជ្រាបដឹងពីការឈឺចាប់របស់យើង ។

អ្នកខ្លះស្លាប់ទាំងវ័យក្មេង ហើយទីបំផុតគឺយើងទាំងអស់គ្នានឹងស្លាប់ ។ ពួកយើងម្នាក់ៗនឹងត្រូវបានសាកល្បង ដោយការប្រឈមមុខនឹងសេចក្ដីស្លាប់នៃមនុស្សដែលយើងស្រឡាញ់ ។

កាលពីម្សិលម្ងៃ ខ្ញុំបានជួបបុរសម្នាក់ដែលខ្ញុំពុំបានឃើញគាត់តាំងពីប្រពន្ធគាត់បានចែកឋានទៅម្ល៉េះ ។ វាគឺជាឱកាសជួបជុំក្នុងថ្ងៃបុណ្យជាតិក្នុងសង្គមដ៏ជាទីមនោរម្យមួយ ។ គាត់បានញញឹមពេលគាត់ដើរសំដៅមករកខ្ញុំ ។ ដោយចាំពីមរណភាពរបស់ភរិយាគាត់ នោះខ្ញុំបានស្វាគមន៍គាត់ដោយប្រើឃ្លាសាមញ្ញមួយដោយប្រុងប្រយ័ត្នថា ៖ « តើលោកមានសុខទុក្ខយ៉ាងណាដែរ ? »

គាត់ឈប់ញញឹម ទឹកភ្នែកគាត់ចាប់ផ្ដើមហូរ ហើយគាត់បាននិយាយស្ងាត់ៗ ដោយស្មោះអស់ពីចិត្តថា « ខ្ញុំសុខសប្បាយធម្មតាទេ ។ ប៉ុន្តែវាពិបាកណាស់ » ។

វា *ពិតជា* ពិបាកណាស់ ដូចដែលភាគច្រើននៃអ្នកទាំងអស់គ្នាបានដឹង ហើយជូនកាលពួកយើងគ្រប់គ្នានឹងដឹង ។ ផ្នែកដ៏លំបាកបំផុតនៃការសាកល្បងនោះគឺ ដើម្បីស្គាល់នូវអ្វីដែលត្រូវធ្វើពេលកើតទុក្ខឯកោ និងបាត់បង់ ដែលយើងអាចទទួលអារម្មណ៍ ដែលជាផ្នែកមួយនៃអ្វីដែលយើងបាត់បង់ ។ ការឈឺចាប់អាចបន្តបៀមជាប់នៅដូចជាជំងឺរ៉ាំរ៉ៃមួយ ។ ហើយមនុស្សខ្លះ មានអារម្មណ៍នៃកំហឹង ឬភាពអយុត្តិធម៌ ។

ដង្វាយធួន និងការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះផ្ដល់ព្រះចេស្ដារដល់ទ្រង់ ឲ្យដោះលែងយើងចេញពីការសាកល្បងទាំងនោះ ។ តាមរយៈបទពិសោធន៍របស់ទ្រង់ ទ្រង់អាចជ្រាបដឹងពីការឈឺចាប់ទាំងអស់របស់យើង ។ ទ្រង់អាចជ្រាបដឹងការឈឺចាប់ទាំង



រូបភាពលម្អិតមកពី *ព្រះអម្ចាស់នៃការអធិស្ឋាន* ដោយ យ៉ុងសាំង ទទួលបានសិទ្ធិអនុញ្ញាតពី ហេរិន ឡាយ

នោះ តាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណ ប៉ុន្តែទ្រង់បានជ្រើសជ្រាបដឹងតាមរយៈការទទួលបទពិសោធន៍នូវការឈឺចាប់ដោយព្រះអង្គផ្ទាល់ជំនួសវិញ ។ នេះគឺជាដំណើររឿង ៖

« ហើយមើលចុះ ទ្រង់នឹងប្រសូតមកពីនាងម៉ារា នៅក្រុងយេរូសាឡិម ដែលជាដែនដីរបស់ពួកអយ្យកោដើមរបស់យើង នាងជាស្ត្រីព្រហ្មចារី គឺជាប្រដាប់ដ៏ជម្រើស ហើយពិសេសមួយ ដែលនឹងត្រូវគ្របដណ្ដប់ ហើយចាប់ទំផ្ទៃដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ហើយនឹងប្រសូតបានបុត្រមួយ មែនហើយ គឺជាព្រះរាជបុត្រានៃព្រះ ។

ហើយព្រះយេស៊ូវគ្រីស្ទនឹងយាងទៅដោយរងការឈឺចាប់ និងទុក្ខវេទនា និងការល្បួងគ្រប់បែបយ៉ាងហើយទ្រង់ធ្វើយ៉ាងនេះ គឺដើម្បីឲ្យបានបំពេញនូវពាក្យទាំងឡាយ ដែលបានថែងមកថា ទ្រង់នឹងលើកដាក់លើខ្លួនទ្រង់នូវការឈឺចាប់ និងជំងឺទាំងឡាយរបស់រាស្ត្រទ្រង់ ។

ហើយទ្រង់នឹងយកដាក់លើរូបអង្គទ្រង់នូវសេចក្ដីស្លាប់ ដើម្បីទ្រង់អាចស្រាយចំណងទាំងឡាយនៃសេចក្ដីស្លាប់ដែលចងរាស្ត្រទ្រង់ ហើយទ្រង់នឹងដាក់លើរូបអង្គទ្រង់នូវជំងឺឈឺចាប់របស់ពួកគេ ដើម្បីឲ្យព្រះហឫទ័យទ្រង់ បានពោរពេញទៅដោយសេចក្ដីមេត្តាករុណា ស្របតាមសាច់ឈាម ដើម្បីទ្រង់អាចដឹងស្របតាមសាច់ឈាមថា តើត្រូវជួយរាស្ត្រទ្រង់បែបណាតាមជំងឺរបស់គេ » ( អាលម៉ា ៧:១០–១២ ) ។

មនុស្សល្អនៅជុំវិញអ្នកនឹងព្យាយាមយល់ពីការឈឺចាប់របស់អ្នកនៅគ្រានៃការស្លាប់របស់មនុស្សជាទីស្រឡាញ់ណាម្នាក់ ។ ពួកគេអាចទទួលអារម្មណ៍នៃការឈឺចាប់ដោយខ្លួនពួកគេផ្ទាល់ ។ ព្រះអង្គសង្គ្រោះពុំគ្រាន់តែយល់ និងទទួលអារម្មណ៍ឈឺចាប់ប៉ុណ្ណោះទេ ទ្រង់ថែមទាំងទទួលអារម្មណ៍នៃការឈឺចាប់ផ្ទាល់ *របស់អ្នក* ផងដែរ ដែលមានតែអ្នកប៉ុណ្ណោះដែលអាចទទួលអារម្មណ៍ឈឺចាប់នោះ ។ ហើយទ្រង់ស្គាល់អ្នកយ៉ាងច្បាស់ ។ ទ្រង់ជ្រាបពីចិត្តរបស់អ្នក ។

## អញ្ជើញព្រះវិញ្ញាណបរិសុទ្ធ

ព្រះអង្គសង្គ្រោះអាចដឹងថា តើកិច្ចការណាមួយនៃកិច្ចការជាច្រើនដែលអ្នកអាចធ្វើ ដែលនឹងក្លាយជាល្អបំផុតសម្រាប់អ្នក នៅពេលអ្នកអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យលួងលោម និងប្រទានពរដល់អ្នក ។ ទ្រង់នឹងជ្រាបដឹងពីកន្លែងដែលល្អបំផុតសម្រាប់ឲ្យអ្នកចាប់ផ្ដើម ។ ជួនកាលវាគឺជាការអធិស្ឋាន ។ ជួនកាលវាគឺជាការទៅលួងលោមចិត្តបុគ្គលណាម្នាក់ទៀត ។ ខ្ញុំស្គាល់ស្ត្រីមេម៉ាយម្នាក់ដែលមានជំងឺពិការភាព ដែលត្រូវបានបំផុសគំនិតឲ្យទៅសួរសុខទុក្ខស្ត្រីមេម៉ាយម្នាក់ផ្សេងទៀត ។ ខ្ញុំពុំបាននៅទីនោះទេ ប៉ុន្តែខ្ញុំប្រាកដក្នុងចិត្តថា ព្រះអម្ចាស់បានបំផុសគំនិតសិស្សស្មោះត្រង់ម្នាក់ ឲ្យឈោងទៅជួយបុគ្គលម្នាក់ទៀត ហើយរឿងនោះអាចជួយពួកគេទាំងពីរនាក់ ។

*ព្រះអង្គសង្គ្រោះអាចជ្រាបពីទុក្ខព្រួយយើង តាមរយៈការបំផុសគំនិតពីព្រះវិញ្ញាណ ប៉ុន្តែទ្រង់បានជ្រើសរើសជ្រាបដឹងតាមរយៈការដកពិសោធន៍នូវទុក្ខព្រួយដោយព្រះអង្គទ្រង់ផ្ទាល់ជំនួសវិញ ។*

មានមធ្យោបាយជាច្រើនដែលព្រះអង្គសង្គ្រោះអាចជួយសង្គ្រោះអស់អ្នកដែលមានការឈឺចាប់ ហើយរបៀបនីមួយៗត្រូវម៉ាច់នឹងពួកគេតែម្ដង ។ ប៉ុន្តែអ្នកអាចប្រាកដថា ទ្រង់អាច និងធ្វើវាក្នុងរបៀបមួយដែលល្អបំផុតសម្រាប់អស់អ្នកដែលឈឺចាប់ និងសម្រាប់អស់អ្នកដែលនៅជុំវិញពួកគេ ។ ឧទាហរណ៍ពេលព្រះដោះលែងមនុស្សចេញពីការឈឺចាប់ គឺថាពួកគេមានអារម្មណ៍បន្ទាបខ្លួនដូចជាកូនក្មេងនៅចំពោះព្រះភក្ត្រទ្រង់ ។ គំរូដ៏អស្ចារ្យស្ដីពីអំណាចនៃភាពរាបសាដ៏ស្មោះត្រង់កើតចេញពីជីវិតរបស់យ៉ូប ( សូមមើល យ៉ូប ១:២០–២២ ) ។ ឧទាហរណ៍មួយទៀត ដែលយ៉ូបក៏មានដែរនោះគឺ សេចក្ដីជំនឿដែលមាននៅក្នុងអំណាចនៃការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ( សូមមើល យ៉ូប ១៩:២៦ ) ។

យើងទាំងអស់គ្នានឹងរស់ឡើងវិញ រួមទាំងមនុស្សជាទីស្រឡាញ់របស់យើងដែលបានស្លាប់ផងដែរ ។ ការជួបជុំដែលយើងនឹងមានជាមួយពួកគេ ពុំមែនជាការមានរូបកាយដែលពុកផុយនោះទេ ប៉ុន្តែជាការមានរូបកាយដែលនឹងពុំចេះស្លាប់ ពុំចាស់ និងគ្មានជំងឺឡើយ ។

ពេលព្រះអង្គសង្គ្រោះបង្ហាញព្រះកាយដល់ពួកសាវកទ្រង់បន្ទាប់ពីទ្រង់មានព្រះជន្មរស់ឡើងវិញ នោះទ្រង់ពុំគ្រាន់តែធានាជាថ្មីចំពោះទុក្ខសោករបស់ពួកគេប៉ុណ្ណោះទេ តែទ្រង់ថែមទាំងធានាចំពោះយើងទាំងអស់គ្នាដែលមានការឈឺចាប់ផងដែរ ។ ទ្រង់បានធានាដល់ពួកគេ និងពួកយើងជាថ្មីទៀតតាមរបៀបនេះ ៖

« សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្ដីសុខសាន្តចុះ ។ . . .

ចូរមើលមកដៃ និងជើងខ្ញុំឲ្យបានដឹងថា នេះគឺខ្ញុំពិតមែន ចូរពាល់ខ្ញុំមើល ដ្បិតខ្មោចគ្មានសាច់ឬឆ្អឹង ដូចជាឃើញខ្ញុំនេះទេ » ( លូកា ២៤:៣៦, ៣៩ ) ។

ព្រះអម្ចាស់អាចបំផុសគំនិតយើងឲ្យទទួលនូវព្រះចេស្ដានៃការដោះលែងចេញពីការឈឺចាប់របស់យើងក្នុងរបៀបមួយដែលស័ក្ដិសមបំផុតសម្រាប់យើង ។ យើងអាចជ្រើសបម្រើមនុស្សដទៃសម្រាប់ព្រះអម្ចាស់ ។ យើងអាចថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ អំពីដំណឹងល្អរបស់ទ្រង់ អំពីការស្ដារឡើងវិញនៃសាសនាចក្ររបស់ទ្រង់ និងការមានព្រះជន្មរស់ឡើងវិញរបស់ទ្រង់ ។ យើងអាចគោរពបទបញ្ញត្តិរបស់ទ្រង់ ។

ជម្រើសទាំងអស់នោះអញ្ជើញព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គដែលលួងលោមយើងក្នុងរបៀបមួយដែលត្រូវនឹងតម្រូវការរបស់យើង ។ ហើយតាមរយៈការបំផុសគំនិតរបស់ព្រះវិញ្ញាណនោះយើងអាចមានទីបន្ទាល់អំពីការរស់ឡើងវិញ និងទស្សនៈច្បាស់លាស់អំពីការជួបជុំដ៏រុងរឿងនាពេលខាងមុខ ។ ខ្ញុំទទួលអារម្មណ៍លួងលោមនោះ នៅពេលខ្ញុំបានមើលទៅថ្មក្បាលផ្នូរនៃបុគ្គលម្នាក់ដែលខ្ញុំស្គាល់—ជាបុគ្គលដែលខ្ញុំដឹងថា ខ្ញុំអាចឱបពួកគេក្នុងរង្វង់ដៃខ្ញុំនៅពេលខាងមុខ ។ ដោយដឹងថា ខ្ញុំពុំគ្រាន់តែអាចដោះលែងចេញពីការឈឺចាប់ប៉ុណ្ណោះនោះទេ ខ្ញុំថែមទាំងបានពោរពេញដោយការរំពឹងទុកមួយដ៏រីករាយទៀតផង ។

អ្នកអាចប្រាកដក្នុងចិត្តថា ព្រះអង្គសង្គ្រោះអាច ហើយនឹងជួយ តាមរបៀបមួយដ៏ល្អបំផុតដល់អស់អ្នកដែលមានទុក្ខព្រួយ និងអស់អ្នកដែលនៅជុំវិញពួកគេ ។

ដោយមានបុគ្គលតូចនោះបានរស់នៅរហូតដល់ចាស់ទុំ នោះនាងត្រូវការការដោះលែងឲ្យរួចក្នុងការសាកល្បងផ្សេងៗទៀត ។ នាងត្រូវបានសាកល្បងឲ្យបន្តនៅស្មោះត្រង់នឹងព្រះ តាមរយៈឧបសគ្គខាងសាច់ឈាម និងខាងវិញ្ញាណ ដែលកើតមានលើមនុស្សគ្រប់រូប ។ ទោះបីជារូបកាយនេះជាការបង្កបង្កើតដ៏សំខាន់ក្ដី ការរក្សាវាឲ្យដំណើរការគឺជាឧបសគ្គមួយដែលសាកល្បងយើងទាំងអស់គ្នា ។ មនុស្សគ្រប់រូបត្រូវតែពុះពារឆ្លងកាត់នូវជំងឺ និងឥទ្ធិពលនៃភាពចាស់ជរា ។

« ចូរមានចិត្តរាបសា »

ព្រះចេស្ដានៃការដោះលែងឲ្យរួចពីការសាកល្បងរបស់យើងគឺមានសម្រាប់យើង ។ វាដំណើរការក្នុងរបៀបមួយដូចនឹងការដោះលែងចេញពីការសាកល្បងដែលកើតឡើងនឹងការប្រឈមមុខនឹងសេចក្ដីស្លាប់របស់មនុស្សជាទីស្រឡាញ់ ។ ដូចជាការដោះលែងនោះដែលពុំមែនតែងតែជាការប្រោសប្រណីជីវិតដល់មនុស្សជាទីស្រឡាញ់ជានិច្ច នោះការដោះលែងចេញពីការសាកល្បងផ្សេងទៀតអាចពុំត្រូវបានដកចេញពីពួកគេដូចគ្នានោះដែរ ។ ព្រះអម្ចាស់អាចពុំបន្ធូរការឈឺចាប់ឡើយ រហូតដល់យើងអភិវឌ្ឍនូវសេចក្ដីជំនឿ ដើម្បីធ្វើជម្រើសដែលនឹងនាំព្រះចេស្ដានៃដង្វាយធួនឲ្យដំណើរការក្នុងជីវិតរបស់យើងសិន ។ ទ្រង់ពុំតម្រូវរឿងនោះចេញពីភាពព្រងើយកន្តើយឡើយ ប៉ុន្តែត្រូវចេញពីសេចក្ដីស្រឡាញ់សម្រាប់យើង ។

មគ្គុទេសក៍មួយសម្រាប់ការទទួលព្រះចេស្ដានៃការដោះលែងឲ្យរួចរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតនេះ ត្រូវបានប្រទានឲ្យទៅថូម៉ាស ប៊ី ម៉ាស ដែលកាលនោះគឺជាប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ លោកមានការសាកល្បងដ៏លំបាក ហើយព្រះអម្ចាស់បានជ្រាបថា លោកនឹងប្រឈមមុខនឹងការសាកល្បងជាច្រើនទៀត ។ នេះគឺជាព្រះឱវាទចំពោះលោក ដែលខ្ញុំបានយកវាដាក់លើខ្លួនខ្ញុំ ហើយសូមផ្ដល់ជូនដល់អ្នក ៖ « ចូរមានចិត្តរាបសា ហើយ



រូបភាពលម្អិតមកពី ចៀមដែលបាត់ ដោយ យ៉ុងសាំង ទទួលបានសិទ្ធិអនុញ្ញាតពី ហេវិន ឡាយ

ព្រះអម្ចាស់ជាព្រះរបស់អ្នកនឹងដឹកដៃអ្នក ហើយប្រទានចម្លើយដល់បទអធិស្ឋានទាំងឡាយរបស់អ្នក » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ១១២:១០ ) ។

ព្រះអម្ចាស់សព្វព្រះទ័យដឹកនាំយើងទៅរកការដោះលែងជានិច្ចតាមរយៈការប្រែកាន់តែសុចរិតរបស់យើង ។ ការណ៍នោះតម្រូវឲ្យមានការប្រែចិត្ត ។ ហើយវាត្រូវការការបន្ទាបខ្លួន ។ ដូច្នេះផ្លូវទៅកាន់ការដោះលែង តម្រូវឲ្យមានការបន្ទាបខ្លួន ដើម្បីព្រះអម្ចាស់អាចដឹកនាំយើងដោយដឹកដៃទៅកន្លែងដែលទ្រង់មានព្រះទ័យចង់យកយើងទៅ ដោយឆ្លងកាត់បញ្ហារបស់យើង ហើយបន្តទៅកាន់ភាពបរិសុទ្ធ ។

ការសាកល្បងអាចបង្កើតឲ្យមានការពេញចិត្ត ឬការបាក់ទឹកចិត្ត ។ ភាពរាបសាដែលអ្នក និងខ្ញុំត្រូវការសម្រាប់ឲ្យព្រះអម្ចាស់ដឹកនាំយើងដោយដឹកដៃយើងនោះ កើតឡើងពីសេចក្ដីជំនឿ ។ វាកើតឡើងពីសេចក្ដីជំនឿដែលថា ព្រះពិតជាមានព្រះជន្មរស់នៅ ថាទ្រង់ស្រឡាញ់ពួកយើង ហើយអ្វីដែលទ្រង់សព្វព្រះទ័យ—យ៉ាងខ្លាំង—ឲ្យយើងមាននោះគឺជាអ្វីដែលល្អបំផុតសម្រាប់យើង ។

ព្រះអង្គសង្គ្រោះបានបង្ហាញយើងនូវភាពរាបសានោះ ។ អ្នកបានអាននូវរបៀបដែលទ្រង់បានអធិស្ឋាននៅក្នុងច្បារគែតសេម៉ានីអំឡុងពេលទ្រង់រងទុក្ខនូវការសាកល្បងជំនួសពួកយើង ដែលហួសពីសមត្ថភាពដែលយើងអាចយល់បាន ឬស៊ូទ្រាំបាន ឬឲ្យខ្ញុំពិពណ៌នាបាន ។ អ្នកចាំពីការអធិស្ឋានរបស់ទ្រង់ថា ៖ « ឱព្រះវរបិតាអើយ បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូលបង្គំទៅ ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ » ( លូកា ២២:៤២ ) ។

ទ្រង់បានស្គាល់ ហើយបានទុកព្រះទ័យលើព្រះវរបិតាសួគ៌ទ្រង់គឺព្រះអេឡូហិមដ៏មហិមា ។ ទ្រង់បានជ្រាបថា ព្រះវរបិតាទ្រង់មានគ្រប់ព្រះចេស្ដាទាំងអស់ និងមានព្រះទ័យសប្បុរសជាខ្លាំង ។ បុត្រាសំណព្វបានទូលសូមដោយពាក្យរាបសា—ដូចជាកុមារតូចៗទាំងនោះ—ទូលសូមនូវព្រះចេស្ដានៃការដោះលែងឲ្យរួច ដើម្បីជួយទ្រង់ ។

## ចូរក្លាហាន និងទទួលការលួងលោម

ព្រះវរបិតាពុំបានដោះលែងព្រះរាជបុត្រាឲ្យរួចតាមរយៈការដកយកការសាកល្បងចេញឡើយ ។ សម្រាប់ជាប្រយោជន៍យើង ទ្រង់ពុំធ្វើបែបនោះឡើយ ប៉ុន្តែទ្រង់អនុញ្ញាតឲ្យព្រះអង្គសង្គ្រោះបញ្ចប់នូវបេសកកម្មដែលទ្រង់យាងចុះមកធ្វើ ។ ប៉ុន្តែយើងអាចមានចិត្តក្លាហាន និងទទួលការលួងលោមជារៀងរហូត ចេញពីការដឹងអំពីជំនួយដែលព្រះវរបិតាបានប្រទានមក ៖

« នោះមានទេវតាលេចមកឯទ្រង់អំពីស្ថានសួគ៌ មកចម្រើនកម្លាំងថ្វាយ ។

ហើយដោយទ្រង់កើតទុក្ខជាខ្លាំង បានជាទ្រង់អធិស្ឋានទទូចរឹតតែខ្លាំងឡើង ញើសទ្រង់ក៏ត្រឡប់ដូចជាដំណក់ឈាមដ៏ធំៗ ស្រក់ទៅដី ។

រួចទ្រង់ក្រោកពីទីអធិស្ឋាន វិលទៅឯពួកសិស្សវិញ ក៏ឃើញគេដេកលក់ដោយព្រួយចិត្ត ។

ទ្រង់មានព្រះបន្ទូលថា ហេតុអ្វីបានជាដេកលក់ដូច្នេះ ចូរក្រោកឡើងអធិស្ឋានចុះ ដើម្បីកុំឲ្យត្រូវសេចក្ដីល្បួងឡើយ » ( លូកា ២២:៤៣–៤៦ ) ។

ព្រះអង្គសង្គ្រោះបានអធិស្ឋានទូលសូមការដោះលែងឲ្យរួច ។ អ្វីដែលទ្រង់បានពោលពាក្យអធិស្ឋានពុំមែនជាការគេចចេញពីការសាកល្បងនោះទេ ប៉ុន្តែជាការលួងលោមសមល្មមដើម្បីឆ្លងកាត់ការសាកល្បងនោះដោយរុងរឿង ។

ការត្រាស់បង្គាប់របស់ទ្រង់ទៅកាន់សិស្សទ្រង់ ដែលពួកគេនឹងត្រូវទទួលការសាកល្បងគឺជាមគ្គុទេសក៍មួយសម្រាប់យើង ។ យើងអាចប្ដេជ្ញាចិត្តធ្វើតាមការបង្គាប់នោះ ។ យើងអាចប្ដេជ្ញាចិត្តក្រោកឡើង ហើយអធិស្ឋានដោយសេចក្ដីជំនឿ និងរាបសាបំផុត ។ ហើយយើងអាចធ្វើតាមការត្រាស់បង្គាប់បន្ថែមនៅក្នុងគម្ពីរម៉ាកុស ៖ « ចូរក្រោកឡើង យើងទៅ » ( ម៉ាកុស ១៤:៤២ ) ។

> *ព្រះយេស៊ូវគ្រីស្ទបានបង់ថ្លៃលោះបាបសម្រាប់អំពើបាបទាំងអស់របស់យើង និងបុត្រាបុត្រីទាំងអស់របស់ព្រះវរបិតាសួគ៌ ដើម្បីយើងអាចត្រូវបានដោះលែងឲ្យរួចពីសេចក្ដីស្លាប់ និងអំពើបាប ។*

ចេញពីខគម្ពីរនេះ អ្នកមានការទូន្មានសម្រាប់ហែលឆ្លងកាត់ការសាកល្បងខាងសាច់ឈាម និងខាងវិញ្ញាណនៃជីវិត ។ អ្នកនឹងត្រូវការជំនួយរបស់ព្រះ បន្ទាប់ពីអ្នកបានធ្វើអស់ពីសមត្ថភាពដែលអ្នកអាចធ្វើសម្រាប់ខ្លួនអ្នក ។ ដូច្នេះ ចូរក្រោកឡើង ហើយទៅ ប៉ុន្តែសូមទទួលជំនួយពីទ្រង់ឲ្យបានកាន់តែឆាប់ កុំចាំរហូតដល់មានវិបត្តិ ទើបទូលសូមរកការដោះលែងនោះ ។

ខ្ញុំសូមថ្លែងជាសាក្សីដ៏ឱឡារិករបស់ខ្ញុំថា ព្រះគឺជាព្រះវរបិតាមានព្រះជន្មរស់នៅ ហើយទ្រង់ស្រឡាញ់អ្នក ។ ខ្ញុំដឹងរឿងនោះ ។ ផែនការនៃសុភមង្គលរបស់ទ្រង់គឺល្អឥតខ្ចោះ ហើយវា *ជា* ផែនការនៃសុភមង្គល ។ ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ឡើងវិញ ហើយយើងនឹងរស់ឡើងវិញផងដែរ ។ ទ្រង់បានរងទុក្ខ ដើម្បីទ្រង់អាចជួយយើងក្នុងគ្រប់ការសាកល្បងរបស់យើង ។ ទ្រង់បានបង់ថ្លៃលោះសម្រាប់អំពើបាបទាំងអស់របស់យើង និងបុត្រាបុត្រីទាំងអស់របស់ព្រះវរបិតាសួគ៌ ដើម្បីយើងអាចត្រូវបានដោះលែងឲ្យរួចពីសេចក្ដីស្លាប់ និងអំពើបាប ។

ខ្ញុំដឹងថា នៅក្នុងសាសនាចក្រព្រះយេស៊ូវគ្រីស្ទ ព្រះវិញ្ញាណបរិសុទ្ធអាចយាងមកលួងលោម និងសម្អាតយើង ពេលយើងធ្វើតាមលោកចៅហ្វាយ ។ សូមឲ្យអ្នកទទួលការលួងលោម និងជំនួយរបស់ទ្រង់ក្នុងគ្រាអាសន្នរបស់អ្នក ពេញទាំងការសាកល្បងនានានៃជីវិតរបស់អ្នក ។ ■

*ដកស្រង់ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន « The Power of Deliverance » ដែលបានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ។*

កំណត់ចំណាំ

1. « ដើរតាមពន្លឺ » *ទំនុកតម្កើង* លេខ ៤៦ ។



រឿងលម្អិតដកស្រង់ចេញពី *គែតសេម៉ានី* ដោយជេ ខឺក រីឆាដ, មែកដើមអូលីវមកពី GETTY IMAGES

# នៅក្នុងសួនច្បារដ៏ពិសិដ្ឋ

*ដោយត្រិះរិះពិចារណា* ♩ = ៦០–៦៨

ទំនុកបទ និង ទំនុកភ្លេង ដោយ ថាមមី ស៊ីមីស្ទើរ រ៉ូប៊ីនសុន




© 2003 Tammy Simister Robinson. All rights reserved.
បទ ចម្រៀងនេះ អាចថតចម្លងប្រើប្រាស់ជាបន្ទាប់បន្សំនៅ ក្នុងព្រះវិហារ ឬនៅគេហដ្ឋានដែលពុំមានលក្ខណៈជាពាណិជ្ជកម្មឡើយ ។
សេចក្ដីជូនដំណឹងនេះត្រូវបិទនៅលើសំណៅ ថតចម្លងនីមួយៗ ។



ដោយ ប្រែអិន ខេ អាស្តុន
ទីប្រឹក្សាទីពីរនៅក្នុងគណៈ
ប្រធានសាលាថ្ងៃអាទិត្យទូទៅ

# មេរៀនបីស្ដីពីសេចក្ដីស្រឡាញ់ អំណរ និងភាពសុខសាន្ត

ការធ្វើតាមជំហានទាំងបីនេះអាចធ្វើឲ្យមានការផ្លាស់ប្ដូរដ៏ធំនៅក្នុងជីវិតរបស់អ្នក ហើយជួយអ្នកឲ្យទទួលអារម្មណ៍នៃផលផ្លែនៃព្រះវិញ្ញាណ ។

កាលខ្ញុំរៀននៅមហាវិទ្យាល័យ នោះខ្ញុំបានគិតច្រើនពីអនាគតខ្ញុំ ។ ពេលខ្ញុំឈានដល់ពេលអនាគត—មានន័យថា ជីវិតបន្ទាប់ពីមហាវិទ្យាល័យ—ខ្ញុំបានរៀនមេរៀនបីសំខាន់ៗ ដែលធ្វើឲ្យជីវិតខ្ញុំមានការផ្លាស់ប្ដូរយ៉ាងធំ ។ ខ្ញុំចង់ចែកចាយមេរៀនទាំងនេះជាមួយអ្នក ដោយសង្ឃឹមថា អ្នកពុំរៀនវាយូរដូចខ្ញុំឡើយ ពេលអ្នករៀនអំពីមេរៀនទាំងនេះ ។ មេរៀនទាំងនេះអាចជួយអ្នកឲ្យរកឃើញអំណរដ៏ប្រសើរនៅក្នុងជីវិត—ហើយទីបំផុតទទួលបានភាពតម្កើងឡើងជាមួយនឹងព្រះវរបិតាសួគ៌របស់យើង ។



## ១. ស្វែងរកសុភមង្គល ភាពសុខសាន្ត និងព្រះវិញ្ញាណបរិសុទ្ធ

ខ្ញុំបានជួបមេលីនដាភរិយាខ្ញុំ អំឡុងឆ្នាំទីពីរនៃមហាវិទ្យាល័យ ប្រហែលជាប្រាំមួយខែបន្ទាប់ពីខ្ញុំបានត្រឡប់ពីបេសកកម្មរបស់ខ្ញុំវិញ ។ ខ្ញុំបានដឹងភ្លាមថា ខ្ញុំចង់រៀបការនឹងនាង ។ ប៉ុន្តែមេលីនដាពុំមានបទពិសោធន៍ដូចនោះទេ ។ គាត់ពុំបានដឹងឡើយ រហូតដល់ប្រាំឆ្នាំក្រោយមកទើបគាត់ទទួលចម្លើយថា

វានឹង « ល្អ » ប្រសិនបើគាត់រៀបការនឹងខ្ញុំ ។

អំឡុងពេលប្រាំឆ្នាំនោះ ខ្ញុំមានការសាកល្បងដ៏លំបាកមួយក្នុងជីវិតខ្ញុំ ។ ខ្ញុំបានស្គាល់មនុស្សដែលខ្ញុំត្រូវរៀបការជាមួយ ហើយព្រះវិញ្ញាណបានជំរុញចិត្តខ្ញុំ ប៉ុន្តែខ្ញុំហាក់ដូចជាពុំអាចឈោងទៅសម្រេចបានគោលដៅនោះឡើយ ។

មិនយូរប៉ុន្មានក្រោយពីខ្ញុំបានបញ្ចប់ការសិក្សា មេលីនដាបានសម្រេចចិត្តទៅបម្រើបេសកកម្ម—ខ្ញុំជឿថា នោះគឺជាផ្នែកមួយនៃការជំរុញចិត្តរបស់នាងដើម្បីទៅឲ្យឆ្ងាយពីខ្ញុំ ។ មានគ្រាជាច្រើនអំឡុងបេសកកម្មរបស់នាង ពេលខ្ញុំរងទុក្ខ ដោយសារខ្ញុំបានផ្តោតទៅលើអ្វីដែលខ្ញុំគ្មាន ។ ប៉ុន្តែ ខ្ញុំបានសិក្សាព្រះគម្ពីរ និងអធិស្ឋានរៀងរាល់ថ្ងៃ បម្រើនៅក្នុងសាសនាចក្រ ហើយព្យាយាមធ្វើកិច្ចការដែលបានយាងព្រះវិញ្ញាណបរិសុទ្ធឲ្យចូលមកក្នុងជីវិតខ្ញុំ ។

នៅព្រឹកថ្ងៃអាទិត្យស្រោងៗដ៏ត្រជាក់មួយនៅទីក្រុងមីនេប៉ូលីស រដ្ឋមីណេសូតា ស.រ.អា. អំឡុងពេលខ្ញុំកំពុងបើកឡានទៅការប្រជុំសាសនាចក្រ ខ្ញុំបានគិតថា « តាមពិត ខ្ញុំត្រូវរងទុក្ខខ្លាំងនៅពេលនេះ ។ រឿងគ្រប់យ៉ាងពុំបានកើតឡើងដូចអ្វីដែលចិត្តខ្ញុំចង់បានឡើយ ។ ប៉ុន្តែខ្ញុំពុំរងទុក្ខនោះទេ ។ ខ្ញុំមានអារម្មណ៍រីករាយដែលមិនគួរឲ្យជឿ ។

ឥឡូវតើខ្ញុំអាចរីករាយដូចម្ដេចកើត បើខ្ញុំកំពុងឆ្លងកាត់ការសាកល្បងដ៏លំបាកមួយនោះ ?

ចម្លើយត្រូវបានរកឃើញនៅក្នុង កាឡាទី ៥:២២–២៣ ៖ « ផលផ្លែនៃព្រះវិញ្ញាណនោះគឺសេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត និងដឹងខ្នាត » ។

ដោយសារខ្ញុំបានធ្វើកិច្ចការដែលយាងព្រះវិញ្ញាណមកក្នុងជីវិតខ្ញុំ នោះខ្ញុំបានទទួលសេចក្ដីស្រឡាញ់របស់ព្រះ ។ ខ្ញុំបានទទួលអារម្មណ៍នៃអំណរ និងភាពសុខសាន្ត ។ ខ្ញុំអាចរងទុក្ខបានយូរ ហើយនៅតែមានចិត្តរីករាយ ។

ការមានសេចក្ដីស្រឡាញ់ អំណរ និងភាពសុខសាន្តនៅក្នុងជីវិតយើង គ្រួសារយើង និងអាពាហ៍ពិពាហ៍យើង ពុំកើតឡើងពីការមានផ្ទះធំ ឡានស្អាត សម្លៀកបំពាក់ម៉ូដថ្មីៗ ជោគជ័យក្នុងមុខរបរ ឬអ្វីៗផ្សេងៗទៀតដែលលោកិយនេះនិយាយថាជាសុភមង្គលឡើយ ។ ប្រាកដណាស់ ដោយសារអារម្មណ៍នៃសេចក្ដីស្រឡាញ់ អំណរ និងភាពសុខសាន្តកើតចេញពីព្រះវិញ្ញាណ ការទទួលនូវអារម្មណ៍ទាំងនេះពុំទាក់ទងនឹងកាលៈទេសៈខាងសាច់ឈាមរបស់យើងទាល់តែសោះ ។

*ពេលអ្នកធ្វើកិច្ចការតូចតាច ហើយទុកចិត្តលើការពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ នោះអ្នកអាចរកឃើញសេចក្ដីស្រឡាញ់ អំណរ ភាពសុខសាន្ត និងសុភមង្គល មិនថាកាលៈទេសៈរបស់អ្នកបែបណានោះទេ ។*

សូមយល់ថា ខ្ញុំពុំមែននិយាយថា យើងនឹងរីករាយជានិច្ច ឬកាលៈទេសៈខាងសាច់ឈាមរបស់យើងពុំប៉ះពាល់ដល់សុភមង្គលរបស់យើងនោះទេ ។ ប្រាកដណាស់ ប្រសិនបើយើងពុំភ្លក់ភាពជូរចត់ទេ នោះយើងពុំអាចដឹងរសជាតិផ្អែមឡើយ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ២៩:៣៩ សូមមើលផងដែរ ម៉ូសេ ៦:៥៥ ) ។

ខ្ញុំត្រូវតែជួបនូវឧបសគ្គនៅក្នុងជីវិត ។ លើសពីនោះទៀត លក្ខខណ្ឌខាងសាច់ឈាម និងផ្លូវចិត្តមួយចំនួន អាចបណ្ដាលឲ្យយើងមានការរងទុក្ខដ៏ធំ ហើយធ្វើឲ្យវាលំបាកខ្លាំងសម្រាប់យើងក្នុងការទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។ ប៉ុន្តែប្រសិនបើយើងព្យាយាមធ្វើឲ្យមានព្រះវិញ្ញាណនៅក្នុងជីវិតយើង ហើយទុកចិត្តលើព្រះ ជាទូទៅយើងអាចមានភាពរីករាយ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ចេញពីបទពិសោធន៍ផ្ទាល់ថា រឿងនេះជាការពិត ។ ដោយសារបទពិសោធន៍ខ្ញុំអំឡុងពេលមេលីនដានៅបម្រើបេសកកម្ម នោះខ្ញុំបានកត់សម្គាល់ឃើញថា ប្រសិនបើខ្ញុំធ្វើកិច្ចការនានាដែលយាងព្រះវិញ្ញាណមកក្នុងជីវិតខ្ញុំ រួមមានការជ្រើសជឿ និងទទួលយកថា រឿងនោះនឹងដំណើរតាមព្រះទ័យរបស់ព្រះ ជាទូទៅខ្ញុំមានភាពរីករាយ ( សូមមើល យ៉ាកុប ៣:២ ) ។១

## ២. កុំជឿលើអារម្មណ៍ក្លែងក្លាយ

សាតាំងផ្ដល់ជម្រើសក្លែងក្លាយផ្សេងៗស្រដៀងទៅនឹងអ្វីៗទាំងអស់ដែលព្រះបានធ្វើ ក្នុងគោលបំណងដើម្បីបំភាន់ និងបោកបញ្ឆោតយើង ។ ទោះជាការប៉ុនប៉ងរបស់សាតាំងដើម្បីបញ្ចុះបញ្ចូលយើងក្ដី ផ្ទុយទៅវិញព្រះអង្គសង្គ្រោះបង្រៀនយើងថា « ដើមដែលអាក្រក់ [ ពុំ ] អាចនឹងបញ្ចេញផលល្អបាន » ( នីហ្វៃទី ៣ ១៤:១៨ ) ។ ដោយសារសាតាំងគឺជាដើមដែលអាក្រក់ នោះវាពុំអាចធ្វើឲ្យយើងទទួលអារម្មណ៍នៃ « សេចក្ដីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត [ និង ] ដឹងខ្នាត » ឡើយ ( កាឡាទី ៥:២២–២៣ ) ។ ផ្ទុយទៅវិញ សាតាំងចង់ធ្វើឲ្យយើងរងទុក្ខ ( សូមមើល នីហ្វៃទី ២ ២:២៧ ) ។

ដូច្នេះតើសាតាំងធ្វើអ្វីខ្លះ ? វាព្យាយាមបោកបញ្ឆោតយើង ។

មិត្តភក្ដិម្នាក់របស់ខ្ញុំគឺជាអ្នកជម្រើសម្នាក់ត្រូវបានវាបោកបញ្ឆោត ។ មិត្តភក្ដិរបស់ខ្ញុំបានបម្រើបេសកកម្ម ហើយគាត់គឺជាអ្នកផ្សព្វផ្សាយសាសនាដ៏ឆ្នើមមួយរូប ។ ពេលគាត់ត្រឡប់ពីបេសកកម្មគាត់ទៅផ្ទះវិញ គាត់

មានបំណងធ្វើកិច្ចការតូចៗទាំងអស់ ដែលធ្វើឲ្យគាត់មានព្រះវិញ្ញាណចូលមកគង់ក្នុងជីវិតគាត់ ហើយបានពង្រឹងគាត់ក្នុងបេសកកម្ម ។ ហើយគាត់បានធ្វើកិច្ចការនោះមួយរយៈ ។

ប៉ុន្តែ គាត់បានឃើញមិត្តភក្តិជាច្រើនដែលជាអ្នកត្រឡប់ពីបេសកកម្ម មកព្រះវិហាររៀងរាល់ថ្ងៃអាទិត្យ ប៉ុន្តែនៅក្រៅព្រះវិហារ ពួកគេរស់នៅតាមរបៀបលោកិយ ។ ពួកគេហាក់ដូចជារីករាយ ។ ពួកគេធ្វើរឿង « សប្បាយ » ។ ហើយបែបផែននៃជីវិតរបស់ពួកគេហាក់ដូចជាពុំតម្រូវឲ្យខិតខំច្រើនដូចជីវិតរបស់គាត់ឡើយ ។

គាត់បានឈប់ធ្វើកិច្ចការតូចៗទាំងនោះបន្តិចម្តងៗ ដែលជាកិច្ចការនាំកម្លាំងខាងវិញ្ញាណដល់គាត់នៅពេលបម្រើបេសកកម្ម ។ គាត់នៅតែមានទីបន្ទាល់ ប៉ុន្តែគាត់បានប្រាប់ខ្ញុំថា គាត់បានគិតថា « ប្រសិនបើខ្ញុំនៅតែចូលរួមការប្រជុំព្រះវិហារ នោះខ្ញុំមិនអីទេ—ខ្ញុំមានសុវត្ថិភាពហើយ » ។ ប៉ុន្តែគាត់បាននិយាយថា « ខ្ញុំបានអសកម្មខាងវិញ្ញាណហើយ » ។[២] ពេលគាត់បានរស់នៅដូចមនុស្សលោកិយរស់នៅ គាត់បានជ្រើសធ្វើជម្រើសមិនល្អមួយ ហើយនាំទៅធ្វើជម្រើសមិនល្អបន្តទៀត ហើយមិនយូរប៉ុន្មានក្រោយមកគាត់បានមានទម្ងន់ ។

ទីបំផុត ជម្រើសមិនសុចរិតរបស់គាត់បានផ្តល់លទ្ធផលដល់គាត់ ។ គាត់ពុំសប្បាយរីករាយឡើយ ហើយគាត់បានដឹងរឿងនោះ ។ សំណាងល្អ មិត្តភក្តិរបស់ខ្ញុំបានទទួលស្គាល់ថា គាត់បានចាញ់ការបោកបញ្ឆោត ហើយគាត់បានប្រែចិត្ត ។

រឿងរបស់គាត់គួរសបញ្ជាក់ថា សូម្បីតែយើងដែលជាមនុស្សល្អបំផុតក៏អាចចាញ់ការបោកបញ្ឆោតដែរ ។ លើសពីនោះទៀត រឿងរបស់គាត់ចង្អុលបង្ហាញថា យើងត្រូវតែការពារខ្លួនជានិច្ចទាស់នឹងការបោកបញ្ឆោត ។ យើងសម្រេចកិច្ចការនេះ តាមរយៈការធ្វើកិច្ចការតូចៗដែលយាងព្រះវិញ្ញាណមកក្នុងជីវិតយើង ។

ខ្ញុំរីករាយដើម្បីប្រាប់ថា សព្វថ្ងៃនេះមិត្តភក្តិរបស់ខ្ញុំមានភាពរីករាយ គាត់កំពុងព្យាយាមគោរពបទបញ្ញត្តិ ហើយសកម្មក្នុងដំណឹងល្អទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ។

ការបោកបញ្ឆោតរបស់សាតាំងកើតឡើងតាមរបៀបជាច្រើន ។ ខ្ញុំនឹងលើកឡើងតែពីរបីប៉ុណ្ណោះ ។

*សាតាំងផ្តល់ជម្រើសក្លែងក្លាយផ្សេងៗ ស្រដៀងទៅនឹងអ្វីៗទាំងអស់ដែលព្រះបានធ្វើ ក្នុងគោលបំណងដើម្បីបំភាន់ និងបោកបញ្ឆោតយើង ។ ព្រះអង្គសង្គ្រោះបង្រៀនយើងថា « ដើមដែលអាក្រក់ [ ពុំ ] អាចនឹងបញ្ចេញផលល្អបាន »*

( នីហ្វៃទី ៣ ១៤:១៨) ។

សាតាំងព្យាយាមបញ្ចុះបញ្ចូលយើងឲ្យដាក់អាទិភាពខាងសាច់ឈាមជាងរឿងខាងវិញ្ញាណ ។ យើងអាចប្រាប់ថា តើអាទិភាពរបស់យើងងាកចេញពីកន្លែង តាមរយៈការសម្គាល់ពីភាពញឹកញាប់ដែលយើងនិយាយថា « ខ្ញុំមមាញឹកពេក ឬខ្ញុំនឿយហត់ពេលក្នុងពេលបច្ចុប្បន្ន ដើម្បី ________ » ។ សូមបំពេញក្នុងចន្លោះ ៖ ចូលរួមព្រះវិហារបរិសុទ្ធ ផ្តល់ការងារបម្រើ សិក្សា និងពិចារណាព្រះគម្ពីរ បំពេញការហៅបម្រើរបស់ខ្ញុំ ឬសូម្បីតែអធិស្ឋាន ។

ហេតុផលមួយដែលយើងមានភាពមមាញឹកនោះ គឺថា សាតាំងបានខិតខំបង្វែរអារម្មណ៍យើង ។ វាប្រើទូរសព្ទស្មាតហ្វូតដែលមានក្នុងដៃយើង វិទ្យុក្នុងរថយន្តយើង ទូរទស្សន៍នៅផ្ទះយើង និងកិច្ចការជាច្រើនផ្សេងទៀត ដើម្បីបន្តបង្វែរអារម្មណ៍យើងស្ទើរតែគ្រប់ពេលទាំងអស់ ។ ជាលទ្ធផល យើងមានអារម្មណ៍ថា យើងរវល់ជាងទាំងយើងមិនរវល់ផងនោះ ។

លទ្ធផលផ្សេងទៀតនៃការបង្វែរអារម្មណ៍នេះគឺថា យើងពិចារណាកាន់តែតិចទៅៗ ។ សាតាំងធ្វើការបង្វែរអារម្មណ៍យើង ដោយសារវាដឹងថា ការពិចារណា ជាពិសេសព្រះគម្ពីរនឹងនាំទៅរកការប្រែចិត្តជឿ និងវិវរណៈកាន់តែប្រសើរឡើង ។

ការបោកបញ្ឆោតមួយផ្សេងទៀតរបស់សាតាំងកើតឡើងតាមរយៈគំនិតថា សកម្មភាពខាងក្រៅរបស់យើងសំខាន់ជាងការជំរុញពីក្នុងចិត្តយើង ។ ពេលយើងខ្វះការជំរុញចិត្តត្រឹមត្រូវដើម្បីធ្វើកិច្ចការខាងវិញ្ញាណ នោះយើងបរាជ័យក្នុងការទទួលបទពិសោធន៍អំណាចនៃដំណឹងល្អ ។ ជាលទ្ធផល ការរក្សាបទបញ្ញត្តិចាប់ផ្តើមធ្វើឲ្យមានអារម្មណ៍ថា ដូចជាបន្ទុក ហើយសាតាំងដឹងថា ប្រសិនបើវាអាចនាំយើងឲ្យមានអារម្មណ៍បែបនេះ នោះយើងទំនងជាឈប់ធ្វើអ្វីដែលយើងដឹងថា យើងគប្បីធ្វើវា ។

សាតាំងក៏បោកបញ្ឆោតយើងឲ្យជឿថា អំណរ និងសុភមង្គលកើតឡើងពីជីវិតងាយស្រួល ឬការមានភាពសប្បាយរីករាយសាមញ្ញគ្រប់ពេលវេលា ។ វាពុំមែនជាការពិតទេ ។ សេចក្តីពិតគឺថា គ្មានអំណរ ឬសុភមង្គលណាដែលមិនតម្រូវឲ្យមានការខិតខំនោះទេ ( សូមមើល នីហ្វៃទី ២ ២:១១, ២៣ ) ។

ការបោកបញ្ឆោតចុងក្រោយរបស់សាតាំង ដែលខ្ញុំលើកឡើងនេះគឺថា វាព្យាយាមបញ្ចុះបញ្ចូលយើងថា សេចក្តីទុច្ចរិត ជាមួយនឹងភាពរីករាយបណ្តោះអាសន្នរបស់វា ជាសុភមង្គលពិតប្រាកដ ។ សាតាំងដឹងថា យ៉ាងហោចណាស់នៅគ្រានោះ អារម្មណ៍ ឬសតិពិតប្រាកដអាច (១) ធ្វើឲ្យយើងគិតថា យើងកំពុងមាន



អារម្មណ៍ផលផ្លែនៃព្រះវិញ្ញាណ (២) បិទបាំងបំណងប្រាថ្នាយើងពីផលផ្លែទាំងនោះ ឬ (៣) មានអារម្មណ៍ថា អារម្មណ៍ជំនួសនោះអាចទទួលយកបាន ។

ឧទាហរណ៍ សាតាំងអាចល្បួងយើងឲ្យស្វែងរកសម្រេកសម្រើបជំនួសឲ្យសេចក្ដីស្រឡាញ់ ។ វាអាចទាក់ចិត្តយើងជាមួយនឹងក្ដីរំភើបរីករាយជំនួសឲ្យអំណរដ៏យូរអង្វែង ។ វាព្យាយាមបង្វែរអារម្មណ៍យើងជាជាងផ្ដល់ភាពសុខសាន្តដល់យើង ។ វាចង់ឲ្យយើងមានចិត្តថា យើងសុចរិត ជឿស៊ុប និងធ្វើអ្វីៗដែលមនុស្សលោកមានអារម្មណ៍ត្រឹមត្រូវបំផុត ជំនួសឲ្យការមិនគិតពីខ្លួនឯង គោរពប្រតិបត្តិជាប់លាប់ និងផ្ដោតទៅលើរឿងខាងវិញ្ញាណត្រឹមត្រូវ ។ ការល្បួងរបស់វាអាចបណ្ដាលឲ្យយើងមានការភាន់ច្រឡំ ដែលក្រោយមកអាចនាំយើងឲ្យគិតថា ការមិនគោរពបទបញ្ញត្តិនឹងនាំមកនូវសុភមង្គល ។

### ៣. ធ្វើកិច្ចការតូចតាច

ជានិច្ចកាល កិច្ចការតូចតាចនាំឲ្យមានព្រះវិញ្ញាណចូលមកក្នុងជីវិតយើង រារាំងយើងមិនឲ្យចាញ់ការបោកបញ្ឆោត ហើយទីបំផុតជួយយើងឲ្យទទួលកម្លាំង ដើម្បីគោរពបទបញ្ញត្តិ និងទទួលបានជីវិតអស់កល្បជានិច្ច ។ ព្រះអង្គសង្គ្រោះបានបង្រៀនគោលការណ៍នេះដល់ពួកអែលឌើរនៃសាសនាចក្រនៅទីក្រុងខឺតឡង់ រដ្ឋហៃអូថា ៖ « ហេតុដូច្នោះហើយ ចូរកុំណាយចិត្តនឹងធ្វើការល្អឡើយ ដ្បិតអ្នករាល់គ្នាកំពុងតែដាក់គ្រឹះនៃកិច្ចការដ៏ធំ ។ ហើយចេញពីការណ៍ដ៏តូចតាច នោះបណ្ដាលឲ្យមានការណ៍ដ៏ធំធេងឡើង » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣៣ ) ។

ហេតុអ្វីកិច្ចការតូចតាចសំខាន់ម្ល៉េះ ? នៅក្នុងខគម្ពីរបន្ទាប់ ព្រះអង្គសង្គ្រោះបានពន្យល់ថា « ព្រះអម្ចាស់ទ្រង់តម្រូវចិត្ត និងគំនិតដែលស្ម័គ្រតាម » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៣៤ ) ។ ហេតុអ្វីព្រះអង្គសង្គ្រោះភ្ជាប់ការធ្វើកិច្ចការតូចតាចទៅនឹងចិត្ត និងគំនិតដែលស្ម័គ្រតាម ? ដោយសារនៅក្នុងការធ្វើកិច្ចការតូចតាចបានជាប់លាប់ នោះយើងបណ្ដោយចិត្ត និងគំនិតយើងទៅតាមព្រះ ដែលបន្សុទ្ធ និងញែកយើងចេញជាបរិសុទ្ធ ( សូមមើល ហេលេមិន ៣:៣៥ ) ។

ការបន្សុទ្ធ និងការញែកចេញជាបរិសុទ្ធនេះផ្លាស់ប្ដូរលក្ខណៈរបស់យើង បន្ដិចម្ដងៗ ដើម្បីឲ្យយើងប្រែកាន់តែដូចព្រះអង្គសង្គ្រោះ ។ ការណ៍នេះក៏បណ្ដាលឲ្យយើងកាន់តែទទួលនូវការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើឲ្យយើងទំនងជាមិនសូវចាញ់ការបោកបញ្ឆោត ។

កាលខ្ញុំនៅរៀនវិទ្យាល័យ ឪពុករបស់ខ្ញុំបានបង្រៀនថ្នាក់សិក្ខាសាលាដល់ខ្ញុំនៅក្នុងផ្ទះរបស់យើង ។ ដោយសារប្រធានបទនៅឆ្នាំនោះគឺជាព្រះគម្ពីរមរមន នោះឪពុកខ្ញុំបានសម្រេចចិត្តថា យើងនឹងអានព្រះគម្ពីរមរមនជាមួយគ្នា ពីមួយខទៅមួយខ ហើយពិភាក្សាអំពីអ្វីដែលយើងបានរៀន ។ ពេលយើងអាន ឪពុកខ្ញុំបានសួរសំណួរដែលធ្វើឲ្យខ្ញុំគិតអំពីអ្វីដែលយើងបានអាន ហើយគាត់បានពន្យល់អ្វីដែលខ្ញុំមិនយល់ ។ ខ្ញុំនៅតែចាំពីការរៀនអំពីព្រះអង្គសង្គ្រោះ និងយល់ដឹងថា ទ្រង់ពិតជាបានយាងទៅជួបពួកសាសន៍នីហ្វៃ ហើយថា ខ្ញុំពិតជាអាចទទួលការអភ័យទោសពីអំពើបាបរបស់ខ្ញុំ តាមរយៈដង្វាយធួនរបស់ទ្រង់ ។

ការអានព្រះគម្ពីរនៅអំឡុងពេលនោះជាមួយឪពុកខ្ញុំគឺជាការចាប់ផ្ដើមនៃគ្រឹះរបស់ខ្ញុំក្នុងព្រះគម្ពីរ ។ ខ្ញុំបានទទួលអារម្មណ៍អ្វីមួយពេលយើងបានអានព្រះគម្ពីរ ។ ហើយកាន់តែសំខាន់នោះគឺថា បំណងប្រាថ្នា ការជំរុញចិត្ត និងទង្វើរបស់ខ្ញុំបានផ្លាស់ប្ដូរ ។ ខ្ញុំចង់ក្លាយជាមនុស្សប្រសើរឡើង ។ ខ្ញុំបានចាប់ផ្ដើមមើលឃើញពីចំណុចដែលខ្ញុំកំពុងចាញ់ការបោកបញ្ឆោត ។ ខ្ញុំបានប្រែចិត្តកាន់តែច្រើន ។ នៅចុងបញ្ចប់នៃឆ្នាំទីមួយរបស់ខ្ញុំនៅមហាវិទ្យាល័យ ខ្ញុំបានអានព្រះគម្ពីររៀងរាល់ថ្ងៃ ។

នៅអំឡុងឆ្នាំនោះ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( ១៨៩៩–១៩៩៤ ) បានសុំឲ្យសមាជិកសាសនាចក្រអានព្រះគម្ពីរមរមនប្រចាំថ្ងៃ ហើយអនុវត្តអ្វីដែលពួកគេបានរៀន ។[៣] ដូច្នេះបន្ថែមទៅលើអ្វីផ្សេងទៀតដែលខ្ញុំកំពុងអាន នោះខ្ញុំអានយ៉ាងហោចណាស់នូវអ្វីមួយពីព្រះគម្ពីរមរមន ។

នៅពេលបម្រើបេសកកម្ម ខ្ញុំបានរៀនអំពីរបៀបសិក្សា និងទទួលទានព្រះគម្ពីរយ៉ាងពិតប្រាកដ ។ ខ្ញុំពុំគ្រាន់តែទទួលបានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធពេលខ្ញុំអានព្រះគម្ពីរប៉ុណ្ណោះទេ ខ្ញុំថែមទាំងចាប់ផ្ដើម



ទទួលអារម្មណ៍នៃអំណរ ពេលខ្ញុំស្រាវជ្រាវព្រះគម្ពីរ ដើម្បីស្វែងរកចម្លើយចំពោះបញ្ហារបស់ខ្ញុំ និងសាសនាគន់ការីរបស់ខ្ញុំ ។

បន្ទាប់ពីបេសកកម្ម ខ្ញុំបានបន្តទទួលទានព្រះគម្ពីររៀងរាល់ថ្ងៃ ។ ដោយសារការអនុវត្តនេះបានអញ្ជើញព្រះវិញ្ញាណបរិសុទ្ធមកក្នុងជីវិតខ្ញុំ នោះខ្ញុំបានទទួលការណែនាំពីទ្រង់ ឲ្យជួយខ្ញុំប្រើពេលវេលារបស់ខ្ញុំកាន់តែមានប្រសិទ្ធភាព ។ ជាលទ្ធផល ខ្ញុំធ្វើបានកាន់តែល្អនៅសាលារៀន ហើយក្រោយមកនៅឯកន្លែងធ្វើការផងដែរ ។ វាប្រែកាន់តែងាយស្រួលដើម្បីធ្វើជម្រើសល្អ ។ ខ្ញុំបានអធិស្ឋានកាន់តែច្រើន ហើយមានចិត្តកាន់តែឧស្សាហ៍ព្យាយាមក្នុងការបំពេញការហៅបម្រើរបស់ខ្ញុំ ។ ការទទួលទានព្រះគម្ពីរប្រចាំថ្ងៃពុំបានដោះស្រាយគ្រប់បញ្ហារបស់ខ្ញុំទេ ប៉ុន្តែជីវិតរបស់ខ្ញុំមានភាពកាន់តែងាយស្រួល ។

នៅខែ សីហា ឆ្នាំ ២០០៥ ប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី ( ១៩១០–២០០៨ ) បានចេញការអញ្ជើញមួយឲ្យអាន ឬអានព្រះគម្ពីរមរមនម្តងទៀត ពីមុនដាច់ឆ្នាំនោះ ។[៤] ដោយសារខ្ញុំបានអានព្រះគម្ពីរមរមនប្រចាំថ្ងៃ នោះខ្ញុំបានអានដល់គម្ពីរអេធើរ ឬមរ៉ូណៃទៅហើយ ។ ហេតុដូច្នេះហើយ ពេលចប់ការអាននោះនៅមួយ ឬពីរសប្តាហ៍ក្រោយមក ខ្ញុំបានរាប់ថា ខ្ញុំបានបំពេញការអញ្ជើញរបស់ប្រធានហ៊ិងគ្លី ។

ប៉ុន្តែក្រោយមក គ្រូបង្រៀនតាមផ្ទះដ៏ស្មោះត្រង់បានមកសួរសុខទុក្ខគ្រួសារយើង ។ គាត់បានសួរថា តើខ្ញុំបានធ្វើអ្វីហើយជាមួយនឹងការអញ្ជើញរបស់ប្រធានហ៊ិងគ្លី ។

ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមានសំណាងល្អក្នុងការចាប់ផ្តើមព្រះគម្ពីរមរមន ពីមុនការអញ្ជើញរបស់ប្រធានហ៊ិងគ្លី ។ កាលនោះដោយសារតែភាពសុចរិតផ្ទាល់ខ្លួន ខ្ញុំបានប្រកាសថា ខ្ញុំបានបំពេញកិច្ចការនោះហើយ ។

សំណាងល្អ គ្រូបង្រៀនតាមផ្ទះរបស់ខ្ញុំបានយល់ឃើញខុសពីនោះ ។ ពេលគាត់បានកែតម្រូវខ្ញុំដោយរាបសា នោះព្រះវិញ្ញាណបានខ្សឹបប្រាប់ខ្ញុំថា គ្រូបង្រៀនតាមផ្ទះរបស់ខ្ញុំត្រូវហើយ ។

ឥឡូវខ្ញុំត្រូវអានគម្ពីរមួយថ្ងៃពីរជំពូករហូតដល់ចុងឆ្នាំ ដើម្បីបញ្ចប់ការអានរបស់ខ្ញុំម្តងទៀត ។ ពេលខ្ញុំបានបង្កើនការអានព្រះគម្ពីរមរមន នោះខ្ញុំបានកត់សម្គាល់ឃើញថា ជីវិតខ្ញុំកាន់តែទទួលបានអំណាច ។ ខ្ញុំមានអំណរកាន់តែច្រើន ។ ខ្ញុំបានយល់ពីរឿងនានាកាន់តែច្បាស់ឡើង ។ ខ្ញុំបានប្រែចិត្តកាន់តែញឹកញាប់ឡើង ។ ខ្ញុំចង់ផ្តល់ការងារបម្រើ និងសង្គ្រោះមនុស្សដទៃ ។ ខ្ញុំពុំសូវងាយនឹងធ្លាក់ចូលទៅក្នុងការបោកបញ្ឆោត និងការល្បួងរបស់សាតាំង ។ ខ្ញុំស្រឡាញ់ព្រះអង្គសង្គ្រោះកាន់តែខ្លាំងឡើយ ។

នៅខែវិច្ឆិកាឆ្នាំនោះ ខ្ញុំត្រូវបានហៅឲ្យធ្វើជាប៊ីស្សពនៃវួដនោះ ។ ដោយបញ្ចប់ការអញ្ជើញរបស់ប្រធានហ៊ិងគ្លី បានរៀបចំខ្ញុំសម្រាប់ការហៅបម្រើនោះ ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានកត់សម្គាល់ថា ដរាបណាខ្ញុំកាន់តែមមាញឹកទោះនៅកន្លែងការងារ ឬនៅព្រះវិហារក្តី ដរាបនោះខ្ញុំត្រូវតែសិក្សាព្រះគម្ពីរកាន់តែច្រើនជាពិសេសព្រះគម្ពីរមរមន ។

*ខ្ញុំសូមសន្យាថា ប្រសិនបើអ្នកនឹងទទួលទានព្រះគម្ពីររៀងរាល់ថ្ងៃ ជាពិសេសព្រះគម្ពីរមរមន នោះអ្នកនឹងអញ្ជើញព្រះវិញ្ញាណមកក្នុងជីវិតអ្នក ។*

អ្នកអាចមានពរជ័យ និងអំណាចដូចគ្នានេះនៅក្នុងជីវិតអ្នក ប្រសិនបើអ្នកនឹងទទួលទានព្រះគម្ពីររៀងរាល់ថ្ងៃ ។ ខ្ញុំសូមសន្យាថា ប្រសិនបើអ្នកនឹងទទួលទានព្រះគម្ពីររៀងរាល់ថ្ងៃ ជាពិសេសព្រះគម្ពីរមរមន នោះអ្នកនឹងអញ្ជើញព្រះវិញ្ញាណមកក្នុងជីវិតអ្នក ហើយអ្នកនឹងអធិស្ឋានជាប្រចាំដោយឯកឯង ប្រែចិត្តកាន់តែញឹកញាប់ ហើយឃើញថា វាមានភាពងាយស្រួលដើម្បីចូលរួមព្រះវិហារ និងទទួលទានសាក្រាម៉ង់ប្រចាំសប្តាហ៍ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ពេលអ្នកធ្វើកិច្ចការតូចតាច ហើយទុកចិត្តលើព្រះអម្ចាស់ នោះអ្នកអាចរកឃើញសេចក្តីស្រឡាញ់ អំណរ ភាពសុខសាន្ត និងសុភមង្គល មិនថាកាលៈទេសៈរបស់អ្នកបែបណានោះទេ ។ ខ្ញុំក៏សូមថ្លែងទីបន្ទាល់ថា ការណ៍នេះអាចធ្វើទៅបានដោយសារការពលិកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ។ គ្រប់កិច្ចការល្អទាំងអស់កើតឡើងមកពីទ្រង់ ( សូមមើល មរ៉ូណៃ ៧:២២, ២៤ ) ។ ■

*ដកស្រង់ចេញមកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន « Happiness, Deceit, and Small Things » ដែលបានថ្លែងនៅសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៧ ។*

កំណត់ចំណាំ

១. ពេលយើងមានសេចក្តីជំនឿរឹងមាំលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលទាននូវសេចក្តីស្រឡាញ់របស់ព្រះ ទោះបីយើងមានកាលៈទេសៈបែបណាក្តី ។
២. កំណត់ចំណាំសម្ភាស និងប្រតិបត្តិគ្រពិន្ទុរបស់អ្នកនិពន្ធ ។
៣. សូមមើល អ៊ែសរ៉ា ថាហ្វ បែនសឹន « A Sacred Responsibility » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៧៧–៧៨ សូមមើលផងដែរ « The Book of Mormon—Keystone of Our Religion » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៤–៧ ។
៤. សូមមើល ហ្គដុន ប៊ី ហ៊ីងឃ្លី « First Presidency Message: A Testimony Vibrant and True » *Ensign* ខែ សីហា ឆ្នាំ ២០០៥ ទំព័រ ២–៦ ។

# ទោះបីជាព្យុះសង្ឃរាក៏ពុំអាចបញ្ឈប់យើងបានដែរ

មិនយូរប៉ុន្មានបន្ទាប់ពីខ្ញុំត្រឡប់មកពីបេសកកម្មវិញ ខ្ញុំបានទទួលការអញ្ជើញទៅក្នុងពិធីរាំកម្សាន្តមួយ ។ នៅក្នុងពិធីរាំកម្សាន្តនោះ ខ្ញុំវង្វេងដៃបាត់ទូរសព្ទ ហើយយុវជនម្នាក់បានស្ម័គ្រចិត្តជួយរកទូរសព្ទរបស់ខ្ញុំ ។ ពេលយើងដើររក យើងបានឃើញថា យើងទាំងពីរនាក់គឺជាអ្នកត្រឡប់មកពីបេសកកម្មដូចគ្នា ហើយបានចែកចាយគំនិត និងគោលដៅជាច្រើន ។

ទំនាក់ទំនងរបស់យើងបានអភិវឌ្ឍឡើង ហើយយើងបានឈានដល់ការភ្ជាប់ពាក្យ ។ វាជាក្ដីសុបិនរបស់យើងដើម្បីផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ វ៉ាស៊ីនតោន ឌី.ស៊ី ពីមុនវាត្រូវបានបិទសម្រាប់ការជួសជុលនៅខែមីនា ឆ្នាំ ២០១៨ ។ ប៉ុន្តែបន្ទាប់ពីការសម្រេចចិត្តនោះមក យើងត្រូវបានសាកល្បង ។ ដំបូង ខ្ញុំបានបាត់បង់ការងារ ហើយគ្មានមធ្យោបាយណាដើម្បីសន្សំប្រាក់សម្រាប់ការធ្វើដំណើរទៅព្រះវិហារបរិសុទ្ធឡើយ ។ បន្ទាប់មកទៀត មានព្យុះសង្ឃរាមួយបានបោកបក់ទៅលើប្រទេស ពើរតូ រីកូ ពីមុនកាលបរិច្ឆេទមង្គលការរបស់យើង ។

ពេលព្យុះសង្ឃរាម៉ារៀបានកើតឡើង វាបានបំផ្លិចបំផ្លាញកោះដ៏ស្រស់ស្អាតរបស់យើង ។ ហាងលក់ទំនិញបានបិទទ្វារ ។ យើងអត់មានភ្លើងអគ្គិសនី ទឹក អាហារឡើយ ហើយយើងពិបាករកវត្ថុប្រើប្រាស់ចាំបាច់ផ្សេងៗទៀត ។ យើងបានបាត់បង់អ្វីគ្រប់យ៉ាងដែលយើងគ្រោងទុកប្រើសម្រាប់ពិធីទទួលភ្ញៀវក្នុងពិធីមង្គលការរបស់យើង ។ យើងត្រូវតែលុបចោលពិធីទទួលភ្ញៀវនោះ ហើយវាទំនងថា យើងក៏នឹងលុបចោលពិធីមង្គលការរបស់យើងផងដែរ ។ ការធ្វើដំណើរចេញចូលប្រទេស ពើរតូ រីកូ គឺមានកំណត់ ហើយគ្មាននរណាម្នាក់ដឹងថា វាមានកំណត់យូរប៉ុណ្ណានោះទេ ។ ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍បាក់ទឹកចិត្ត ហើយខ្ញុំពោរពេញដោយមន្ទិលសង្ស័យ និងការភាន់ច្រឡំ ។

នៅយប់មួយ គូដណ្ដឹងរបស់ខ្ញុំ និងខ្ញុំបានពិភាក្សាគ្នាអំពីស្ថានភាពរបស់ពួកយើង ។ ការធ្វើដំណើរពុំដឹងពិតប្រាកដ ហើយយើងគ្មានសម្លៀកបំពាក់សម្រាប់ពិធីទទួលភ្ញៀវ ឬពិធីមង្គលការយើងឡើយ ប៉ុន្តែព្រះវិញ្ញាណបានបញ្ជាក់ថា យើងត្រូវតែទុកចិត្តលើព្រះអម្ចាស់ ។ រឿងសំខាន់បំផុតនោះគឺការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ យើងបានអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ទូលសូមជំនួយ ។

ពេលយន្តហោះចេញពីប្រទេស ពើរតូ រីកូ បានដំណើរការវិញ នោះយើងបានធ្វើគម្រោងហោះហើរថ្មី ហើយដាក់កាលវិភាគផ្សារភ្ជាប់របស់យើងឡើងវិញ ។ យើងគ្មានប្រព័ន្ធទាក់ទងអស់រយៈពេលជាច្រើនសប្ដាហ៍បន្ទាប់ពីព្យុះសង្ឃរានោះ ប៉ុន្តែទូរសព្ទដៃរបស់មិត្តភក្ដិខ្ញុំមានដំណើរការ ។ គាត់បានអនុញ្ញាតឲ្យយើងប្រើទូរសព្ទរបស់គាត់ដើម្បីទាក់ទងទៅព្រះវិហារបរិសុទ្ធ ។ យើងបានរៀបចំអ្វីៗគ្រប់យ៉ាងជាថ្មី ដើម្បីយើងអាចផ្សារភ្ជាប់បាន ! ពីរបីសប្ដាហ៍ពីមុនការធ្វើដំណើររបស់យើង សមាជិកគ្រួសារ និងមិត្តភក្ដិ បានបរិច្ចាគស្បែកជើង និងសម្លៀកបំពាក់ ព្រមទាំងជួយទិញវត្ថុជាច្រើនទៀតសម្រាប់ពិធីមង្គលការរបស់យើង ។

ទីបំផុតពេលយើងបានចូលទៅក្នុងព្រះវិហារបរិសុទ្ធនោះយើងបានទុកនូវក្ដីកង្វល់ទាំងអស់មួយអន្លើរសិន ។ យើងបានកាន់ដៃគ្នាចូលទៅក្នុងអនាគតកាលរបស់យើង ។ ខ្ញុំអាចនិយាយយ៉ាងពិតប្រាកដថា ខ្ញុំបានទទួលព្រះហស្តដឹកនាំរបស់ព្រះអម្ចាស់ និងការធានាអះអាងដល់យើងថា ដរាបណាយើងទុកចិត្តលើទ្រង់ នោះអ្វីៗគ្រប់យ៉ាងនឹងដំណើរការល្អ ។ សព្វថ្ងៃនេះ យើងមានពរដែលមានកូនប្រុសដ៏ស្រស់ស្អាតម្នាក់ ហើយយើងគឺជាគ្រួសារមួយដែលបានផ្សារភ្ជាប់សម្រាប់ភាពអស់កល្បជានិច្ច ។ ■

**កូរៀម៉ា សាន់ទីអាហ្គោ ឌី ជេសឺ ទីក្រុង សាន់ ហ៊ាន ប្រទេស ពើតតូ រីកូ**



*បន្ទាប់ពីព្យុះសង្ឃរាម៉ារៀមក វាទំនងថា យើងនឹងលុបចោលពិធីមង្គលការរបស់យើង ។*

រចនារូបភាពដោយ ស៊ិសានណេ សឹមម៉ុន





រចនារូបភាពដោយ ជេ ខាលីក

# « នេះហើយគឺជាជីវិត ! »

បន្ទាប់ពីការសម្ភាសជាច្រើនក្នុងនាមជាប៊ីស្សព ខ្ញុំបានមកដល់ផ្ទះពេលយប់ជ្រៅនារដូវរងារមួយ ។ ខ្ញុំអស់កម្លាំងខ្លាំងណាស់ ។ សម្ពាធការងាររយៈពេលជាច្រើនសប្ដាហ៍ និងការទទួលខុសត្រូវក្នុងគ្រួសារ និងសាសនាចក្រ បានធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ខ្ញុំពុំអាចធ្វើរឿងគ្រប់យ៉ាងដែលខ្ញុំត្រូវបានសុំឲ្យធ្វើទេ ។

នាល្ងាចនោះ ខ្ញុំត្រូវតែជួសជុលឡានរបស់ខ្ញុំ ដើម្បីខ្ញុំអាចទៅធ្វើការបាននៅព្រឹកបន្ទាប់ ។ ពេលខ្ញុំពាក់អាវក្រៅរបស់ខ្ញុំ នោះខ្ញុំបានប្ដូរតួនាទីខ្ញុំពីប៊ីស្សពទៅជាជាងមេកានិចវិញ ។ ខ្ញុំបានតម្រេកខ្លួនលើកម្រាលហ្គារ៉ាសឡានដ៏ត្រជាក់ក្រោមឡាន ដើម្បីជួសជុល ។ ហេតុអ្វីខ្ញុំត្រូវរងារ អស់កម្លាំង ហើយឈឺក្រញូវដៃ បន្ទាប់ពីខ្ញុំបានធ្វើការយ៉ាងខ្លាំងនៅថ្ងៃនោះទៀតដូច្នេះ ? ខ្ញុំបានបាត់បង់ការអត់ធ្មត់ ហើយចាប់ផ្ដើមយំ ដោយទូលការអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌ ។

« តើវាអាចទៅរួចទេ ប្រសិនបើទ្រង់អាចជួយខ្ញុំតែបន្តិចនោះ ? » ខ្ញុំបាននិយាយថា « ខ្ញុំកំពុងព្យាយាមអស់ពីសមត្ថភាពរបស់ខ្ញុំដើម្បីធ្វើជាឪពុក ស្វាមី និងប៊ីស្សពល្អម្នាក់ ហើយរស់នៅតាមបទបញ្ញត្តិ ។ តើខ្ញុំនឹងមិនបម្រើបានប្រសើរជាងនេះទេឬ ប្រសិនបើខ្ញុំសម្រាកខ្លះនោះ ? សូមជួយទូលបង្គំធ្វើការឲ្យរួច ដើម្បីទូលបង្គំអាចចូលដេក » ។

រំពេចនោះ ពាក្យដ៏ច្បាស់លាស់បានផុសឡើងក្នុងគំនិតខ្ញុំ ៖ « នេះហើយគឺជាជីវិត ! »

ខ្ញុំបានតបថា « ស្អីគេ ? »

ខ្ញុំបានឮពាក្យនោះម្ដងទៀត ៖ « នេះហើយគឺជាជីវិត ! »

ការយល់ដឹងបានចាប់ផ្ដើមមានក្នុងគំនិត និងចិត្តខ្ញុំ ពេលខ្ញុំបានស្ដាប់ឮពាក្យនោះជាលើកទីបី ៖ « នេះហើយគឺជាជីវិត ! » ពាក្យទាំងនេះពាំនាំនូវសារលិខិតមួយមកក្នុងវិញ្ញាណខ្ញុំ ។ « នេះ » គឺជាជីវិតរមែងស្លាប់ ហើយខ្ញុំបានជួបនូវគ្រានៃការរីកចម្រើនដែលបានរៀបចំឡើងដើម្បីជួយខ្ញុំឲ្យក្លាយជាអ្វីដែលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យខ្ញុំប្រែក្លាយ ។ ព្រះវិញ្ញាណទំនងជាមានបន្ទូលមកខ្ញុំថា « តើអ្នករំពឹងថា ដំណើរលើផែនដីនេះគ្មានឧបសគ្គឬ ? » ពេលខ្ញុំក្រោកចេញពីកម្រាលស៊ីម៉ងត៍ដ៏ត្រជាក់នោះ ខ្ញុំពុំមែនជាមនុស្សដូចមុនទៀតឡើយ ។

ដោយផ្អែកទៅលើរបៀបដែលយើងឆ្លើយតបទៅនឹងការសាកល្បងនានា នោះយើងអាចចាត់ទុកការសាកល្បងថាជា អំណោយមកពីព្រះវរបិតាជាទីស្រឡាញ់របស់យើងដែលគង់នៅឋានសួគ៌ ។ ទ្រង់ប្រទានឱកាសឲ្យយើងប្រឈមមុខនឹងការសាកល្បងនានា ដើម្បីយើងអាចរៀនបែរទៅរកទ្រង់ ។ នៅពេលយើងធ្វើដូច្នោះ យើងមានពរដោយការរៀនសូត្រ និងការរីកចម្រើនខាងវិញ្ញាណ ។

ពាក្យទាំងនោះដែលផុសឡើងក្នុងគំនិតខ្ញុំអំឡុងពេលយប់ដ៏រងារនៅលើកម្រាលស៊ីម៉ង់ត៍នៅហ្គារ៉ាសឡានរបស់ខ្ញុំ បានផ្ដល់ពរដល់ខ្ញុំអស់រយៈពេលជាង ៣៥ ឆ្នាំហើយ ។ ខ្ញុំបានព្យាយាមយ៉ាងខ្លាំងដើម្បីយល់ថា ខ្ញុំពុំបានខ្វះខ្វាយនឹងការសាកល្បងដែលខ្ញុំបានទទួលនោះទេ ។ ខ្ញុំឃើញថា ការសាកល្បងគឺជាឱកាសដើម្បីរៀនអ្វីដែលខ្ញុំពុំធ្លាប់រៀនតាមរបៀបមួយផ្សេងទៀត ។ ■

**រីឆាត ជេ អែនឌើរសុន រដ្ឋ យូថាហ៍ សហរដ្ឋអាមេរិក**

*ខ្ញុំកំពុងជួសជុលឡាន ពេលសារលិខិតដ៏ច្បាស់លាស់មួយបានផុសឡើងយ៉ាងខ្លាំងក្នុងគំនិតខ្ញុំ ។*

# ឃើញលោកប៉ាច្រៀង

ខ្ញុំបានទៅបេសកកម្មនៅ ហូណូលូលូ រដ្ឋ ហាវ៉ៃ ស.រ.អា. បានតែរយៈពេលបួនខែកន្លះប៉ុណ្ណោះ ពេលខ្ញុំមានការប្រកាច់ដ៏យូរមួយ ហើយក្រោយមកខ្ញុំត្រូវបានធ្វើរោគវិនិច្ឆ័យថា មានជំងឺឆ្កួតជ្រូក ។ ជាច្រើនខែបន្ទាប់មក ខ្ញុំបានទៅមន្ទីរពេទ្យ ធ្វើតេស្តជាច្រើន ហើយទទួលថ្នាំព្យាបាលថ្មីមួយដែលធ្វើឲ្យមានផលប៉ះពាល់ច្រើន ។

តាំងពីដំបូងរហូតមកដល់ពេលនោះ ខ្ញុំបានផ្ដោតចិត្តយ៉ាងខ្លាំងលើកិច្ចការអ្នកផ្សព្វផ្សាយសាសនា ដែលធ្វើឲ្យខ្ញុំពុំនឹកផ្ទះខ្លាំងទេ ប៉ុន្តែចាប់តាំងពីពេលដែលខ្ញុំមានការប្រកាច់នោះមក ដួងចិត្តខ្ញុំឈឺចាប់ ។ ខ្ញុំនឹកឪពុកម្ដាយខ្ញុំ ហើយខ្ញុំមានអារម្មណ៍ថាឯកោ ទោះបីខ្ញុំនៅក្នុងចំណោមមនុស្សដ៏អស្ចារ្យដែលមើលថែខ្ញុំក្ដី ។ ខ្ញុំមិនចង់ទៅផ្ទះ ប៉ុន្តែខ្ញុំចង់បានអារម្មណ៍នៃភាពសុខសាន្ត ។

ដោយមានការអនុញ្ញាតពីប្រធានបេសកកម្ម ខ្ញុំបាននិយាយជាមួយឪពុកម្ដាយខ្ញុំតាមទូរសព្ទអំពីថ្នាំរបស់ខ្ញុំ ។ ឪពុកខ្ញុំដែលទើបតែបំពេញក្ដីសុបិនដ៏យូររបស់គាត់ ចូលរួមក្រុមចម្រៀងរោងឧបោសថនៅវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធ បានបញ្ជាក់ដល់ខ្ញុំថាគាត់នឹងច្រៀងចម្រៀងឲ្យអស់ពីចិត្តសម្រាប់ខ្ញុំនៅក្នុងសន្និសីទទូទៅ ដែលបានចាប់ផ្ដើមនៅថ្ងៃបន្ទាប់នោះ ។

នៅព្រឹកបន្ទាប់ ខ្ញុំបានអធិស្ឋានដោយស្មោះទូលសូមភាពសុខសាន្តដែលខ្ញុំត្រូវការជាខ្លាំងនោះ ។ ខ្ញុំបានទទួលចម្លើយចំពោះសំណួរជាក់លាក់នានា អំឡុងពេលសន្និសីទទូទៅពីមុនៗ ហើយខ្ញុំបានទុកចិត្តថា ខ្ញុំអាចទទួលការណែនាំម្ដងទៀត ។ នៅពេលចាប់ផ្ដើមសន្និសីទ ក្រុមចម្រៀងបានច្រៀងបទ « កូនចៅនៃព្រះអើយទ្រង់គង់ក្បែរអ្នក » ( *ទំនុកតម្កើង* លេខ ៤៥ ) ។ អំឡុងពេលនាទីដំបូង ខ្ញុំបានឃើញប៉ារបស់ខ្ញុំនៅលើកញ្ចក់ទូរទស្សន៍ ។ អ្នកថតវីដេអូបានពង្រីកកាំម៉ារ៉ាកាន់តែជិតមុខរបស់គាត់មួយសន្ទុះធំ ។

ទឹកភ្នែកខ្ញុំបានហូរស្រក់ចុះមក ពេលខ្ញុំបានទទួលអារម្មណ៍នៃភាពសុខសាន្តពេញខ្លួនខ្ញុំ ។ ខ្ញុំបានដឹងថាព្រះស្រឡាញ់ខ្ញុំ ។ ទ្រង់បានដឹងយ៉ាងពិតប្រាកដអំពីតម្រូវការខ្ញុំនាថ្ងៃនោះ—គឺការបញ្ជាក់យ៉ាងសាមញ្ញថា ទ្រង់គង់នៅក្បែរ ហើយជ្រាបដឹងពីខ្ញុំ ។ ខ្ញុំបានទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះ និងសេចក្ដីស្រឡាញ់របស់គ្រួសារខ្ញុំ ដៃគូ និងប្រធានបេសកកម្មរបស់ខ្ញុំ ។ ជំនួសឲ្យអារម្មណ៍ការមានបន្ទុកឥឡូវនេះ ខ្ញុំបានឃើញពីឱកាសមួយដើម្បីខិតកាន់តែជិតព្រះអម្ចាស់ ។

ឧបសគ្គផ្នែកសុខភាពខ្ញុំពុំបាត់ទៅណាទេ ។ ទីបំផុត ខ្ញុំត្រូវចាកចេញពីបេសកកម្មរបស់ខ្ញុំមុនកំណត់ ប៉ុន្តែខ្ញុំបានដឹងថាព្រះគង់នៅទីនោះ ហើយទ្រង់ស្រឡាញ់ខ្ញុំ ។ ការបញ្ជាក់នោះបាននៅជាប់ជាមួយខ្ញុំ ពេញទាំងការសាកល្បងជាច្រើនទៀតរបស់ខ្ញុំ ហើយបានផ្ដល់សេចក្ដីសង្ឃឹមក្នុងគ្រាលំបាកនានារបស់ខ្ញុំ ។ មនុស្សដទៃអាចគិតថា វាគឺជារឿងចៃដន្យ ប៉ុន្តែខ្ញុំដឹងថា ការឃើញប៉ារបស់ខ្ញុំច្រៀងអំពីសេចក្ដីស្រឡាញ់នៃព្រះ គឺជាអព្ភូតហេតុតូចមួយក្នុងគ្រាអាសន្នរបស់ខ្ញុំ ។ ■

**ម៉ារៀ អូកា រដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា.**

គំនូរដោយ អេលែន ហ្គានស៍



*ខ្ញុំបានយំ ពេលខ្ញុំបានឃើញប៉ារបស់ខ្ញុំនៅលើកញ្ចក់ទូរទស្សន៍ ។*

# លិខិតអញ្ជើញមួយសម្រាប់រីកាដូ

ពេលខ្ញុំពូកែខាងកម្មភាពសាសនាចក្រ ខ្ញុំបានអញ្ជើញមនុស្ស ១០ នាក់ដែលមិនមែនជាសមាជិកសាសនចក្រទៅចូលរួមកម្មវិធីនោះ ។ ខ្ញុំបានធ្វើបែបនេះអស់ជាច្រើនឆ្នាំ ។ ខ្ញុំបានធ្វើលិខិតអញ្ជើញ ហើយដាក់វាក្នុងស្រោមសំបុត្រពណ៌សមួយ ហើយអធិស្ឋានសូមឲ្យព្រះវិញ្ញាណដឹកនាំខ្ញុំ ។ បន្ទាប់មក ខ្ញុំបានចែកលិខិតអញ្ជើញនោះ ។ កម្រណាស់ដែលមានមនុស្សទាំង ១០ នាក់នោះចូលរួម ប៉ុន្តែប្រសិនបើមានតែម្នាក់ចូលរួម នោះខ្ញុំមានអារម្មណ៍ថា ខ្ញុំមានជោគជ័យ ។

បួនប្រាំឆ្នាំកន្លងទៅនេះ ខ្ញុំបានរៀបចំលិខិតអញ្ជើញចំនួនដប់ សម្រាប់ការប្រជុំពិសេសមួយរបស់គូស្វាមីភរិយាដែលបានរៀបការរួច ។ ខ្ញុំបានជូនលិខិតអញ្ជើញនោះទៅមនុស្សប្រាំបួននាក់នៅកន្លែងធ្វើការ ហើយនៅសល់លិខិតមួយទៀត ។ ខ្ញុំពុំដឹងថា ខ្ញុំត្រូវជូនលិខិតអញ្ជើញនោះទៅនរណាទេ ។ ប៉ុន្មាននាទីក្រោយ រីកាដូអ្នកតំណាងផ្នែកលក់ បានដើរកើតតុធ្វើការរបស់ខ្ញុំ ។ ខ្ញុំទទួលការបំផុសគំនិតឲ្យអញ្ជើញគាត់ ទោះបីគាត់បានបដិសេធការអញ្ជើញមួយពីមិត្តរួមការងារម្នាក់ឲ្យចូលរួមសកម្មភាពនៅព្រះវិហារគាត់ក្តី ។ ខ្ញុំបានគិតថា រីកាដូនឹងពុំចាប់អារម្មណ៍ទេ ។

ប៉ុន្តែពេលរីកាដូបានដើរកាត់តុធ្វើការខ្ញុំម្តងទៀតដើម្បីចេញទៅវិញ នោះខ្ញុំទទួលការបំផុសគំនិតម្តងទៀត ។ ប៉ុន្តែគាត់បានចេញទៅយ៉ាងលឿន ដែលធ្វើឲ្យខ្ញុំគ្មានឱកាសនិយាយជាមួយគាត់ឡើយ ។ ខ្ញុំបានអធិស្ឋានថា រីកាដូនឹងត្រឡប់មកវិញ ប្រសិនបើខ្ញុំត្រូវជូនលិខិតអញ្ជើញនោះដល់គាត់ ។

បន្ទាប់ពីខ្ញុំបានបញ្ចប់ការអធិស្ឋានរួច រីកាដូបានត្រឡប់វិញ ហើយសួរសំណួរមួយដល់ខ្ញុំ ។ បន្ទាប់មក ខ្ញុំបាននិយាយថា « រីកាដូ ព្រះវិហាររបស់ខ្ញុំមានសកម្មភាពសម្រាប់គូស្វាមីភរិយាដែលរៀបការរួច ។ យើងនឹងចែកចាយបទពិសោធន៍អំពីរបៀបដើម្បីរស់នៅដោយរីករាយរៀងរាល់ថ្ងៃ ។ បន្ទាប់ពីកម្មវិធីនោះចប់ យើងនឹងរាំកម្សាន្ត ។ ខ្ញុំសូមអញ្ជើញអ្នកឲ្យទៅកម្មវិធីនោះ តើអ្នកនឹងទៅកម្មវិធីនោះដែរឬទេ ? »



*ខ្ញុំបានជូនលិខិតអញ្ជើញនោះទៅមនុស្សប្រាំបួននាក់នៅកន្លែងធ្វើការ ហើយនៅសល់លិខិតមួយទៀត ។ ខ្ញុំពុំដឹងថា ខ្ញុំត្រូវជូនលិខិតអញ្ជើញនោះទៅនរណាទេ ។*

រីកាដូបាននិយាយថា « បាទ ខ្ញុំនឹងទៅ ! » ប៉ុន្តែចម្លើយរបស់គាត់ពុំធ្វើឲ្យខ្ញុំជឿគាត់ឡើយ ។

ខ្ញុំបានគិតថា « យ៉ាងហោចណាស់ខ្ញុំបានធ្វើកិច្ចការដែលខ្ញុំត្រូវធ្វើហើយ » ។

ភរិយាខ្ញុំ និងខ្ញុំបានទៅដល់ព្រះវិហារមុនគេ ដើម្បីស្វាគមន៍មនុស្សពេលពួកគេមកដល់ ។ រំពេចនោះ ខ្ញុំបានឃើញរីកាដូ និងភរិយាគាត់រេជីណា ។ ខ្ញុំបានណែនាំពួកគេឲ្យស្គាល់ភរិយាខ្ញុំ និងមនុស្សដទៃដែលចូលរួមកម្មវិធីនោះ ។ ពេញមួយល្ងាចនោះ រីកាដូ និងរេជីណា ហាក់ដូចជារីករាយនឹងកម្មវិធីនោះណាស់ ។ ខ្ញុំមានក្តីរំភើបចិត្ត ពេលពួកគេនិយាយថា ពួកគេនឹងមកចូលរួមព្រះវិហារនៅថ្ងៃអាទិត្យដើម្បីរៀនបន្ថែមទៀត ។

រីកាដូ និងរេជីណា និងកូនពីរនាក់របស់ពួកគេបានរៀនបន្ថែមទៀត ។ ទីបំផុត ពួកគេបានចូលរួមសាសនាចក្រ ។ ក្រោយមកទៀត ពួកគេបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ មានគ្រាមួយ រីកាដូបានប្រាប់ខ្ញុំថា គាត់ និងភរិយាគាត់បាននិយាយគ្នាពីរឿងលែងលះគ្នា ប៉ុន្តែក្រោយមកព្រះអម្ចាស់បានដឹកនាំរីកាដូឲ្យទៅការិយាល័យរបស់ខ្ញុំ ។

ចាប់តាំងពីពេលនោះមក ខ្ញុំបានអធិស្ឋានទូលសូមឲ្យព្រះអភ័យទោសដល់ខ្ញុំដែលគិតថា រីកាដូនឹងពុំទទួលលិខិតអញ្ជើញរបស់ខ្ញុំទេ ។ ខ្ញុំបានដឹងថា វាគឺជារឿងសំខាន់ដើម្បីអញ្ជើញមនុស្សគ្រប់រូប ។ អ្នកមិនអាចដឹងមុនទេថា តើនរណាខ្លះដែលនឹងទទួលយកការអញ្ជើញនោះ ។ ■

**ម៉ាទីន អាប៉ូឡូ ខូដ្ឋាំ ទីក្រុង ប៉ាក់ណា ប្រទេសប្រេស៊ីល**

រចនារូបភាពដោយ ខាងី ដុកត្រឹប

# អាជីវកម្មកំពុងដំណើរការល្អ

ដោយ យូស្វេ ជេ. ភីឌី
ទស្សនាវដ្ដីសាសនាចក្រ

ដោយអរគុណចំពោះអ្វីដែលគាត់បានរៀននៅក្នុងថ្នាក់ភាពខ្លួនទីពឹងខ្លួន នោះ ថេឌី រេយើស រកឃើញឱកាសថ្មីមួយទៀត ទោះបីគាត់បាត់បង់ឱកាសមួយក្ដី ។

ម៉ោង ៤ ព្រឹកនៅទីក្រុងសានតូ ដូមីងហ្គោ សាធារណៈរដ្ឋដូមីនីហ្គែន ហើយ ថេឌី រេយើ បានក្រោកឡើង ហើយកំពុងធ្វើការ ។ គាត់មានកិច្ចការច្រើនត្រូវធ្វើដើម្បីឲ្យអាជីវកម្មរបស់គាត់ដំណើរល្អ ។ គាត់បានចាប់ផ្ដើមចិតប៉េងប៉ោះ និងនំបុ័ងជាចំណិតៗ ។ បន្ទាប់មក គាត់ធ្វើទឹកជ្រលក់ពិសេសរបស់គាត់ ។



នៅម៉ោង ៦ ព្រឹក បុគ្គលិកពីរនាក់បានមក ហើយជួយធ្វើការគាត់ និងការរៀបចំត្រូវបន្ថែមល្បឿនឡើង ។ ពេលម៉ោង ៨ ព្រឹក ពួកគេធ្វើនំបុ័ងសាំវិចបាន ៣០០ ខ្ចប់ ដាក់ក្នុងកញ្ចប់ប្លាស្ទីក ហើយដាក់វាក្នុងថង់ ។ បុគ្គលិកប្រាំមួយនាក់ទៀតបានមកដល់ ហើយក្រុមនេះទាំងមូលបានចេញទៅក្រៅដើម្បីលក់ ។

ត្រឹមម៉ោង ៩ ព្រឹក ពួកគេលក់នំបុ័ងសាំវិចដាច់ទាំងអស់ លើកលែងតែមួយចំនួនប៉ុណ្ណោះ—គឺនំបុ័ងបីឬបួនដែលថេឌី ទុកសម្រាប់ក្រុមរបស់គាត់ ។

អាជីវកម្មនេះល្អសម្រាប់ថេឌី ។ ប៉ុន្តែអ្វីគ្រប់យ៉ាងមិនស្រួលជានិច្ចនោះទេ ។ ប្រាកដណាស់ អស់រយៈពេលប្រាំឆ្នាំមកហើយ គាត់ពុំអាចរកបានការងារមានស្ថេរភាពមួយក្នុងវិជ្ជាជីវៈដែលគាត់បានជ្រើសរើសឡើយ—គឺមេធាវី ។

ដូច្នេះ តើថេឌីបានធ្វើការផ្លាស់ប្ដូរពីការប្រឹក្សាដល់អតិថិជនមកលក់នំបុ័ងសាំវិចដោយរបៀបណា ? ប្រាកដណាស់ វាតម្រូវឲ្យមានការខិតខំខ្លាំង

ប៉ុន្តែវាក៏ត្រូវអនុវត្តគោលការណ៍ទាំងនោះដោយប្រុងប្រយ័ត្ន ជាគោលការណ៍ដែលគាត់បានរៀននៅក្នុងថ្នាក់កម្មវិធីសេវាកម្មភាពខ្លួនទីពឹងខ្លួនរបស់សាសនាចក្រ ។

## ការបាត់បង់ការងាររបស់គាត់

អស់រយៈពេលប្រាំឆ្នាំ ជីវិតរបស់ថេឌីគឺអស្ចារ្យណាស់ ។ គាត់មានការងារមួយល្អក្នុងនាមជាមេធាវី គាត់ទើបតែរៀបការរួច ហើយគាត់បានជ្រមុជទឹកភរិយារបស់គាត់ ។ គាត់និយាយថា « ប៉ុន្តែយើងមានឧបសគ្គមួយចំនួន ហើយខ្ញុំបានបាត់បង់ការងាររបស់ខ្ញុំ » ។

អស់រយៈពេលបួនឆ្នាំបន្ទាប់មកទៀត ថេឌីមានការលំបាកក្នុងការស្វែងរកការងារ ។ « មានការងារច្រើនដែលខ្ញុំអាចធ្វើបាន ប៉ុន្តែគ្មាននរណាម្នាក់ចង់បង់ថ្លៃឈ្នួលឲ្យខ្ញុំឡើយ ។ ខ្ញុំបានព្យាយាមចាប់ផ្តើមមុខរបរផ្សេងដោយខ្លួនឯង ប៉ុន្តែវាពុំដំណើរការទេ » ។

ស្ទេផានីភរិយារបស់គាត់មានការងារល្អមួយ ប៉ុន្តែប្រាក់ខែរបស់គាត់តែឯងពុំអាចផ្គត់ផ្គង់ថ្លៃចាយវាយគ្រប់ឡើយ ។ មិនយូរប៉ុន្មានក្រោយមក គូស្វាមីភរិយានេះមានកូនម្នាក់ ។ ពួកគេមានក្តីរំភើបណាស់ ប៉ុន្តែហិរញ្ញវត្ថុរបស់ពួកគេមានកាន់តែតិច ។ ពួកគេបានបាត់បង់ផ្ទះ ពួកគេត្រូវលក់ឡានរបស់ពួកគេ ហើយចាយប្រាក់សន្សំទាំងអស់របស់ពួកគេ ។ ទីបំផុតពួកគេត្រូវប្តូរទៅនៅក្នុងផ្ទះតូចមួយដែលជារបស់ម្តាយស្ទេផានី ។

ប៉ុន្តែថេឌីពុំចុះចាញ់ឡើយ ។ មិនយូរប៉ុន្មានក្រោយមក ឱកាសពុំបានរំពឹងទុកមួយបានបង្ហាញឡើង ។

## អំណាចនៃភាពខ្លួនទីពឹងខ្លួន

បន្ទាប់ពីច្រើនឆ្នាំនៃការលំបាក ថេឌីបានដឹងថា វាដល់ពេលត្រូវផ្លាស់ប្តូរហើយ ។

គាត់និយាយថា « ខ្ញុំបានសម្រេចចិត្តចូលរៀនថ្នាក់ភាពខ្លួនទីពឹងខ្លួនរបស់សាសនាចក្រ ។ ខ្ញុំបានឮពីថ្នាក់នេះ ប៉ុន្តែខ្ញុំតែងតែគិតថា ថ្នាក់ទាំងនោះមិនមែនសម្រាប់ខ្ញុំទេ ។ ខ្ញុំបានគិតថា វាគឺជាការធ្វើកិច្ចការដោយខ្លួនយើង ។ ថ្នាក់រៀនទាំងនោះគឺអស្ចារ្យណាស់ » ។

ដំបូងថេឌីបានចូលរួមក្រុមហិរញ្ញវត្ថុផ្ទាល់ខ្លួន ។ បន្ទាប់មក គាត់បានចូលរួមក្រុម ការចាប់ផ្តើម និងការពង្រីកអាជីវកម្មរបស់ខ្ញុំ ។ ការពិភាក្សាក្នុងថ្នាក់បានជួយថេឌីឲ្យមានចំណេះដឹងផ្នែកអាជីវកម្ម ប៉ុន្តែក៏ជួយគាត់អភិវឌ្ឍផ្នែកខាងវិញ្ញាណផងដែរ ។

គាត់បាននិយាយថា « ការរៀនថ្នាក់ទាំងនេះបានផ្លាស់ប្តូរអ្វីគ្រប់យ៉ាង ។ ខ្ញុំបានសម្រេចចិត្តធ្វើអ្វីដែលពួកគេបានបង្រៀន ។ ហើយហិរញ្ញវត្ថុរបស់ខ្ញុំបានផ្លាស់ប្តូរភ្លាមៗ ។ ខ្ញុំបានចាប់ផ្តើមថ្វាយដង្វាយមួយភាគក្នុងដប់ពេញលេញ អធិស្ឋានរៀងរាល់ថ្ងៃ សិក្សាព្រះគម្ពីរ និងអនុវត្តសេចក្តីជំនឿ ។ ហើយអ្វីៗបានផ្លាស់ប្តូរ—ខ្ញុំបានចាប់ផ្តើមសន្សំប្រាក់ ហើយរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ។ គ្រប់គោលការណ៍ទាំងអស់បានផ្តល់ពរដល់ខ្ញុំ » ។

នៅក្នុងក្រុម ការចាប់ផ្តើម និងការពង្រីកអាជីវកម្មរបស់ខ្ញុំ ថេឌីបានរៀនពីរបៀបស្វែងរកផលិតផលដែលមានសក្តានុពល ដែលអាចផ្តល់ប្រយោជន៍ដល់អតិថិជននៅកន្លែងដែលគាត់រស់នៅ ។ ពេលគាត់បានវាយតម្លៃនូវអ្វីដែលមនុស្សកំពុងស្វែងរក នោះការបំផុសគំនិតបានចាប់ផ្តើមកើតមានឡើង ។ នៅក្នុងតំបន់របស់គាត់មនុស្សចូលចិត្តនំប៉័ងសាំវិចស្រស់ៗ ប៉ុន្តែពួកគេក៏ចូលចិត្តបញ្ជាទិញវា—ហើយដឹកវាយកទៅឲ្យពួកគេផងដែរ ។

ថេឌីនិយាយថា « មានភោជនីដ្ឋានជាច្រើនមានទឹកជ្រលក់ពិសេសដែលធ្វើឲ្យអាហាររបស់ពួកគេឆ្ងាញ់ ។ ដូច្នេះខ្ញុំបានធ្វើទឹកជ្រលក់សាំវិចពិសេសផ្ទាល់ខ្លួនខ្ញុំ » ។

## ការពង្រីកអាជីវកម្មរបស់គាត់

នៅថ្ងៃដែលគាត់បើកអាជីវកម្មរបស់គាត់ ថេឌីបានធ្វើនំប៉័ងសាំវិចចំនួន ៣០ ដើម ។

គាត់និយាយថា « សាមសិបនាទីក្រោយមក ខ្ញុំបានត្រឡប់ទៅផ្ទះវិញ ។ ភរិយាខ្ញុំមានចិត្តព្រួយពេលគាត់ឃើញខ្ញុំដេកលើសាឡុង ។ គាត់បានសួរខ្ញុំថា តើខ្ញុំមកផ្ទះវិញហើយ—តើខ្ញុំមិនទៅលក់នំប៉័ងសាំវិចទេឬអី ? ខ្ញុំបានលក់វាដាច់អស់ហើយ ! »

ពីរបីសប្តាហ៍បន្ទាប់មក ថេឌីបានទាក់ទងអាជីវកម្ម និងសាលារៀនក្នុងមូលដ្ឋាន ។ មានមនុស្សជាច្រើនអន្ទះសារទិញនំប៉័ងសាំវិចរបស់គាត់ ហើយអាជីវកម្មរបស់គាត់បានរីកចម្រើនឡើង ។ គាត់បានរៀនយ៉ាងលឿនអំពីរបៀបរក្សាបន្លែស្រស់ដើម្បីគាត់អាចទុកវាបានយូរ ។ គាត់ក៏ដឹងច្បាស់ថា តើទឹកជ្រលក់ពិសេសរបស់គាត់អាចទុកបានយូរប៉ុណ្ណាផងដែរ ។ គាត់បានបញ្ជាទិញ និងយកនំប៉័ងរៀងរាល់ល្ងាច ។ គាត់ទិញបន្លែបញ្ចុះតម្លៃនៅរាល់ថ្ងៃសៅរ៍ ដែលមានតម្លៃថោកជាង ហើយអាចទុកបានរហូតដល់ថ្ងៃចន្ទ ។

មិនយូរប៉ុន្មានក្រោយមក គេបានបញ្ជាទិញនំប៉័ងសាំវិចជាច្រើនប្រភេទពីគាត់ ហើយទិញច្រើនៗសម្រាប់កម្មវិធីពិសេសៗ ។ គាត់ត្រូវការជំនួយ ហើយបានចាប់ផ្តើមជួលបុគ្គលិកឲ្យធ្វើការ ។

ដោយបង្កើតទំនាក់ទំនងវិជ្ជមានជាមួយសាលារៀន និងអាជីវកម្មក្នុងមូលដ្ឋាន ថេឌីបានបង្កើតក្រុមអតិថិជនដែលសកម្ម និងជាប់លាប់ ។ ក្នុងរយៈពេលបួនខែ គាត់មានបុគ្គលិកប្រាំបីនាក់ ហើយបានលក់នំប៉័ងសាំវិច ៣០០ ដើមក្នុងមួយថ្ងៃ ប្រាំថ្ងៃមួយសប្តាហ៍ ។ ក្រុមលក់របស់គាត់ពិតជាមានប្រសិទ្ធភាពណាស់ ពួកគេបានលក់សាំវិចទាំងអស់ ទោះបីអំឡុងពេលរដូវក្តៅជាពេលដែលសាលារៀនសម្រាកក្តី ។ ឥឡូវនេះថេឌីត្រៀមខ្លួនដើម្បីពង្រីកអាជីវកម្មទៀត ។

ដោយសារគាត់បានរៀនថ្នាក់ភាពខ្លួនទីពឹងខ្លួននោះគាត់ត្រូវបានបំផុសគំនិតឲ្យកើតមានគំនិតនៃការលក់នំសាំងវិច ។ គាត់និយាយថា « ដោយសារការណែនាំនេះពីសាសនាចក្រ និងពរជ័យដែលខ្ញុំបានទទួលនោះខ្ញុំមានទីបន្ទាល់យ៉ាងរឹងមាំអំពីសាសនាចក្រ និងព្រះយេស៊ូវគ្រីស្ទ » ។ ■

រូបថតដោយ រ៉ុល សានធ្វី



# កូនប្រុសយើងគឺជាបុត្រ របស់ព្រះវរបិតាសួគ៌

ដោយ ជើលីន មើហ្វី

ហេឌិនកូនប្រុសតូចដ៏គួរឲ្យស្រឡាញ់របស់យើង បានកើតមកលើផែនដីនេះដោយស្លេកស្លាំង អត់ដកដង្ហើម និងមានការពិបាកនឹងរស់នៅ ។ អត់យំ ។ អត់កម្រើក ។

ពេលវេជ្ជបណ្ឌិត និងគិលានុប្បដ្ឋយិការត់ខ្វែងដៃខ្វែងជើងពេញបន្ទប់ពេទ្យ នោះខ្ញុំដឹងថា មានអ្វីអាក្រក់បានកើតឡើងហើយ ។ ស្វាមីខ្ញុំ និងឪពុកខ្ញុំបានផ្ដល់ការប្រសិទ្ធពរបព្វជិតភាពមួយភ្លាមឲ្យហេឌិន ហើយហេឌិនត្រូវបានយកទៅបន្ទប់សង្គ្រោះបន្ទាន់ភ្លាម ។ មិនយូរប៉ុន្មានក្រោយមក វេជ្ជបណ្ឌិតបានធ្វើរោគវិនិច្ឆ័យថា ហេឌិនមានជំងឺបេះដូងមិនប្រក្រតីដ៏កម្រមួយ ។ ហេឌិនបានទទួលការវះកាត់បេះដូងជាច្រើនដងក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ ។

តាមរយៈអំណាចនៃការប្រសិទ្ធពរបព្វជិតភាពប្រកបដោយអព្ភូតហេតុ ការតមអាហារ និងអធិស្ឋាន នោះហេឌិនបានរស់រានមានជីវិតទោះបីគាត់មិនត្រូវបានរំពឹងថានឹងរស់ក្ដី ។ យើងបានរីករាយជាខ្លាំងដើម្បីនាំយកកូនប្រុសរបស់យើងមកផ្ទះ ហើយចាប់ផ្ដើមជីវិតថ្មីរបស់យើងជាមួយគ្នា ។

ហេឌិនបាននាំមកនូវអំណរដ៏ច្រើនអនេកមកក្នុងជីវិតយើង ។ យើងស្រឡាញ់ និងពេញចិត្តគាត់ណាស់ ។ ប៉ុន្តែយូរៗទៅ ខ្ញុំបានចាប់ផ្ដើមបារម្ភថា គាត់ពុំរីកលូតលាស់ដូចការរំពឹងទុកឡើយ ។ ទោះបីអ្នកឯកទេសបានបញ្ជាក់ជាមួយយើងថា គាត់នឹងអភិវឌ្ឍក្ដី ក៏មន្ទិលសង្ស័យបានបន្ដមាន កាលខ្ញុំពុះពារជួយដល់កូនប្រុសរបស់ខ្ញុំ ។

ស្វាមីខ្ញុំ និងខ្ញុំបានសិក្សាអំពីអ្វីៗទាំងអស់ដែលយើងអាចរៀនពីជំងឺរបស់ហេឌិន ។ យើងបានធ្វើនូវអ្វីគ្រប់យ៉ាងដែលវេជ្ជបណ្ឌិតបានប្រាប់យើងឲ្យធ្វើ ។ ប៉ុន្តែការរីកចម្រើននោះពុំកើតឡើងសោះ ។

ការនឿយហត់ និងភាពស្មុគស្មាញរបស់ខ្ញុំបានកើនឡើង ។ ខ្ញុំបានទូលអង្វរដល់ព្រះវរបិតាខ្ញុំដែលគង់នៅស្ថានសួគ៌ ឲ្យជួយខ្ញុំស្វែងរកនរណាម្នាក់ដែលអាចជួយហេឌិន ប៉ុន្តែជំនួយនោះពុំបានកើតឡើងទេ ។

ស្ថានភាពរបស់ហេឌិនប្រែកាន់តែដុនដាបទៅៗ ។ គាត់បានចាប់ផ្ដើមមានការប្រកាច់ ។ យើងមានការភ័យព្រួយ ។ យើងគិតថា យើងនឹងបាត់បង់គាត់ហើយ ។

យប់មួយ ខ្ញុំនៅស្រាវជ្រាវរកចម្លើយរហូតដល់យប់ជ្រៅ ។ ខ្ញុំបានសរសេរសំបុត្រមួយឲ្យទៅហេឌិន ។ ខ្ញុំបានប្រាប់គាត់អំពីក្ដីស្រឡាញ់ដ៏ធំធេងដែលខ្ញុំមានចំពោះគាត់ និងពីការខិតខំជាខ្លាំងដែលខ្ញុំបានធ្វើដើម្បីឲ្យជីវិតគាត់មានភាពងាយស្រួល ។ ខ្ញុំបានសន្យាថា ខ្ញុំនឹងចំណាយពេលពេញមួយជីវិតរបស់ខ្ញុំ ដើម្បីរកជំនួយតាមគាត់ត្រូវការ ។

ភាពស្មុគស្មាញ និងគ្រាដែលពុំប្រាកដប្រជាបានកើតមានចំពោះខ្ញុំ ។ ខ្ញុំបានលុតជង្គង់ចុះ ហើយទូលសួរទៅកាន់ព្រះវរបិតារបស់ខ្ញុំដែលគង់នៅស្ថានសួរថា « ហេតុអ្វី ? » ខ្ញុំបានគិតថា ទ្រង់បានបញ្ជូនហេឌិនមកខ្ញុំ ដោយសារទ្រង់បានដឹងថា ខ្ញុំពុំបោះបង់ការព្យាយាមជួយកូនប្រុសខ្ញុំឡើយ ។ ដូច្នេះ ហេតុអ្វីខ្ញុំពុំបានចម្លើយអ្វីសោះ ? ហេតុអ្វីវេជ្ជបណ្ឌិតថ្មីគ្រប់រូប និងការព្យាបាលថ្មីៗនាំទៅរកឧបសគ្គផ្សេងមួយទៀត ? តើព្រះវរបិតាសួគ៌មិនស្រឡាញ់ហេឌិនទេឬ ?

ខ្ញុំនឹងមិនភ្លេចគ្រានោះឡើយ ។ រំពេចនោះ អារម្មណ៍នៃសេចក្ដីស្រឡាញ់ដ៏ជ្រាលជ្រៅបានផុសឡើងនៅក្នុងចិត្តខ្ញុំភ្លាម ។ ពាក្យដែលពុំមែនជាពាក្យផ្ទាល់របស់ខ្ញុំបានផុសឡើងក្នុងគំនិតខ្ញុំថា ៖ « ជើលីន តើអ្នកគិតថា អ្នកស្រឡាញ់គាត់ជាងយើងស្រឡាញ់គាត់ឬ ? »

ខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ។ ម៉ោងហាក់ដូចជានៅស្ងៀមទ្រឹង ។ ទឹកភ្នែកបានហូរចុះលើមុខខ្ញុំ—ពុំមែនដោយភាពស្មុគស្មាញពីមុនទេ ប៉ុន្តែដោយសារសេចក្ដីសង្ឃឹម ការយល់ដឹង និងសេចក្ដីស្រឡាញ់វិញ ។

នៅគ្រានោះ អ្វីៗគ្រប់យ៉ាងបានផ្លាស់ប្ដូរ ។ ចិត្តរបស់ខ្ញុំត្រូវបានបន្ទន់ ។ សំណួររបស់ខ្ញុំបានផ្លាស់ប្ដូរ ។ ឥឡូវនេះ ខ្ញុំយល់ថា ព្រះវរបិតាគង់នៅស្ថានសួគ៌ស្រឡាញ់ហេឌិនដោយនូវសេចក្ដីស្រឡាញ់ដ៏ល្អឥតខ្ចោះ ។ ហេឌិនត្រូវបានបញ្ជូនមកកាន់ផែនដីនៅក្នុងរូបកាយដែលស័ក្ដិសមសម្រាប់តម្រូវការរបស់គាត់ និងឱកាសគាត់សម្រាប់រីកចម្រើន និងរៀនសូត្រ ។ គាត់មានសមត្ថភាពពិសេស និងឧបសគ្គផ្ទាល់ខ្លួនគាត់ ដូចជាពួកយើងម្នាក់ៗមានផងដែរ ។ ខ្ញុំបានដឹងច្បាស់ថា កុមារដែលពិការគឺមានតម្លៃ ហើយជាបុត្រសំណព្វរបស់ព្រះវរបិតាសួគ៌ ដែលមានបេសកកម្មពិសេសនៅលើផែនដីនេះ ។

ស្វាមីខ្ញុំ និងខ្ញុំបន្តទទួលចម្លើយ និងពរជ័យ ប៉ុន្តែវាកើតឡើងតាមពេលវេលារបស់ព្រះអម្ចាស់ ពុំមែនតាមពេលវេលារបស់យើងទេ ។ យើងត្រូវបានដឹកនាំទៅរកសៀវភៅ

ពាក្យដែលពុំមែនជាពាក្យផ្ទាល់របស់ខ្ញុំបានផុសឡើងក្នុងគំនិតខ្ញុំថា ៖ « តើអ្នកគិតថា អ្នកស្រឡាញ់គាត់ជាងយើងស្រឡាញ់គាត់ឬ ? »

ការព្យាបាល សាលារៀន និងគ្រូបង្រៀនត្រឹមត្រូវ ដើម្បីជួយហេឌិនមានជោគជ័យក្នុងជីវិតរមែងស្លាប់របស់គាត់ ។ យើងព្យាយាមស្រាវជ្រាវរកផ្លូវដែលព្រះវរបិតាគង់នៅស្ថានសួគ៌បានដាក់សម្រាប់ហេឌិន ជំនួសឲ្យផ្លូវដែលយើងចង់បានឲ្យគាត់ដើរ ។ យើងកំពុងធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើបាន ដើម្បីជួយហេឌិនឲ្យឈានទៅដល់សក្ដានុពលនៃភាពជាព្រះរបស់គាត់ និងរស់នៅក្នុងជីវិតដែលព្រះវរបិតាសួគ៌បានរៀបចំសម្រាប់គាត់ ។ ការយល់ដឹងរបស់យើងអំពីផែនការរបស់ព្រះវរបិតាសួគ៌បានប្រែកាន់តែច្បាស់ឡើងក្នុងពេលនេះ ដោយសារយើងយល់ថា ហេឌិនគឺបុត្ររបស់ទ្រង់ពីមុនគាត់ក្លាយជាកូនរបស់យើង ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ អារីស្សូណា ស.រ.អា. ។*



**រូបកាយ ៖ អំណោយដែលពុំអាចកាត់ថ្លៃបាន**

« ជាទូទៅ សម្រាប់ហេតុផលដែលយើងមិនដឹង មនុស្សខ្លះបានកើតមកពិការ ។ ផ្នែកជាក់លាក់នៃរាងកាយ អាចមិនប្រក្រតី ។ ប្រព័ន្ធជីវសាស្ត្រទាំងឡាយអាចមិនដំណើរការប្រក្រតី ។ ហើយរូបកាយយើងទាំងអស់គ្នាអាចមានជំងឺ ហើយស្លាប់ ។ ទោះយ៉ាងណា អំណោយនៃរូបកាយខាងសាច់ឈាម គឺមិនអាចកាត់ថ្លៃបានទេ ។ ប្រសិនបើគ្មានរូបកាយទេនោះ យើងពុំអាចទទួលបានអំណរដ៏ពោរពេញឡើយ ។

« មិនតម្រូវឲ្យមានរូបកាយល្អឥតខ្ចោះមួយ ដើម្បីសម្រេចបានជោគវាសនាដ៏ទេវភាពនោះទេ ។ ការពិត វិញ្ញាណដ៏ផ្អែមល្ហែមមួយចំនួនត្រូវបានដាក់ក្នុងរូបកាយទន់ខ្សោយ ។ ជាញឹកញាប់ កម្លាំងខាងវិញ្ញាណដ៏អស្ចារ្យត្រូវបានអភិវឌ្ឍ ដោយអ្នកដែលមានភាពពិការខាងរាងកាយ ពិតណាស់គឺមកពីពួកគេមានការពិបាកខ្លាំង ។ បុគ្គលបែបនោះស័ក្តិសមនឹងទទួលនូវពរជ័យទាំងអស់ដែលព្រះបានរៀបចំសម្រាប់បុត្រាបុត្រីដ៏ស្មោះត្រង់ និងគោរពប្រតិបត្តិរបស់ទ្រង់ » ។

ប្រធាន រ័សុល អិម ណិលសុន « We Are Children of God » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៨៦–៨៧ ។

រូបថតរបស់អ្នកនិពន្ធ និងកូនប្រុសរបស់នាង

# ការដោះស្រាយជាមួយនឹងសោកនាដកម្ម

មិនយូរមិនឆាប់ កុមារនឹងជួបនូវសោកនាដកម្ម ទោះបីវានៅជិតផ្ទះ ឬនៅឆ្ងាយពីផ្ទះក្ដី ។ ប៉ុន្តែ « ទោះបីជាពេលដែលពិភពលោកស្ថិតនៅក្នុងភាពចលាចលនៅជុំវិញខ្លួនអ្នកក្ដី ក៏អ្នកអាចទទួលបានពរជ័យនៃភាពសុខសាន្តនៅក្នុងចិត្តដែរ » ។[១] នេះជារបៀបមួយចំនួនដែលអ្នកអាចធ្វើដើម្បីជួយកុមារឲ្យទទួលភាពសុខសាន្តនោះ ។



## ស្ថេរភាព

នៅពេលសោកនាដកម្មអ្វីមួយកើតឡើង កុមារអាចមានអារម្មណ៍ថា ជីវិតរបស់ពួកគេដូចជាពុំមានតុល្យភាពទេ ។ ចូរធ្វើជាគំរូនៃភាពខ្ជាប់ខ្ជួនដល់ពួកគេ ។ ចូរនិយាយដោយរម្ងាប់អារម្មណ៍ និងដោយទំនុកចិត្តអំពីបញ្ហានោះ ។ ចូរបន្តធ្វើកិច្ចការដែលអ្នកធ្វើតាមដែលអាចធ្វើទៅបាន ។ ធ្វើឲ្យអស់ពីសមត្ថភាពរបស់អ្នកដើម្បីធ្វើរាត្រីជួបជុំក្រុមគ្រួសារ សិក្សាព្រះគម្ពីរ អធិស្ឋាន និងទម្លាប់ផ្សេងទៀតជាមួយគ្រួសារ ។ យូរៗទៅ កុមារអាចរៀនថា ទោះបីពេលជីវិតរបស់ពួកគេមានការរំខានក្ដី ដំណឹងល្អនាំមកនូវទស្សនវិស័យ ហើយជីវិតនៅតែបន្តទៅមុខ ។

## ការគោរព

បង្ហាញការគោរពដល់ផ្លូវអារម្មណ៍របស់កុមារ ។ សូមស្ដាប់កុមារ ហើយទទួលស្គាល់អារម្មណ៍ពួកគេ ។ សូមបង្ហាញពួកគេថាអ្នកកំពុងចាត់ទុកកង្វល់របស់ពួកគេជារឿងសំខាន់ ។ កុំបង្ខំពួកគេឲ្យនិយាយ ប្រសិនបើពួកគេត្រូវការពេលវេលា ប៉ុន្តែទុកឲ្យពួកគេដឹងថា អ្នកមានពេល ពេលពួកគេត្រៀមខ្លួនរួចរាល់ដើម្បីនិយាយ ។ សូមឆ្លើយសំណួរដោយស្មោះត្រង់ តាមរបៀបដែលពួកគេយល់បាន ។ សូមឲ្យកុមារដឹងថា ពួកគេអាចនិយាយជាមួយអ្នកជានិច្ចអំពីការភ័យខ្លាច និងក្ដីបារម្ភរបស់ពួកគេ ។





## ការណែនាំ

កូនរបស់អ្នកអាចសួរថា « ហេតុអ្វីព្រះទុកឲ្យរឿងអាក្រក់កើតឡើង ? » សូមពន្យល់ថា ទាំងគ្រាល្អ និងគ្រាអាក្រក់គឺជាផ្នែកមួយនៃជីវិតរបស់យើង ហើយជាផ្នែកមួយនៃផែនការអស់កល្បរបស់ព្រះ ។ ទ្រង់អនុញ្ញាតឲ្យមនុស្សម្នាក់ធ្វើការជ្រើសរើសរៀងៗខ្លួន ហើយជួនកាលមនុស្សជ្រើសរើសមិនល្អ ដែលបណ្ដាលឲ្យមានការរងទុក្ខ ។ ជួនកាល សោកនាដកម្មពុំមែនជាកំហុសរបស់បុគ្គលណាឡើយ ប៉ុន្តែវាជាផ្នែករបស់ធម្មជាតិ ។ មិនថាមានអ្វីកើតឡើងទេ ព្រះវរបិតាសួគ៌តែងគង់នៅទីនោះសម្រាប់យើងជានិច្ច ។ ជាមួយនឹងជំនួយរបស់ទ្រង់ យើងអាចរៀន និងរីកចម្រើន សូម្បីតែបទពិសោធន៍នោះឈឺចាប់ក្ដី ។ យើងអាចងាកទៅរកទ្រង់ដើម្បីស្វែងរកភាពសុខសាន្ត ។

### ភាពក្លាហាន

សូមបង្ហាញកុមារថា ពួកគេមានអំណាចដើម្បីធ្វើឲ្យមានការផ្លាស់ប្ដូរមួយ តាមរយៈការផ្ដល់របៀបមួយដើម្បីឲ្យពួកគេជួយ ។ ឧទាហរណ៍ ពួកគេអាចប្រមូលការបរិច្ចាគសម្រាប់ជនរងគ្រោះដោយគ្រោះធម្មជាតិ ទៅសួរសុខទុក្ខមិត្តភក្ដិដែលមានជំងឺ ឬរងរបួសនៅមន្ទីរពេទ្យ លួងលោមនរណាម្នាក់ដែលកំពុងបាត់បង់សមាជិកគ្រួសារ ឬអធិស្ឋានសម្រាប់អ្នកដែលកំពុងជួបការលំបាក ។ យើងពុំអាចជួសជុលអ្វីគ្រប់យ៉ាងឡើយ ប៉ុន្តែយើងមានសមត្ថភាពដើម្បីធ្វើកិច្ចការបានច្រើន ហើយ « យើងធ្វើការសម្រាប់ភាពសុខសាន្ត ពេលយើងជួយរំសាយទុក្ខរបស់មនុស្សម្នាក់ទៀត » ។[២]

### លួងលោម

សូមរំឭកកូនរបស់អ្នកថា ព្រះស្រឡាញ់ពួកគេ ហើយអ្នកក៏ស្រឡាញ់ពួកគេដែរ ។ កុំសន្យាកុហកថា គ្មានអ្វីអាក្រក់នឹងកើតឡើងចំពោះពួកគេឡើយ ប៉ុន្តែសូមអះអាងពួកគេថា ពួកគេមានសុវត្ថិភាពក្នុងពេលនេះ ហើយអ្នកនឹងធ្វើអស់ពីសមត្ថភាពដើម្បីការពារពួកគេ ។ សូមធានាអះអាងនឹងពួកគេថា ព្រះវរបិតាសួគ៌នឹងជួយពួកគេឲ្យរួចផុតពីការសាកល្បងដែលកើតមាននៅក្នុងជីវិតពួកគេ ។

ពេលអ្នកឃើញថា អ្នកកើតទុក្ខដោយសារតែសេចក្ដីវេទនានោះ សូមចាំថា នៅទីបំផុត សេចក្ដីល្អនឹងមានជ័យជម្នះលើសេចក្ដីអាក្រក់ ។ ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) បានបង្រៀនថា « យើងកំពុងធ្វើសង្គ្រាមជាមួយអំពើបាប. . .ប៉ុន្តែយើងពុំត្រូវអស់សង្ឃឹមឡើយ ។ វាគឺជាសង្គ្រាមដែលយើងអាច ហើយនឹងឈ្នះបាន ។ ព្រះវរបិតាគង់នៅស្ថានសួគ៌របស់យើងបានប្រទានដល់យើងនូវឧបករណ៍ទាំងឡាយដែលយើងត្រូវការ ដើម្បីអាចឈ្នះបាន ។ ទ្រង់គង់នៅឯចង្កូតនាវា ។ យើងពុំត្រូវខ្លាចឡើយ » ។[៣] ■

កំណត់ចំណាំ

១. « ភាពសុខសាន្ត » Gospel Topics topics.lds.org ។
២. « ភាពសុខសាន្ត » Gospel Topics ។
៣. ថូម៉ាស អេស ម៉នសុន « Looking Back and Moving Forward » *Liahona* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៩០ ។

**សម្រាប់កុមារ**

នៅក្នុងទស្សនាវដ្ដី *ព្រំយមិត្ត* ខែនេះ ៖

- « ខ្ញុំនឹងឃើញទ្រង់ម្ដងទៀត » ( ទំព័រ ខ២០ )
- « ប័ណ្ណលួងលោម » ( ទំព័រ ខ២១ )

សម្រាប់ធនធានផ្សេងទៀត សូមមើលគេហទំព័រ lessonhelps.lds.org ហើយចុចលើ « Lesson Helps by Topic » ។



**សម្រាប់យុវវ័យ**

មាននៅក្នុងច្បាប់នេះ ៖

- « ការស្វែងរកភាពសុខសាន្តសម្រាប់ខ្លួនឯង និងមនុស្សដទៃនៅក្នុងគ្រាលំបាក » ( ទំព័រ ៥២–៥៣ ) ។

សម្រាប់ធនធានផ្សេងទៀត សូមមើលគេហទំព័រ youth.lds.org ។





## តើព្រះកំពុងដឹកនាំខ្ញុំមែនដែរឬទេ ?

ជីវិតរបស់យើងពោរពេញដោយជម្រើសធំៗ ៖ តើគួរជ្រើសរើសមុខរបរអ្វី តើត្រូវរៀបការជាមួយនរណា តើត្រូវរៀននៅសាលាណា ជាដើម ។ ជីវិតរបស់យើងក៏ពោរពេញដោយកង្វល់ជាប្រចាំរបស់យើងផងដែរ ៖ ការជ្រើសរើសប្រើពេលវេលាឲ្យបានល្អបំផុត ព្យាយាមយល់ពីគោលលទ្ធិ និងការស្វែងរកភាពសុខសាន្តពេលកំពុងមានការសាកល្បង ។ សរុបទៅ **យើងត្រូវការវិវរណៈផ្ទាល់ខ្លួន** ។ ប៉ុន្តែពេលខ្លះ វាអាចជាការពិបាកដើម្បីដឹងពីរបៀបទទួលវិវរណៈ និងរបៀបដើម្បីទទួលស្គាល់វា ពេលយើងទទួលវា ។ ពេលយើងពុំទទួលចម្លើយ ឬទទួលស្គាល់ចម្លើយ យើងអាចឆ្ងល់ថា « តើនោះជាព្រះវិញ្ញាណ ឬវាគ្រាន់តែជាគំនិតរបស់ខ្ញុំ ? » « ហេតុអ្វីខ្ញុំបានទទួលការបំផុសគំនិតឲ្យធ្វើរឿងនោះ ហើយបន្ទាប់មកបរាជ័យទៅវិញ ? » « ហេតុអ្វីខ្ញុំមានអារម្មណ៍ថា ព្រះហាក់ដូចជាពុំឆ្លើយតបការអធិស្ឋានរបស់ខ្ញុំដូច្នេះ ? »

សំណាងល្អ នៅក្នុងអត្ថបទ « ការសម្រេចចិត្ត ៖ សិទ្ធិជ្រើសរើស ទល់នឹង វិវរណៈ » ( ទំព័រ ៤៤ ) អ៊ីរិនចែកចាយរឿងរបស់គាត់អំពីវិវរណៈផ្ទាល់ខ្លួនពេលគាត់បានធ្វើការសម្រេចចិត្តមួយដើម្បីផ្លាស់ប្ដូរជីវិត ។ ដោយសារ **ព្រះសព្វព្រះទ័យដឹកនាំយើង** នោះទ្រង់ក៏សព្វព្រះទ័យជួយយើងឲ្យរៀនពឹងផ្អែកលើសិទ្ធិជ្រើសរើសរបស់យើងដើម្បីធ្វើជម្រើសល្អផងដែរ ។

ការរៀនឲ្យដឹងអំពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់អ្នកផ្ទាល់ គឺជាផ្នែកសំខាន់មួយផ្សេងទៀតនៃការទទួល និងការទទួលស្គាល់វិវរណៈ ។ វាអាចមានសភាពខុសគ្នាចំពោះយើងម្នាក់ៗ ។ នៅទំព័រ ៤៨ **យុវមជ្ឈិមវ័យជាច្រើននាក់ចែកចាយអំពីរបៀបដែលពួកគេទទួលវិវរណៈ** ។

នៅក្នុងអត្ថបទដែលមានសម្រាប់តែឌីជីថលប៉ុណ្ណោះ នោះអាស្តែនពន្យល់ថា វិវរណៈផ្ទាល់ខ្លួនតម្រូវឲ្យ « ហ្វឹកហាត់សាច់ដុំខាងវិញ្ញាណរបស់អ្នក » ។

ការគិតអំពីអនាគតអាចធ្វើឲ្យមានភាពស្មុគស្មាញ ហើយថែមទាំងមានការភ័យព្រួយទៀតផង ។ ជាពិសេសក្នុងនាមជាយុវមជ្ឈិមវ័យ ។ ប៉ុន្តែពេលខ្ញុំចាំពីរបៀបដែល **ព្រះបានដឹកនាំជីវិតខ្ញុំ** កាលពីអតីតកាល វាផ្ដល់ភាពក្លាហានដល់ខ្ញុំឲ្យបន្តឆ្ពោះទៅមុខ ហើយធ្វើសកម្មភាព ដោយទុកចិត្តថា **ទ្រង់នឹងបន្តប្រទានការណែនាំដែលខ្ញុំត្រូវការដល់ខ្ញុំ** នៅក្នុងដំណើរជីវិតខ្ញុំ ។

ដោយស្មោះស្ម័គ្រ

ខាធី ស៊ូ អែមប្លី

Katie Sue

# យុវមជ្ឈិមវ័យ

**ពាក្យទូន្មានល្អបំផុត. . .**

*យុវមជ្ឈិមវ័យចែកចាយពាក្យទូន្មានល្អបំផុត ដែលពួកគេធ្លាប់បានទទួលអំពីការទទួលវិវរណៈផ្ទាល់ខ្លួន ៖*

*« មានគ្រាមួយ ថ្នាក់ដឹកនាំ អ៊ី. អេហ្វ. ហ្វ៉ាយ. របស់ខ្ញុំបានប្រាប់ខ្ញុំថា ‹ ចូរអភិវឌ្ឍទំនាក់ទំនងរបស់អ្នកជាមួយព្រះ ទុកដូចជាព្រះវរបិតាខាងវិញ្ញាណពិតប្រាកដរបស់អ្នក ។ ដរាបណាអ្នកមានទំនាក់ទំនងរឹងមាំជាមួយទ្រង់ ដរាបនោះអ្នកនឹងយល់កាន់តែច្បាស់ និងកាន់តែទទួលបានការដឹកនាំ › ។ ការណ៍នោះបានធ្វើឲ្យមានការផ្លាស់ប្ដូរដ៏ធំនៅក្នុងការអធិស្ឋានរបស់ខ្ញុំ » ។*
**—ហ្គ្រាន ហ្គូស្ស៊ី រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា.**

*« លោកអយ្យកោស្ដេករបស់យើងបានឲ្យមនុស្សគ្រប់គ្នាទន្ទេញឃ្លាមួយថា ៖ ‹ ដើម្បីទទួលវិវរណៈ សូមអានវិវរណៈ › ។ ការអានព្រះគម្ពីរពិតជាបានជួយខ្ញុំច្រើនណាស់ ។*
**—ស្បែប៉ាយ ធីបផែត រដ្ឋ មិសសួរី ស.រ.អា.**

*« ចំណាយពេលដើម្បីពិចារណា ។ យ៉ូសែប ស្ម៊ីធ បានពិចារណា យ៉ាកុប ១:៥ ពីមុនលោកសម្រេចចិត្តធ្វើសកម្មភាព ។ ជួនកាលព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើង ដាក់ទុនក្នុងការអធិស្ឋាន និងសិក្សា ពីមុនទ្រង់ប្រទានចម្លើយដល់យើង ។ យើងរៀនបានច្រើនបំផុតតាមការធ្វើបែបនោះ » ។*
**—ណាថាស្យា ហើប រដ្ឋយូថាហ៍ ស.រ.អា**

*« សូមប្រើដួងចិត្តរបស់អ្នកស្ដាប់ ពុំមែនប្រើត្រចៀកអ្នកស្ដាប់ឡើយ » ។*
**—សាយ ធូ សាម័រអាមេរិក**

*តើពាក្យទូន្មានល្អបំផុតអ្វី ដែលអ្នកធ្លាប់បានទទួលអំពីការប្រែចិត្ត ? សូមផ្ញើចម្លើយរបស់អ្នកតាមរយៈ **liahona.lds.org** ឲ្យបានត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩ ។*

**អំពីអ្នកនិពន្ធផ្នែកយុវមជ្ឈិមវ័យ**



**អ៊ីរិន រ៉ាយឌើរ** គឺជាមេធាវី និងជាសហការីនៃការចាក់ផ្សាយ ។ គាត់ទើបតែបានរត់ប្រណាំងកីឡាម៉ារ៉ាតុនពាក់កណ្ដាលលើកដំបូង ។ ពេលទំនេរគាត់ចូលចិត្តអានសៀវភៅ ឡើងភ្នំ លេងកីឡាស្គីលើទឹក និងចំណាយពេលជាមួយនឹងគ្រួសារ និងមិត្តភក្តិ ។



**អាស្ដែន ស្ទែនឌើរ** គឺជាអ្នកនិពន្ធ និងអ្នកកែសម្រួលមកពីរដ្ឋយូថាហ៍ ស.រ.អា. ។ គាត់ចូលចិត្តឡើងភ្នំ ធ្វើដំណើរ អានសៀវភៅ និងលេងព្យាណូ ។



**ខាធី ស៊ូ អែមប្លី** គិតថា ពិភពលោកនេះមានសុទ្ធតែមនុស្សល្អៗដែលគួរតែចែកចាយរឿងរបស់ពួកគេ ។ គាត់សិក្សាផ្នែកអ្នកសារព័ត៌មាន និងភាសាអេស្ប៉ាញ ដោយមានគោលដៅដើម្បីចែកចាយសេចក្ដីល្អ #sharegoodness ។

**ចែកចាយរឿងរបស់អ្នក**

តើអ្នកមានរឿងអស្ចារ្យដើម្បីចែកចាយឬទេ ? ឬតើអ្នកចង់ឃើញអត្ថបទអ្វីខ្លះអំពីប្រធានបទជាក់លាក់នានា ? ដូច្នេះ យើងចង់ឮពីអ្នក ! អ្នកអាចផ្ញើអត្ថបទ ឬមតិកែលម្អរបស់អ្នកតាមគេហទំព័រ **liahona.lds.org** ។

**នៅក្នុងវគ្គនេះ**


**៤៤ ការសម្រេចចិត្ត ៖ សិទ្ធិជ្រើសរើសទល់នឹង វិវរណៈ**
ដោយ អ៊ីរិន រ៉ាយឌើរ

**៤៨ ការធ្វើឲ្យវាក្លាយជាវិវរណៈផ្ទាល់ខ្លួន**




ស្វែងរកអត្ថបទទាំងនេះ និងអ្វីៗបន្ថែមទៀត ៖

- នៅគេហទំព័រ **liahona.lds.org**
- នៅក្នុង **យុវមជ្ឈិមវ័យប្រចាំសប្ដាហ៍** ( ខាងក្រោម « យុវមជ្ឈិមវ័យ » នៅក្នុងកម្មវិធី Gospel Library )
- នៅគេហទំព័រ **facebook.com/liahona**

**មានតែឌីជីថលប៉ុណ្ណោះ**

**ការហ្វឹកហាត់សាច់ដុំខាងវិញ្ញាណរបស់អ្នក**
ដោយ អាស្ដែន ស្ទែនឌើរ



# ការសម្រេចចិត្ត ៖ សិទ្ធិជ្រើសរើស ទល់នឹង វិវរណៈ

**ពេលមានការសម្រេចចិត្តធំៗ តើយើងត្រូវពឹងផ្អែកលើព្រះឲ្យប្រាប់យើងនូវអ្វីដែលយើងត្រូវធ្វើខ្លាំងប៉ុណ្ណា ?**

ដោយ អ៊ីរិន ព៉យឌើរ

រៀងរាល់ថ្ងៃ យើងម្នាក់ៗប្រឈមមុខនឹងការសម្រេចចិត្ត ។ ការសម្រេចចិត្តខ្លះវាជារឿងធម្មតា ដូចជា « តើខ្ញុំគួរស្លៀកពាក់អ្វី ? » « តើខ្ញុំគួរបរិភោគអ្វីសម្រាប់អាហារថ្ងៃត្រង់ ? » « តើវាដល់ពេលត្រូវទិញឡានថ្មី ឬក៏ខ្ញុំអាចនៅទ្រាំប្រើឡានចាស់នេះបន្តិចទៀតសិន ? » ប៉ុន្តែជារឿយៗ យើងជួបនឹងការសម្រេចចិត្តធំៗ—« តើខ្ញុំគួរតែត្រឡប់ទៅរៀនវិញដែរឬទេ ? » « តើខ្ញុំគួរតែទទួលយកការងារនេះដែរឬទេ ? » « តើខ្ញុំគួរតែប្តូរទៅរស់នៅទីក្រុងថ្មីដែរឬទេ ? » « តើខ្ញុំគួរតែទិញផ្ទះដែរឬទេ ? » « តើខ្ញុំគួរតែណាត់ដើរលេងជាគូនឹងបុគ្គលនេះដែរឬទេ ? » « តើខ្ញុំគួរតែរៀបការជាមួយបុគ្គលនេះដែរឬទេ ? » ជាដើម ។

ពេលជួបនឹងការសម្រេចចិត្តធំៗ យើងមានទំនោរ—ដោយសមរម្យ—ប្រើពេលច្រើនដើម្បីធ្វើការសម្រេចចិត្ត ។ យើងធ្វើតាមការទូន្មានដែលអូលីវើរ ខៅឌើរី បានទទួលនៅក្នុង គោលលទ្ធិ និងសេចក្ដីសញ្ញា ៩:៨–៩ ដែលព្រះអម្ចាស់មានបន្ទូលថា ៖

« ប៉ុន្តែមើលចុះ យើងប្រាប់អ្នកថា អ្នកត្រូវសិក្សាក្នុងគំនិតរបស់អ្នក រួចហើយ អ្នកត្រូវសូមដល់យើង បើសិនជាការណ៍នោះត្រឹមត្រូវ ហើយបើសិនជាត្រឹមត្រូវ នោះយើងនឹងបណ្ដាលឲ្យទ្រូងរបស់អ្នកខ្ជួលខ្មាញ់ខាងក្នុង ហេតុដូច្នោះហើយ អ្នកនឹងមានអារម្មណ៍ថា ការណ៍នោះត្រឹមត្រូវ ។

ប៉ុន្តែបើសិនជាការណ៍នោះមិនត្រឹមត្រូវវិញ នោះអ្នកនឹងពុំមានអារម្មណ៍យ៉ាងដូច្នោះឡើយ ប៉ុន្តែអ្នកនឹងអាប់គំនិត ដែលនឹងបណ្ដាលឲ្យអ្នកភ្លេចនូវអ្វីដែលខុស » ។

ទោះបីនេះគឺពិតជាការទូន្មានល្អក្ដី ពេលមានការសម្រេចចិត្តធំៗកើតឡើង ជួនកាលយើងពឹងផ្អែកច្រើនបន្តិចទៅលើផ្នែកដែលព្រះមានបន្ទូលប្រាប់យើងនូវអ្វីដែលត្រឹមត្រូវ ហើយមិនពឹងផ្អែកច្រើនល្មមទៅលើផ្នែកដែលទ្រង់ប្រាប់យើងឲ្យសិក្សាវានៅក្នុងគំនិតយើង ។ យើងបែរជាផ្ដោតចិត្តខ្លាំងទៅលើការទន្ទឹងចាំព្រះ ឲ្យបញ្ជាក់ការសម្រេចចិត្តយើង ដែលយើងបានឲ្យឱកាសដ៏អស្ចារ្យរំលងចេញពីយើងទៅ ។ យើងថែមទាំងទទួលស្គាល់តួនាទីនៃសិទ្ធិជ្រើសរើស ប៉ុន្តែយើងភ័យខ្លាចនឹងការសម្រេចចិត្តដែលអាចទាញយើងចេញពីផ្លូវនៃ « ផែនការ » ដែលបានតាំងចិត្តជាមុន ហើយបញ្ចប់ដោយការសន្មតថា អ្វីៗផ្សេងទៀតក្រៅពីការបណ្ដាលឲ្យទ្រូងខ្ជួលខ្មាញ់ ឬសំឡេងចេញពីស្ថានសួគ៌នោះមានន័យថា ការសម្រេចចិត្តរបស់យើងគឺខុស ។ សម្រាប់យើងជាច្រើន

រចនារូបភាពដោយ ដេវីឌ គ្រីន



នាក់ ភាពតានតឹងដែលពុំអាចថ្លែងបានរវាងសិទ្ធិជ្រើសរើស និងវិញ្ញាណផ្ទាល់ខ្លួនដឹកនាំទៅរកសំណួរសំខាន់មួយ ៖ តើព្រះមានតួនាទីអ្វីនៅក្នុងការជួយយើងឲ្យធ្វើការសម្រេចចិត្ត ?

**តួនាទីរបស់ព្រះក្នុងការសម្រេចចិត្តរបស់យើង**

ប្រហែលសំណួរនេះគឺត្រូវឆ្លើយបានល្អបំផុតតាមរយៈរឿងរបស់បងប្រុសយ៉ារេឌ ? មានលំនាំដ៏គួរឲ្យចាប់អារម្មណ៍មួយស្ដីពីការរីកចម្រើននៅក្នុងរឿងនេះ ដែលបង្រៀនយើងអំពីរបៀបដែលព្រះរំពឹងទុកឲ្យយើងធ្វើការសម្រេចចិត្ត ។ បន្ទាប់ពីបានបំភាន់ភាសានៅប៉មបាបិលមក យ៉ារេឌសូមឲ្យបងប្រុសរបស់លោកទូលសួរព្រះអម្ចាស់ថាតើពួកគេគួរចាកចេញពីដែនដីដែរឬទេ ហើយបើត្រូវចាកចេញមែន តើពួកគេគួរតែទៅទីណា ( សូមមើល អេធើរ ១:៣៦–៤៣ ) ។ បងប្រុសរបស់យ៉ារេឌបានអធិស្ឋាន ហើយព្រះអម្ចាស់បានដឹកនាំពួកគេទៅឆ្នេរសមុទ្រ ។ ពេលពួកគេធ្វើដំណើរព្រះអម្ចាស់បានមានព្រះបន្ទូលទៅកាន់ពួកគេពីលើពពក ហើយបានដឹកនាំពួកគេគ្រប់ជំហាននៃការធ្វើដំណើររបស់ពួកគេ ។ ទីបំផុតពួកគេបានទៅដល់ឆ្នេរសមុទ្រជាកន្លែងដែលពួកគេបានស្នាក់នៅអស់ជាច្រើនឆ្នាំ ។

នៅចុងឆ្នាំទីបួន ព្រះបានប្រាប់បងប្រុសរបស់យ៉ារេឌឲ្យសាងសង់ភេត្រា ដើម្បីត្រៀមខ្លួនឆ្លងកាត់មហាសមុទ្រ ។ ពេលបងប្រុសរបស់យ៉ារេឌដឹងថាភេត្រាទាំងនោះនឹងគ្មានខ្យល់ នោះលោកធ្វើតាមលំនាំដដែល ដោយទៅរកព្រះដើម្បីទូលសូមអ្វីដែលលោកគួរធ្វើ ។ ដូចបានរំពឹងទុក ព្រះអម្ចាស់ឆ្លើយតប ដោយប្រទានការណែនាំលម្អិតដល់លោកឲ្យចោះរន្ធនៅផ្នែកខាងលើ និងបាតភេត្រាទាំងនោះ ។ សូមកត់សម្គាល់ពីលំនាំនៃវិវរណៈកន្លងមក ៖ ព្រះប្រទានផែនការដល់ពួកគេ ពួកគេសួរ

សំណួរអំពីរបៀបដើម្បីបំពេញផែនការនោះ ហើយព្រះឆ្លើយតបនូវចម្លើយដ៏លម្អិត និងច្បាស់លាស់ ។

ប៉ុន្តែបន្ទាប់ពីលោកបានចោះរន្ធនៅក្នុងភេត្រា ហើយនោះ បងប្រុសរបស់យ៉ារេឌដឹងថា ភេត្រានឹងគ្មានពន្លឺទេ ។ ជាថ្មីម្ដងទៀត លោកបានទូលសួរព្រះថា តើលោកគួរតែធ្វើដូចម្ដេច ។ ប៉ុន្តែជំនួសឲ្យការផ្ដល់ចម្លើយ ព្រះបានសួរថា « តើអ្នកចង់ឲ្យយើងធ្វើអ្វី ដើម្បីឲ្យអ្នកមានពន្លឺនៅក្នុងភេត្រាទាំងឡាយរបស់អ្នក ? » ( អេធើរ ២:២៣ ) ។ ជាជាងការប្រទាននូវការណែនាំលម្អិតដូចទ្រង់បានធ្វើកាលពីមុន នៅគ្រានេះព្រះអម្ចាស់រង់ចាំឲ្យបងប្រុសយ៉ារេឌសម្រេចចិត្តធ្វើកិច្ចការនោះ ។

ចម្លើយបែបនេះពីព្រះអម្ចាស់ ប្រហែលជាពិបាកយល់បំផុត ពេលព្យាយាមធ្វើការសម្រេចចិត្តមួយ ។ យើងត្រូវបានបង្រៀនឲ្យអធិស្ឋាន ហើយរង់ចាំទទួលចម្លើយ ដូច្នេះជាទូទៅ យើងបារម្ភពេលយើងអត់ទទួលចម្លើយ ។ ជារឿយៗ យើងឆ្ងល់ថា តើការខ្វះចម្លើយច្បាស់លាស់ស្មើនឹង « អាប់គំនិត » បង្ហាញថាជម្រើសរបស់ខុសឬ ។ មានគ្រាផ្សេងទៀត យើងឆ្ងល់ថា តើវាមានន័យថា យើងពុំសុចរិតល្មមដើម្បីស្ដាប់ចម្លើយ ឬតើយើងពុំបានសូមដោយ « ចិត្តស្មោះសរ » ឬ ( សូមមើល មរ៉ូណៃ ១០:៤ ) ។ ប៉ុន្តែមានជម្រើសទីបី ដែលជួនកាលយើងពុំពិចារណា—ប្រហែលដូចជាបងប្រុសរបស់យ៉ារេឌ ព្រះទន្ទឹងរង់ចាំឲ្យ *យើង* ធ្វើការសម្រេចចិត្ត *ផ្ទាល់* ដោយខ្លួនឯង ។

## ការធ្វើការសម្រេចចិត្ត

ថ្មីៗនេះ ខ្ញុំបានជួបនឹងស្ថានភាពមួយដែលជាឧបសគ្គរាំងផ្លូវខ្ញុំឲ្យគិតអំពីសិទ្ធិជ្រើសរើស និងវិវរណៈផ្ទាល់ខ្លួន ។ ពេលខ្ញុំជិតបញ្ចប់ការសិក្សា មានគេផ្ដល់ការងារផ្សេងៗមួយចំនួនដល់ខ្ញុំនៅក្នុងទីក្រុងផ្សេងៗ ហើយខ្ញុំពុំអាចសម្រេចចិត្តថា ត្រូវយកមួយណាទេ ។ ដូចជាបងប្រុសរបស់យ៉ារេឌដែរ ខ្ញុំបានជួបនូវគ្រាជាច្រើន ដែលខ្ញុំបានអធិស្ឋានអំពីការសម្រេចចិត្តធំៗ ហើយព្រះបានឆ្លើយតបជាមួយនឹងចម្លើយដ៏ច្បាស់លាស់ ។ ដោយពឹងផ្អែកលើបទពិសោធន៍ពីមុនៗ ខ្ញុំបានចាប់ផ្ដើមអធិស្ឋាន ហើយទូលសូមព្រះឲ្យជួយខ្ញុំសម្រេចចិត្តថា តើការងារមួយណាដែលខ្ញុំគួរតែយក ។ ខ្ញុំក៏កំពុងធ្វើផ្នែករបស់ខ្ញុំ តាមរយៈការរៀនអំពីឱកាសការងារនីមួយៗ ហើយប្រឹក្សាជាមួយមនុស្សជាច្រើន ។ ប៉ុន្តែមិនថា ខ្ញុំបានអធិស្ឋាន ឬតមអាហារច្រើនប៉ុណ្ណាទេ ស្ថានសួគ៌ហាក់ដូចជាស្ងប់ស្ងាត់ ហើយខ្ញុំពុំបានទទួលចម្លើយឡើយ ។

ថ្ងៃផុតកំណត់ធ្វើការសម្រេចចិត្តជិតមកដល់ ហើយខ្ញុំបានចាប់ផ្ដើមភ័យ ។ ប្រាកដណាស់ ព្រះអម្ចាស់ត្រូវតែខ្វល់ខ្វាយនឹងការសម្រេចចិត្តបែបនេះ ហេតុអ្វីទ្រង់ពុំឆ្លើយតប ? ប្រហែលជាទ្រង់ពុំខ្វល់ខ្វាយអំពីមុខរបរណាមួយដែលខ្ញុំជ្រើសរើសឡើយ ប៉ុន្តែទ្រង់ត្រូវខ្វល់ថា តើខ្ញុំត្រូវប្ដូរទៅរស់នៅទីក្រុងណាមួយ ដោយសារវានឹងជះឥទ្ធិពលលើជីវិតខ្ញុំ ។ ព្រះអម្ចាស់ខ្វល់ព្រះទ័យនឹងការសម្រេចចិត្តរបស់ខ្ញុំជានិច្ចកាលពីអតីតកាល ហេតុអ្វីទ្រង់មិនខ្វល់ព្រះទ័យនឹងការសម្រេចចិត្តរបស់ខ្ញុំលើកនេះ ?

មិនថា ខ្ញុំខំប្រឹងបែបណាទេ ខ្ញុំពុំបានទទួលចម្លើយឡើយ ។ ខ្ញុំបានចាប់ផ្ដើមឆ្ងល់ថា តើខ្ញុំបានចេញឆ្ងាយពីព្រះឬ បានជាខ្ញុំពុំឮចម្លើយទ្រង់ដូច្នេះ ។ ខ្ញុំក៏ឆ្ងល់ផងដែរថា តើខ្ញុំពុំអាចឮចម្លើយទ្រង់ ដោយសារខ្ញុំមិន *ចង់* ឮចម្លើយឬ ។ ទីបំផុតនៅមួយថ្ងៃមុនដល់ថ្ងៃកំណត់ ខ្ញុំបានដឹងថា ខ្ញុំបានសម្រេចចិត្តហើយ ដូច្នេះខ្ញុំបានប្រើការវិនិច្ឆ័យរបស់ខ្ញុំ ហើយធ្វើការសម្រេចចិត្ត ។ នាយប់នោះខ្ញុំអធិស្ឋានយ៉ាងសាមញ្ញ ដោយទូលសូមទ្រង់ឲ្យប្រាប់ខ្ញុំ ប្រសិនបើចម្លើយរបស់ខ្ញុំខុស ។ នៅតែគ្មានចម្លើយកើតឡើងឡើយ ដូច្នេះខ្ញុំបានបន្តឆ្ពោះទៅមុខ ហើយទទួលយកការងារនោះ ។

បីបួនខែក្រោយមក ខ្ញុំនៅតែមានមន្ទិលសង្ស័យអំពីការសម្រេចចិត្តរបស់ខ្ញុំ ដូច្នេះខ្ញុំបានសូមការប្រសិទ្ធពរបព្វជិតភាពដើម្បីទទួលការបញ្ជាក់ ។ នៅក្នុងការប្រសិទ្ធពរនោះ ខ្ញុំត្រូវបានប្រាប់ថា



ខ្ញុំពុំបានទទួលចម្លើយចំពោះការអធិស្ឋានខ្ញុំទេ ដោយសារព្រះអម្ចាស់សព្វព្រះទ័យនឹងការសម្រេចចិត្តដែលខ្ញុំបានធ្វើ ។ ពរជ័យនេះពង្រឹងដល់ការទូន្មានពីមុនដែលបានផ្ដល់ដល់ខ្ញុំតាមរយៈប្រធានបេសកកម្មខ្ញុំ ដែលបានប្រាប់ខ្ញុំថា ជារឿយៗវាមិនសំខាន់ថា យើងសម្រេចចិត្តធ្វើអ្វីនោះទេ ។ ព្រះសព្វព្រះទ័យឲ្យយើងរៀនអំពីរបៀបដើម្បីពឹងផ្អែកលើខ្លួនឯង ហើយសម្រេចចិត្តពីរបៀបដែលជីវិតយើងត្រូវរស់នៅ ។ ប្រធានបេសកកម្មរបស់ខ្ញុំក៏បានរំឭកខ្ញុំដែរថា ព្រះជាព្រះវរបិតាសួគ៌របស់យើងពុំដាក់ទោសយើង ហើយយកឱកាសនានាដែលបានសន្យាចេញពីយើងទេ ប្រសិនបើយើងមានចិត្តស្មោះ ដោយព្យាយាមចង់ដឹងអ្វីដែលត្រូវធ្វើនោះ ។

បងប្រុសយ៉ារេឌទំនងជាត្រូវបានផ្ដល់យោបល់ឲ្យស្ទើរតែគ្រប់ដំណោះស្រាយទាំងអស់ ដើម្បីបំភ្លឺភេត្រាទាំងនោះ ហើយព្រះអម្ចាស់យល់ស្របនឹងរឿងនោះ ។ ចំណុចនៃបទពិសោធន៍នោះគឺពុំគ្រាន់តែសម្រាប់បងប្រុសយ៉ារេឌពង្រឹងសេចក្ដីជំនឿរបស់លោកទេ លោកថែមទាំងបានរៀនពីរបៀបធ្វើការសម្រេចចិត្តផងដែរ ។

**អនុវត្តសិទ្ធិជ្រើសរើស**

ចេញពីទស្សនវិស័យអស់កល្បមួយ ការអនុវត្តសិទ្ធិជ្រើសរើសគឺជាធាតុចាំបាច់មួយដើម្បីរីកចម្រើនផ្ទាល់ខ្លួន ។ បើគ្មានសិទ្ធិជ្រើសរើសទេនោះ យើងពុំអាចធ្វើការសម្រេចចិត្តដែលនឹងជួយយើងឲ្យសម្រេចបានសក្ដានុពលដ៏ពេញលេញរបស់យើងឡើយ ។ ដូចជាអ្វីៗផ្សេងទៀតនៅក្នុងដំណឹងល្អ ការរីកចម្រើនកើតឡើង « មួយបន្ទាត់ម្ដងៗ មួយសិក្ខាបទម្ដងៗ » ( នីហ្វៃទី ២ ២៨:៣០ ) ។ ព្រះសព្វព្រះទ័យឲ្យយើងក្លាយជាមនុស្សមានការរៀបចំ ពុំមែនជាមនុស្សខ្លាចមិនហ៊ានអនុវត្តនោះទេ ហើយទ្រង់រំពឹងឲ្យយើងប្រើប្រាស់សិទ្ធិជ្រើសរើសរបស់យើងដើម្បីរស់នៅឲ្យបានល្អបំផុតតាមដែលយើងអាចធ្វើបាន ។

ពេលយើងរៀនស្វែងរកតុល្យភាពរវាងសិទ្ធិជ្រើសរើស និងវិវរណៈហើយ នោះយើងអាចដកពិសោធន៍ការរីកចម្រើនខាងវិញ្ញាណយ៉ាងពិតប្រាកដ ។ នេះគឺជាអ្វីដែលបានកើតឡើងចំពោះបងប្រុសយ៉ារេឌ ។ បន្ទាប់ពីគិតអំពីរឿងនោះមក លោកបានធ្វើការរំលាយក្រួស ១៦ ដុំ ចេញពីថ្ម ហើយសូមឲ្យព្រះពាល់ក្រួសទាំងនោះ ហើយធ្វើឲ្យវាមានពន្លឺឡើង ( សូមមើល អេធើរ ៣:១–៥ ) ។ លើកនេះ ពេលព្រះបានឆ្លើយតប អ្វីៗគ្រប់យ៉ាងបានផ្លាស់ប្ដូរ ។ ជាជាងការឮសំឡេងរបស់ព្រះនៅលើពពក បងប្រុសយ៉ារេឌបាន *ឃើញ* ព្រះអម្ចាស់ដោយផ្ទាល់ ដែលពុំគ្រាន់តែបង្ហាញព្រះកាយទ្រង់ប៉ុណ្ណោះទេ ទ្រង់ថែមទាំងបង្ហាញបងប្រុសយ៉ារេឌនូវការនិមិត្តដ៏អស្ចារ្យអំពីពិភពលោក និងអ្វីៗគ្រប់យ៉ាងដែលនឹងកើតឡើង ( សូមមើល អេធើរ ៣:៦–២៦ ) ។ វាអាចថាបងប្រុសយ៉ារេឌពុំបានរៀបចំខ្លួនខាងវិញ្ញាណដើម្បីទទួលការនិមិត្តនោះឡើយ ប្រសិនបើលោកពុំបានទទួលបទពិសោធន៍នៃការរីកចម្រើនផ្ទាល់ខ្លួនជាមុនដំបូងសិន ដែលកើតមកពីការសម្រេចចិត្តផ្ទាល់ខ្លួនលោកនោះ ។

ពេលយើងធ្វើការសម្រេចចិត្ត យើងត្រូវប្រាកដថា ធ្វើតាមការទន្មានរបស់អាលម៉ាឲ្យ « ប្រឹក្សាជាមួយនឹងព្រះអម្ចាស់នូវគ្រប់កិច្ចការ [ របស់យើង ] ( អាលម៉ា ៣៧:៣៧ ) ។ ពេលព្រះអម្ចាស់ត្រូវការយើងឲ្យធ្វើការសម្រេចចិត្តជាក់លាក់មួយ ទ្រង់នឹងអនុញ្ញាតឲ្យយើងដឹង និងជួយរារាំងយើងពីការវង្វេងផ្លូវ ។ ប៉ុន្តែយើងក៏ត្រូវរៀបចំខ្លួនដើម្បីឈរយ៉ាងរឹងប៉ឹង ហើយបន្ដឆ្ពោះទៅមុខដោយសេចក្ដីជំនឿ ទោះបីមាន ឬគ្មានចម្លើយកើតឡើងក្ដី ។ ដរាបណាយើងរក្សាសេចក្ដីសញ្ញារបស់យើង ហើយបន្តនៅស្មោះត្រង់ចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលអារម្មណ៍នៃទំនុកចិត្តក្នុងការសម្រេចចិត្តដ៏សុចរិតរបស់យើង និងភាពសុខសាន្តដែលព្រះអម្ចាស់សព្វព្រះទ័យជាមួយនឹងកិច្ចខិតខំរបស់យើង ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋយូថាហ៍ ស.រ.អ. ។*



# ការធ្វើឲ្យវាក្លាយជាវិវរណៈផ្ទាល់ខ្លួន

តើអ្នកស្គាល់ពីភាពខុសគ្នារវាងវិវរណៈ និងគំនិតផ្ទាល់ខ្លួនរបស់អ្នកដែរឬទេ ?



យើងរស់នៅក្នុងពិភពមួយនៃឱកាសជាច្រើន ។ យើងមានសេរីភាពដើម្បីជ្រើសរើសមុខរបរ សាលារៀន ស្វាមី ឬភរិយា កន្លែងផ្ទាល់ខ្លួនយើងដែលយើងចង់រស់នៅ និងអ្វីៗជាច្រើនទៀត ។ វាពិតជាពរជ័យក្នុងជំនាន់របស់យើង ។ ប៉ុន្តែម្យ៉ាងវិញទៀត វាធ្វើឲ្យការជ្រើសរើសទាំងនេះកាន់តែពិបាក ដោយសារវាពិបាកដើម្បីធ្វើការសម្រេចចិត្ត ពេលមានផ្លូវ និងឱកាសជាច្រើនដែលនឹងដឹកនាំយើងទៅរករឿងល្អៗ ។ តើយើងជ្រើសរើសត្រឹមត្រូវដូចម្ដេច ពេលមានឱកាសជាច្រើនដែលល្អៗនោះ ? ពេលអ្នកមានអារម្មណ៍ថា វង្វេង ឬភាន់ច្រឡំនៅក្នុងការសម្រេចចិត្តនានា សូមដឹងថា ព្រះវរបិតាសួគ៌សព្វព្រះទ័យដឹកនាំអ្នក ។ អ្នកអាចជ្រើសរើសផ្លូវត្រឹមត្រូវ ហើយទទួលចម្លើយដែលអ្នកកំពុងស្វែងរក ប្រសិនបើអ្នកធ្វើតាមសំឡេងទ្រង់ ។ ចូរទទួលស្គាល់របៀបដែលទ្រង់មានបន្ទូលមកកាន់អ្នក ចូរទុកចិត្តទ្រង់ ចូរធ្វើតាមព្យាការី ចូរមានចិត្តអត់ធ្មត់ ចូរមានភាពសុទិដ្ឋិនិយម និងមានសេចក្ដីជំនឿ ហើយទីបំផុតអ្នកនឹងត្រូវបានដឹកនាំទៅរកទិសដៅត្រឹមត្រូវ ។

*—វីរ៉ា វ៉ាស្សឆិនកូ ទីក្រុង គីអីវ ប្រទេសអ៊ុយក្រែន*

ពេញមួយជីវិតខ្ញុំ ខ្ញុំបានឃើញរបៀបដែលព្រះអម្ចាស់បានដឹកនាំខ្ញុំ ហើយខ្ញុំទទួលស្គាល់ថា អ្វីៗទាំងអស់ដែលខ្ញុំសម្រេចបានគឺដោយសារទ្រង់ និងការណែនាំរបស់ទ្រង់ ។ ទោះបីនៅក្នុងគ្រាដែលខ្ញុំគិតថា ខ្ញុំដើរតែឯងក្ដី នៅទីបំផុត ទ្រង់បានអនុញ្ញាតឲ្យខ្ញុំដឹង ហើយទទួលអារម្មណ៍ថា ទ្រង់គង់នៅទីនោះជាមួយខ្ញុំជានិច្ច ។ នោះជាមូលហេតុដែលខ្ញុំបានធ្វើការសម្រេចចិត្តដើម្បីបន្តឆ្ពោះទៅមុខដោយសេចក្ដីជំនឿជានិច្ច ទោះបីពេលខ្ញុំមានអារម្មណ៍ថា ខ្ញុំធ្វើកិច្ចការនោះតែឯងក្ដី ។ សម្រាប់ខ្ញុំ ផ្លូវរបស់ខ្ញុំពុំច្បាស់លាស់ជានិច្ចនោះទេ ហើយខ្ញុំពុំអាចឃើញអ្វីដែលទន្ទឹងរង់ចាំខ្ញុំនាពេលអនាគតឡើយ ប៉ុន្តែខ្ញុំបោះជំហានទៅមុខដោយសេចក្ដីជំនឿជានិច្ច ហើយបន្ទាប់មក ខ្ញុំបានចាប់ផ្ដើមឃើញពន្លឺ ហើយទទួលស្គាល់ព្រះចេស្ដារបស់ព្រះនៅក្នុងជីវិតខ្ញុំ ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌របស់យើង និងព្រះបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទស្រឡាញ់ពួកយើង ហើយពួកទ្រង់មានព្រះទ័យដឹកនាំយើង ប៉ុន្តែពួកទ្រង់ក៏រំពឹងឲ្យយើងដាក់សេចក្ដីជំនឿរបស់យើងលើពួកទ្រង់ ហើយធ្វើសកម្មភាព ពេលយើងទទួលការបំផុសគំនិតពីព្រះវិញ្ញាណ ។

*—អ៊ីនហីរ៉ា មេចាយ សាធារណរដ្ឋ ដូមីនីហ្កែន*

រូបភាពដោយ ប្រាយអិន ឃើស្ស៊ិនីក



**នៅ**ក្នុងគ្រួសារតូចរបស់យើង យើងទទួលស្គាល់ព្រះវិញ្ញាណដោយសារភាពសុខសាន្តដែលយើងទទួល ជាពិសេសស្វាមីរបស់ខ្ញុំ និងខ្ញុំរួមគ្នាក្នុងនាមជាគូស្វាមីភរិយា ។ ពេលវាជាគំនិតផ្ទាល់របស់យើង យើងពុំមានអារម្មណ៍ថា វាជារឿងត្រឹមត្រូវទាំងស្រុងទេ—វាមានការសង្ស័យ ឬភាពភ័យខ្លាចជានិច្ច ។ ប៉ុន្តែនៅពេលវាជាវិវរណៈ យើងមានអារម្មណ៍សុខសាន្តជានិច្ច ទោះបើយើងព្យាយាមដោះសារ ហើយអ្វីៗហាក់ដូចជាពុំយល់ច្រើននាគ្រាដំបូងក្តី ។ ពេលយើងធ្វើតាមវិវរណៈដោយជោគជ័យ នោះយើងឃើញអ្វីៗរីកចម្រើនយ៉ាងរលូន ហើយអ្វីៗគ្រប់យ៉ាងដំណើរការល្អជានិច្ច ។ នោះជាពេលដែលយើងមើលមុខគ្នា ហើយនិយាយថា « អ៊ូ ឥឡូវនេះយើងយល់ហើយ ! »

*—ម៉ារីយ៉ាណា រដ្ឋយូថាហ៍ ស.រ.អា.*

**ខ្ញុំ**គិតថា ក្បួនដ៏អស្ចារ្យបំផុតមួយដែលយើងត្រូវចេះឲ្យស្ទាត់នោះគឺ សមត្ថភាពដើម្បីទទួលស្គាល់ការខ្សឹបប្រាប់ដ៏ស្រទន់ពីព្រះវិញ្ញាណបរិសុទ្ធ ។ ការសិក្សាព្រះគម្ពីរដោយព្យាយាមបានជំរុញខ្ញុំឲ្យចេះស្ទាត់ក្នុងរឿងនេះ ។ ខ្ញុំជឿជានិច្ចថា អ្នកដែលព្យាយាមរកដោយឧស្សាហ៍នឹងឃើញ ហើយការអាថ៌កំបាំងទាំងឡាយនៃព្រះនឹងបានបើកបង្ហាញដល់គេដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល នីហ្វៃទី ១ ១០:១៩ ) ។ ម្យ៉ាងវិញទៀត ប្រសិនបើខ្ញុំចង់ទទួលស្គាល់ព្រះវិញ្ញាណ នោះខ្ញុំពុំអាចបណ្ដោយខ្លួនខ្ញុំទៅក្នុងគំនិតឥតប្រយោជន៍ ឬកង្វល់នៃជីវិតប្រចាំថ្ងៃរបស់ខ្ញុំឡើយ ផ្ទុយទៅវិញ ខ្ញុំត្រូវចុះប្រឡូកការងារ ហើយបំភ្លេចខ្លួនរបស់ខ្ញុំ ។ នេះគឺជាគ្រាដែលខ្ញុំអាចនឹងទទួលស្គាល់ព្រះវិញ្ញាណ ដោយសារខ្ញុំត្រៀមខ្លួនសម្រាប់រឿងនោះ ! ដូចទៅនឹងកប៉ាល់ដែលមិនអាចធ្វើដំណើរដោយងាយស្រួលកាត់ព្យុះដែរ នោះយើងពុំអាចស្ដាប់ឮព្រះវិញ្ញាណឡើយ ប្រសិនបើយើងផ្ដោតទៅលើកង្វល់នៃជីវិតដែលហួសពីការគ្រប់គ្រងរបស់យើងនោះ ។

*—អែលម៉ាញូអែល ប៊ិនហ្វ្រេត ដកបី ទីក្រុងអាក្រា ប្រទេសហ្គាណា*



**ពេ**លខ្ញុំកាន់តែធំ នោះខ្ញុំត្រូវតែរៀនភាសានៃព្រះវិញ្ញាណ ។ ព្រះវិញ្ញាណមានបន្ទូលមកកាន់ខ្ញុំតាមរយៈគំនិតសាមញ្ញៗ ។ វាត្រូវការការអនុវត្តដើម្បីឲ្យវាស៊ាំ ប៉ុន្តែជាទូទៅព្រះវិញ្ញាណយាងមករកខ្ញុំនៅកន្លែងស្ងាត់ ដូចជាពេលខ្ញុំបើកឡានទៅធ្វើការជាដើម ។ ខ្ញុំដឹងថា វាពុំមែនជាគំនិតខ្ញុំទេដោយសារជារឿយៗ ព្រះវិញ្ញាណបានយាងចូលមកស្ទើរតែពេលខ្ញុំពុំបានគិតពីប្រធានបទផងនោះ ។

*—ក្លារីសា មៃ ថេលើរ រដ្ឋយូថាហ៍ ស. រ. អា.*

ទោះបីយើងទាំងអស់គ្នាអាចទទួលវិវរណៈផ្ទាល់ខ្លួនក្នុងរបៀបផ្សេងៗក្តី អ្វីមួយដែលឥតសង្ស័យពិតប្រាកដនោះគឺ ៖ ព្រះមានបន្ទូលមកកាន់យើងជារឿយៗ ។ យើងត្រូវមានឆន្ទៈខិតខំបង្កើតសមត្ថភាពយើង ដើម្បីទទួលស្គាល់ និងស្ដាប់សំឡេងរបស់ទ្រង់ ។ ដូចប្រធាន រ័សុល អិម ណិលសុន បានប្រឹក្សាថា ៖ « សូមអធិស្ឋាននៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទអំពីកង្វល់ ការភ័យខ្លាច ភាពទន់ខ្សោយរបស់បងប្អូន—ពិតណាស់ ជាបំណងប្រាថ្នានៅក្នុងដួងចិត្តរបស់អ្នក ។ បន្ទាប់មក ចូរស្ដាប់ ! សូមសរសេរគំនិតដែលកើតមានក្នុងគំនិតរបស់បងប្អូន ។ សូមកត់ត្រាអារម្មណ៍របស់បងប្អូន ហើយធ្វើសកម្មភាពតាមអ្វីដែលបងប្អូនត្រូវបានបំផុសគំនិតឲ្យធ្វើ ។ កាលអ្នកធ្វើដំណើរការនេះម្ដងហើយម្ដងទៀតរៀងរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំ បងប្អូននឹង ‹ រីកចម្រើននៅក្នុងគោលការណ៍នៃវិវរណៈ › » ( « Revelation for the Church, Revelation for Our Lives » *Liahona* ខែឧសភា ឆ្នាំ ២០១៨ ទំព័រ ៩៥ ) ។ ■





# គ្រាដំបូងពេលខ្ញុំទៅរៀនវិទ្យាល័យ

មានរឿងមួយដែលលំបាកសម្រាប់ខ្ញុំ ៖ ពេលត្រូវបានណែនាំនូវមុខវិជ្ជាថ្មីមួយ ខ្ញុំឃើញថា វាពិបាកយល់ណាស់ ។ ល្ងាចមួយ ខ្ញុំបានអធិស្ឋានទូលសូមព្រះវរបិតាសួគ៌ឲ្យជួយខ្ញុំយល់ ហើយយកឈ្នះលើឧបសគ្គនោះ ។ ខ្ញុំមានសេចក្ដីជំនឿ ហើយខ្ញុំអាចយល់បានប្រសើរឡើង ។ ចាប់តាំងពីនោះមក ការអធិស្ឋាន និងសេចក្ដីជំនឿបានក្លាយជាកិច្ចការដែលខ្ញុំត្រូវធ្វើនៅក្នុងសាលារៀន និងគ្រប់ទីកន្លែងដែលខ្ញុំទៅ ។

កាលទៅសាលារៀនក្នុងថ្នាក់ដែលមានក្មេងប្រុសគឺជាឧបសគ្គមួយ ដោយសារតែរឿងអសីលធម៌មួយចំនួនដែលពួកគេធ្វើ ។ ពេលរឿងនោះកើតឡើង ពាក្យសម្ដីរបស់ឪពុកម្ដាយខ្ញុំផុសក្នុងគំនិតខ្ញុំ ៖ « កុំធ្វើអ្វីដែលបណ្ដេញព្រះវិញ្ញាណចេញឆ្ងាយ » ។ ខ្ញុំមានអំណរគុណចំពោះម្ដាយខ្ញុំ ដែលរំឭកខ្ញុំឲ្យស្ដាប់តាមព្រះវិញ្ញាណបរិសុទ្ធជានិច្ច ។ ពេលយើងធ្វើអ្វីដែលត្រូវ ព្រះប្រទានពរដល់យើង ។

**យ៉ាមេ អេស** អាយុ ១៦ ឆ្នាំ ប្រទេសហ្គាណា

## យុវវ័យ

នៅក្នុងវគ្គនេះ



៥៤


៥២ ការស្វែងរកភាពសុខសាន្តសម្រាប់ខ្លួនឯង និងមនុស្សដទៃនៅក្នុងគ្រាលំបាក
ដោយ អាឡិច ហូហ្គី និង អាស្លែន ស្នែនឌើរ

៥៤ ជីវិតគឺដូចជាកីឡារត់ម៉ារ៉ាតុង
ដោយ សាលី ចនសុន អូដេកឃើក

៦០ សំណួរ និងចម្លើយ ៖ តើពររបស់លោកអយ្យកោអាចជួយខ្ញុំឲ្យធ្វើការសម្រេចចិត្តដោយរបៀបណា ?

៦២ សាកល្បងប្រពៃណីបុណ្យអ៊ីស្ទើរថ្មីៗមួយចំនួន
ដោយ ដេវីឌ ឌីកសុន

៦៤ ពាក្យចុងក្រោយ ៖ ការបង្ហាញដ៏អស្ចារ្យបំផុតអំពីសេចក្ដីស្រឡាញ់របស់ព្រះ
ដោយប្រធាន អិម រ័សុល បាឡឺដ




# ការស្វែងរកភាពសុខសាន្ត

ជួនកាលជីវិតមានភាពរឹករវ និងភាន់ច្រឡំ ។ អ្នកអាចបារម្ភអំពីបញ្ហាគ្រួសារ បញ្ហាសុខភាព បញ្ហានៅសាលារៀន ឬព្រឹត្តិការណ៍ច្របូកច្របល់រាប់មិនអស់នៅក្នុងពិភពលោកសព្វថ្ងៃនេះ ។ តើយើងអាចស្វែងរកភាពសុខសាន្តផ្ទាល់ខ្លួនក្នុងពិភពលោកដ៏ច្របូកច្របល់ដោយរបៀបណា ? ទោះបីការខ្វះភាពសុខសាន្តរបស់អ្នកកើតមកពីព្រឹត្តិការណ៍នានាហួសពីសមត្ថភាពដែលអ្នកអាចគ្រប់គ្រងបាន ឬកើតចេញពីអ្វីៗដែលអ្នកអាចជះឥទ្ធិពល និងផ្លាស់ប្ដូរបានក្ដី នេះគឺជាយោបល់មួយចំនួនដើម្បីជួយអ្នកឲ្យស្វែងរកភាពសុខសាន្តក្នុងចិត្តតាមរយៈព្រះយេស៊ូវគ្រីស្ទ ។

## របៀប ៤ យ៉ាងដើម្បីស្វែងរកភាពសុខសាន្តសម្រាប់ខ្លួនឯង

### ១. ផ្ដោតទៅលើភាពអស់កល្បជានិច្ច

វាពិបាកដើម្បីទទួលអារម្មណ៍នៃភាពសុខសាន្តពេលអ្នកផ្ដោតទៅលើក្ដីបារម្ភរយៈពេលខ្លី ។ ប៉ុន្តែប្រសិនបើអ្នកផ្ដោតទៅលើទស្សនដ៏ធំទូលាយគឺផែនការនៃសុភមង្គលរបស់ព្រះ នោះអ្នកអាចរកឃើញភាពសុខសាន្តនៅក្នុងការដឹងថា អ្វីដែលឈឺចាប់ក្នុងពេលនេះ វាមិននៅយូរអង្វែងឡើយ ។ ឧទាហរណ៍ ព្រះវិហារបរិសុទ្ធជួយយើងឲ្យផ្ដោតទៅលើភាពអស់កល្បជានិច្ច ។ ប្រធានហ្គរដុន ប៊ី. ហ៊ិងគ្លី ( ១៩១០–២០០៨ ) បានមានប្រសាសន៍ថា នៅក្នុងព្រះវិហារបរិសុទ្ធ « អ្នកនឹងស្គាល់ភាពសុខសាន្តដែលអ្នកនឹងមិនអាចរកឃើញនៅកន្លែងណាទៀតឡើយ » ។[១]

### ២. ចូរកុំបារម្ភនូវអ្វីដែលអ្នកពុំអាចគ្រប់គ្រងបាន

ពេលមានអ្វីមួយដែលអ្នកពុំអាចគ្រប់គ្រងបាន ដែលដកយកភាពសុខសាន្តរបស់យើង វាល្បួងយើងឲ្យមានអារម្មណ៍អស់សង្ឃឹម ឬខឹងសម្បារ ។ ប៉ុន្តែវាពុំជួយឡើយ ដែលយើងផ្ដោតលើរឿងដែលយើងពុំអាចផ្លាស់ប្ដូរបាននោះ ។ ផ្ទុយទៅវិញ សូមខិតជិតព្រះអង្គសង្គ្រោះ ដើម្បីស្វែងរកភាពសុខសាន្តក្នុងចិត្ត ទោះបីអ្នកមានអារម្មណ៍ថា ជីវិតនេះហាក់ដូចជាអយុត្តិធម៌ក្ដី ។ ទ្រង់បានសន្យាបញ្ជូនអង្គជាជំនួយមកគឺព្រះវិញ្ញាណបរិសុទ្ធ ( សូមមើល យ៉ូហាន ១៤:២៦–២៧ ) ។

### ៣. អភ័យទោសអ្នកដទៃ

ជារឿយៗ រឿងលំបាកបំផុតដើម្បីឈប់បារម្ភនោះគឺ ភាពអវិជ្ជមានដែលអ្នកទទួលពេលនរណាម្នាក់ធ្វើខុសនឹងអ្នក ។ ប៉ុន្តែ អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « យើងនឹងទទួលអំណោយនៃការអភ័យទោសនៅក្នុងជីវិតយើងផ្ទាល់ នៅពេលយើងកំពុងបង្ហាញនូវអំណោយនោះដោយសេរីដល់អ្នកដទៃ ។ . . . ជាលទ្ធផលព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងបំពេញព្រលឹងរបស់យើងដោយអំណរ ជាមួយនឹងភាពសុខសាន្តនៃសតិសម្បជញ្ញៈមកពីព្រះ ( សូមមើល ម៉ូសាយ ៤:២–៣ ) » ។[២] ការងាកបែរទៅរកព្រះអង្គសង្គ្រោះអាចជួយអ្នកមានអារម្មណ៍រួចពីបន្ទុកផ្លូវចិត្ត ហើយពោរពេញដោយភាពសុខសាន្ត ។

### ៤. ប្រែចិត្ត ហើយពឹងផ្អែកលើព្រះគ្រីស្ទ

មិនថាមានអ្វីផ្សេងទៀតដំណើរការល្អនៅក្នុងជីវិតរបស់អ្នកទេ ការរែកបន្ទុកនៃអំពើបាបនឹងប្លន់ភាពសុខសាន្តពីអ្នកជានិច្ច ។ ជួនកាលយើងត្រូវការប៊ីស្សពរបស់យើងជួយយើងឲ្យប្រែចិត្តពេញលេញទាំងស្រុង ។ ប៉ុន្តែយើងទាំងអស់គ្នាត្រូវប្រែចិត្តជាទៀងទាត់តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយប្រែជាស្អាតស្អំនូវរឿងគ្រប់យ៉ាងដែលរារាំងយើងពីការប្រែកាន់តែដូចទ្រង់ ។





# សម្រាប់ខ្លួនឯង និងមនុស្សដទៃនៅក្នុងគ្រាលំបាក

ដោយ អាឡិច ហូហ្គី និង អាស្លែន ស្នែនឌើរ
ទស្សនាវដ្ដីសាសនាចក្រ

***នេះគឺជារបៀបប្រាំបីយ៉ាងដើម្បីជួយអ្នក និងមនុស្សដទៃឲ្យទទួលអារម្មណ៍សុខសាន្ត ពេលជីវិតជួបការលំបាក ។***



រូបភាពនៅផ្ទៃខាងក្រោយ និងរូបថតមកពី GETTY IMAGES

## របៀប ៤ យ៉ាងដើម្បីជួយមនុស្សដទៃស្វែងរកភាពសុខសាន្ត

### ១. ចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ

ដូចជាយើងអាចស្វែងរកភាពសុខសាន្តសម្រាប់ខ្លួនឯង ដោយផ្ដោតលើព្រះអង្គសង្គ្រោះ នោះយើងអាចចង្អុលបង្ហាញមនុស្សដទៃឲ្យទៅកាន់ទ្រង់ ថាទ្រង់ជា « ម្ចាស់នៃសេចក្ដីសុខសាន្ត » ( ម៉ូសាយ ១៥:១៨ ) ។ ឧទាហរណ៍ សូមព្យាយាមចែកចាយបទគម្ពីរ ឬពាក្យដកស្រង់មួយមកពីសន្និសីទទូទៅ ដែលជួយអ្នករៀនបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។

### ២. ចូរធ្វើជាអ្នកផ្សះផ្សាគេ

សូមជួយមិត្តភក្តិ ឬបងប្អូនបង្កើតរបស់អ្នកដោះស្រាយជម្លោះ ។ ដូចជាពួកសាសន៍ អាន់តៃ នីហ្វៃ លីហៃ ក្នុងគម្ពីរអាលម៉ា នោះយើងអាចកប់អាវុធពិជ័យសង្គ្រាមរបស់យើង—អាវុធនានាដូចជា ការនិយាយដើមគេ, ការស្វែងរកការសងសឹក ឬភាពអាត្មានិយម—ហើយដូរវាយកឧបករណ៍នានានៃភាពសុខសាន្ត ៖ គឺការនិយាយដោយក្ដីសប្បុរស ការគោរពបទបញ្ញត្តិព្រះ និងការអត់ទោសឲ្យមនុស្សដទៃ ( សូមមើល អាលម៉ា ២៤:១៩ ) ។

### ៣. ចូរធ្វើជាអ្នកស្ដាប់ល្អម្នាក់

ជួនកាលមនុស្សដែលកំពុងជួបការលំបាកត្រូវតែនិយាយបើកចំហរអំពីគំនិត និងអារម្មណ៍របស់ពួកគេ ជំនួសឲ្យទុកវានៅក្នុងចិត្ត ។ យើងពុំមែនដោះស្រាយបញ្ហាឲ្យពួកគេទេ ប៉ុន្តែយើងអាចស្ដាប់យ៉ាងសាមញ្ញនូវកង្វល់របស់ពួកគេ ហើយផ្ដល់ការគាំទ្រ បង្ហាញសេចក្ដីស្រឡាញ់ និងការយល់ចិត្តដូចជាព្រះយេស៊ូវគ្រីស្ទ ។

### ៤. ផ្ដល់ការងារបម្រើដល់អស់អ្នកដែលនៅក្នុងវួដ និងសហគមន៍របស់អ្នក

អ្នកអាចស្ម័គ្រចិត្តធ្វើការនៅការិយាល័យអ្នកគ្មានផ្ទះសម្បែង ធ្វើជាមិត្តអប់រំមិត្ត ឬយកនំទៅឲ្យគ្រួសារថ្មីមួយនៅជិតខាងអ្នក ។ ជួយមនុស្សឲ្យរកឃើញភាពសុខសាន្តនៅក្នុងកិច្ចការតូចតាច ។ ការមានកន្លែងមួយជាប់លាប់ដើម្បីបរិភោគ និងស្នាក់នៅ ធ្វើជាអ្នកផ្ដល់ប្រឹក្សាដែលអាចទុកចិត្តបាន ឬការបញ្ជាក់តូចមួយដែលថា ការយកចិត្តទុកដាក់របស់បុគ្គលម្នាក់អាចជះឥទ្ធិពលដ៏ខ្លាំង ។

ព្រះយេស៊ូវបានមានបន្ទូលនូវពាក្យលួងលោមទាំងនេះដល់អស់អ្នកដែលពុះពារស្វែងរកភាពសុខសាន្តថា ៖ « ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកីយ៍ឲ្យទេ ។ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ » ( យ៉ូហាន ១៤:២៧ ) ។ ប្រសិនបើយើងនាំខ្លួនយើង និងមនុស្សដទៃខិតកាន់តែជិតព្រះយេស៊ូវគ្រីស្ទ នោះយើងអាចរកឃើញភាពសុខសាន្ត ទោះបីពេលជីវិតជួបការលំបាកក្ដី ។ ■

កំណត់ចំណាំ
1. ហ្គរដុន ប៊ី ហ៊ិងគ្លី នៅក្នុង « Rejoice in the Blessings of the Temple » *Liahona* ខែ ធ្នូ ឆ្នាំ ២០០២ ទំព័រ ៣៣ ។
2. ឌៀថើរ អេស្វ អុជដូហ្វ « Point of Safe Return » *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១០១ ។



# ជីវិតគឺដូចជា កីឡារត់ម៉ា



# រ៉ាតុន

*ពួកបរិសុទ្ធយុវវ័យថ្ងៃចុងក្រោយទាំងនេះរស់នៅសព្វថ្ងៃនេះ នៅកន្លែងដែលសាវកប៉ុលបានរស់នៅអំឡុងគ្រាព្រះគម្ពីរសញ្ញាថ្មី ។ ហើយពួកគេបានរស់នៅតាមការបង្រៀនរបស់លោក ។*

**ដោយ សាលី ចនសុន អូដេកយើក**
ទស្សនាវដ្ដីសាសនាចក្រ

ពីរបីខែកន្លងទៅ សិស្សថ្នាក់សិក្ខាសាលាមួយបានជួបគ្នានៅកូនភ្នំអើរីយ៉ូស ក្បែរទីក្រុងអាតែន ប្រទេសក្រិក ជាកន្លែងដែលសាវកប៉ុលបានថ្លែងការបង្រៀនដ៏មានឥទ្ធិពលមួយ ( សូមមើល កិច្ចការ ១៧:២២–៣៤ ) ។ ពួកសិស្សបាននិយាយគ្នាអំពីឥទ្ធិពលនៃថ្នាក់សិក្ខាសាលាមាននៅក្នុងជីវិតពួកគេ រួមទាំងការបង្រៀនរបស់ប៉ុលផងដែរ ។

អាឡិចសីស អេច អាយុ ១៨ ឆ្នាំ និយាយថា « ការរស់នៅក្នុងប្រទេសក្រិកធ្វើឲ្យព្រះគម្ពីរសញ្ញាថ្មីមានភាពរស់រវើកឡើង ។ ឪពុករបស់ខ្ញុំចូលចិត្តទៅកន្លែងបាក់បែកនានាដែលប៉ុលបានបង្រៀន ហើយគាត់នឹងចែកចាយខគម្ពីរ ឬប្រាប់ពួកយើងអំពីរឿងមួយស្ដីពីកន្លែងដែលព្រឹត្តិការណ៍នោះបានកើតឡើង » ។

ដូចប៉ុលបានប្រឈមមុខនឹងឧបសគ្គនៅក្នុងជំនាន់លោកដែរ នោះពួកយុវវ័យនៅក្នុងប្រទេសក្រិកក៏ជួបនឹងបញ្ហាសង្គមនយោបាយ និងសេដ្ឋកិច្ចផងដែរ ។ សន្និសីទយុវវ័យ និងការបោះជំរំក្រុមយុវនារីគឺជាព្រឹត្តិការណ៍កម្រមួយនៅក្នុងប្រទេសក្រិក ហើយការចូលរួមថ្នាក់សិក្ខាសាលាអាចជាការពិបាកផងដែរ ។ ទោះបីជាមានឧបសគ្គទាំងនេះ និងឧបសគ្គផ្សេងទៀតក្ដី ពួកយុវវ័យនៅក្នុងប្រទេសក្រិកបានអនុវត្តការលើកទឹកចិត្តរបស់ប៉ុល ដើម្បី « ឈរមាំមួនហើយព្រមទាំងមានចិត្តមានគំនិតតែមួយ ដើម្បីនឹងតតាំងជាមួយគ្នា ដោយនូវសេចក្ដីជំនឿ ខាងឯដំណឹងល្អផង » ( ភីលីព ១:២៧ ) ។

ការរស់នៅក្នុងប្រទេសក្រិកមានន័យថា សមាជិកវ័យក្មេងទាំងនេះមានឱកាសរីករាយនឹងអាកាសធាតុក្ដៅល្មម ឆ្នេរសមុទ្រ អាហារ និងការរាំ ។ ពួកគេក៏ចូលចិត្តជួបជុំគ្នាផងដែរ ។ ពេលពួកគេជួបគ្នាក្នុងថ្នាក់សិក្ខាសាលា និងសកម្មភាពសាខា នោះពួកគេមានសេចក្ដីជំនឿ និងមិត្តភាពកាន់តែរឹងមាំឡើង ។

**ថ្នាក់សិក្ខាសាលានៅលើភ្នំអើរីយ៉ូស**

នៅពេលថ្នាក់សិក្ខាសាលាបានចាប់ផ្ដើមនៅប្រទេសក្រិកពីរបីឆ្នាំកន្លងទៅ គឺមានសិស្សតែប្រាំនាក់ប៉ុណ្ណោះ ។ ពួកគេជួបគ្នាបីដងពេលព្រឹកក្នុងមួយសប្ដាហ៍ ដោយមានអ្នកខ្លះចូលរួមតាមវីដេអូ



« ខ្ញុំបានរៀនថា ដំណឹងល្អគឺដូចគ្នានៅគ្រប់ទីកន្លែង ។ ខ្ញុំបានរៀនផ្ដោតចិត្តទៅលើសេចក្ដីពិតនៃដំណឹងល្អ ហើយទទួលអារម្មណ៍ពីព្រះវិញ្ញាណ ជាជាងត្រូវបានបង្វែរអារម្មណ៍ដោយសារតែវប្បធម៌នៃការរស់នៅក្រៅប្រទេស »
—ប្រាយអាណា ដបុលយូ អាយុ ១៥ ឆ្នាំ ។



« ខ្ញុំបានសរសេរពាក្យ ចងចាំ នៅលើកញ្ចក់របស់ខ្ញុំ ដើម្បីចងចាំពីរឿងទាំងអស់ដែលបានកើតឡើងនៅឆ្នាំនេះ ៖ សន្និសីទដើម្បីកម្លាំងនៃយុវជន ការបោះជំរំរបស់ក្រុមយុវនារី ថ្នាក់សិក្ខាសាលា ។ វាជួយខ្ញុំឲ្យចងចាំពីកន្លែងដែលខ្ញុំបានចេញមក » ។
—ម៉ារី អេច អាយុ ១៧ ឆ្នាំ



« ខ្ញុំដឹងថា ពេលខ្ញុំទៅរៀនថ្នាក់សិក្ខាសាលា នោះខ្ញុំអាចទទួលអារម្មណ៍នៃការពេញចិត្តដែលដឹងថា ខ្ញុំកំពុងធ្វើអ្វីដែលខ្ញុំត្រូវធ្វើ ហើយខ្ញុំដឹងថា អ្វីៗគ្រប់យ៉ាងនឹងដំណើរការល្អ » ។
—លីស៊្សី ធី អាយុ ១៧ ឆ្នាំ



លូគៀ សី អាយុ ១៥ ឆ្នាំ បានថ្លែងទីបន្ទាល់របស់នាងជាលើកដំបូងនៅការបោះជំរំរបស់ក្រុមយុវនារី និងក្រោយមកទៀតពេលនាងទទួលបុណ្យជ្រមុជទឹក ។




ក្រុមថ្នាក់សិក្ខាសាលានៅខាងមុខសាលាប្រជុំអាថែន ។

រូបថតទទួលសិទ្ធិអនុញ្ញាតពី លើអាន ហោឌើ

សន្និសីទអិនធើរណែត ។ ពួកគេក៏ជួបគ្នានៅរសៀលថ្ងៃពុធផងដែរសម្រាប់ថ្នាក់សិក្ខាសាលា បន្ទាប់មកមានកម្មវិធីមួយ ។ ពួកគេបានជិតស្និទ្ធនឹងគ្នា ហើយពួកគេក្លាយជាពន្លឺដល់មិត្តភក្ដិរបស់ពួកគេ ដែលកត់សម្គាល់ឃើញគំរូរបស់ពួកគេ ។ ពេលមិត្តភក្ដិរបស់ពួកគេសួរសំណួរ នោះពួកយុវវ័យនាំពួកគេទៅថ្នាក់សិក្ខាសាលា និងសកម្មភាពម៉ូគឌល ។

យុវជនម្នាក់ឈ្មោះ ប៉ាឡូស ខេ អាយុ ១៥ ឆ្នាំនិយាយថា « ការទៅរៀនថ្នាក់សិក្ខាសាលាគឺជារបៀបមួយល្អដើម្បីចាប់ផ្ដើមថ្ងៃថ្មី និងជួយខ្ញុំឲ្យបន្តរឹងមាំ ។ វាជួយខ្ញុំឲ្យផ្ដោតលើការធ្វើជាគំរូដល់មនុស្សដទៃ ។ វាជួយខ្ញុំឲ្យចាប់ផ្ដើមថ្ងៃថ្មីដោយគិតអំពីព្រះយេស៊ូវគ្រីស្ទ » ។

ពេលយុវវ័យមានភាពរឹងមាំ និងមានសាមគ្គីភាពកើនឡើង នោះពរជ័យ និងឱកាសនានាបានកើតមានឡើង ។ ឧទាហរណ៍ ក្នុងឆ្នាំ ២០១៧ ពួកគេទទួលពរដើម្បីចូលរួមសន្និសីទយុវវ័យដ៏ធំមួយក្នុងតំបន់ គឺសន្និសីទដើម្បីកម្លាំងនៃយុវជន ។ ពួកយុវនារីក៏បានចូលរួមក្នុងការបោះជំរំរបស់ក្រុមយុវនារីដំបូងគេនៅក្នុងប្រទេសក្រិកផងដែរ ។ ជាលទ្ធផល ពួកគេបានស្និទ្ធស្នាលនឹងគ្នាកាន់តែខ្លាំងឡើង ហើយយុវនារីពីនាក់បានចូលជាសមាជិកសាសនាចក្រ ។

**សន្និសីទដើម្បីកម្លាំងនៃយុវជនអន្តរជាតិ**

សន្និសិទដែលបានប្រារព្ធធ្វើឡើងនៅ ប្រទេសអាល្លឺម៉ង់ បាននាំពួកបរិសុទ្ធយុវវ័យថ្ងៃចុងក្រោយមកពីទ្វីបអឺរ៉ុបមកជួបជុំគ្នា ។ យុវវ័យមកពីប្រទេសក្រិក និងស៊ីរ៉ុស បានធ្វើដំណើរចម្ងាយរាប់រយគីឡូម៉ែត្រ ហើយបទពិសោធន៍នៃសន្និសីទមានឥទ្ធិពលខ្លាំងលើពួកគេ ។ សម្រាប់ ម៉ាស៊្សីម៉ូស អេ អាយុ ១៤ ឆ្នាំ « រឿងដ៏គួរឲ្យចងចាំបំផុតនៅសន្និសីទដើម្បីកម្លាំងនៃយុវជនគឺពេលយើងចែកចាយទីបន្ទាល់របស់យើង ។ អ្នកចូលរួមទាំងអស់បានទទួលអារម្មណ៍ពីព្រះវិញ្ញាណ ហើយវាបានបំផុសគំនិតខ្ញុំឲ្យអភិវឌ្ឍនូវទីបន្ទាល់របស់ខ្ញុំផ្ទាល់ » ។

លូគៀ សី អាយុ ១៥ ឆ្នាំ បន្ថែមថា « នៅគ្រាដំបូងមានយុវវ័យតែបួននាក់ប៉ុណ្ណោះដែលគ្រោងទៅកម្មវិធីនោះ ប៉ុន្តែនៅទីបំផុត យើងមានយុវវ័យ ១៥ នាក់ចូលរួម—កំណត់ត្រាមួយសម្រាប់ប្រទេសក្រិក—រួមទាំងមិត្តភក្ដិ ៣ នាក់ដែលមិនមែនជាសមាជិកផងដែរ ។

វាពិតជាល្អណាស់ដើម្បីជួបគ្នានៅកន្លែងមួយដែលអ្នកមាននូវដំណឹងល្អដូចគ្នា ហើយអ្នកពុំមែនជាមនុស្សប្លែកពីគេ ។ ពួកយើងទាំងអស់គ្នានៅជាមួយគ្នា ហើយយើងទទួលអារម្មណ៍ពីព្រះវិញ្ញាណដូចគ្នា ។ រឿងទាំងនេះជួយដល់ខ្ញុំ » ។

ដេសៀណា អាយុ ១៦ និយាយថា « ឪពុកខ្ញុំពុំមែនជាសមាជិកទេ ហើយគាត់ពុំអនុញ្ញាតឲ្យខ្ញុំទៅសន្និសីទដើម្បីកម្លាំងនៃយុវជន ឬទទួលបុណ្យជ្រមុជទឹកឡើយ ។ ប៉ុន្តែក្រោយមកប្រធានសាខាបានតមអាហារសម្រាប់ខ្ញុំ ហើយលោកយាយខ្ញុំបាននិយាយរឿងនេះជាមួយឪពុកខ្ញុំ ។ បន្ទាប់មក ឪពុកខ្ញុំបាននិយាយថា ខ្ញុំអាចទៅសន្និសីទនោះបាន ! »

នៅសន្និសីទដើម្បីកម្លាំងនៃយុវជន ដេសៀណាបានទទួលបទពិសោធន៍ដំបូងៗជាច្រើនដូចជា « ការចូលរួមក្នុងមេរៀន និងសកម្មភាព ព្រមទាំងការថ្លែងទីបន្ទាល់របស់ខ្ញុំបានជួយខ្ញុំឲ្យយល់ថា តើការទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធមានសភាពបែបណា ។ ខ្ញុំពុំធ្លាប់ទទួលអារម្មណ៍ពីព្រះវិញ្ញាណ

ដូចនេះពីមុនឡើយ ហើយខ្ញុំពិតជារីករាយ និងរំភើបចិត្តខ្លាំងណាស់ ។ ខ្ញុំបានថ្លែងទីបន្ទាល់របស់ខ្ញុំជាលើកដំបូង » ។

បន្ថែមពីលើការទទួលបានអាហារខាងវិញ្ញាណ នោះពួកយុវជនអាចសម្រាកលំហែកាយ ហើយមានភាពរីករាយជាមួយគ្នានៅក្នុងសន្និសីទនោះ ។ ហាហ្គ ធី អាយុ ១៤ ឆ្នាំមកពីប្រទេសស៊ីរ៉ុសបានមកចូលរួមសន្និសីទនេះផងដែរ ។ « ខ្ញុំបានរៀនដើម្បីមានទំនាក់ទំនងក្នុងសង្គមកាន់តែច្រើន រៀនដើម្បីមានមិត្តភាពពិតប្រាកដ និងមានភាពរីករាយ ទោះបីនៅក្នុងគ្រាលំបាកក្តី » ។

**ការបោះជំរំរបស់ក្រុមយុវនារី**

ការបោះជំរំរបស់ក្រុមយុវនារីក៏មានឥទ្ធិពលស្រដៀងគ្នានេះផងដែរ ។ យុវនារីដប់ពីរនាក់បានជួបជាមួយថ្នាក់ដឹកនាំរបស់ពួកគេនៅក្បែរទីលានប្រកួតម៉ារ៉ាតុនពីបុរាណកាលមួយ ។ ពួកគេបានចំណាយពេលបីថ្ងៃជាមួយគ្នា ដោយរៀនពឹងផ្អែកគ្នាទៅលើផ្នែកកម្លាំង និងការលើកទឹកចិត្ត ។

លូគៀនិយាយថា « កាលខ្ញុំអាយុ ១២ ឆ្នាំ ខ្ញុំបានទៅព្រះវិហារជាលើកដំបូង ហើយខ្ញុំសប្បាយចិត្តណាស់ ប៉ុន្តែក្រោយមក ខ្ញុំបានដឹងថា អ្នកដែលមានអាយុ ១២ ឆ្នាំគឺមានតែខ្ញុំម្នាក់ឯងប៉ុណ្ណោះ ។ ពីរឆ្នាំក្រោយមក យើងមានយុវនារីជាច្រើនដែលពួកយើងអាចបោះជំរំរបស់ក្រុមយុវនារីជាលើកដំបូង » ។ ពេលពួកគេជួបជុំគ្នា លូគៀនិយាយថា « ខ្ញុំបានស្គាល់ពីអត្ថន័យនៃការក្លាយជាពួកបរិសុទ្ធថ្ងៃចុងក្រោយហើយ ។ ពេលយើងរស់នៅតាមដំណឹងល្អ នោះមានពន្លឺមួយដែលហ៊ុមព័ទ្ធយើង » ។

សម្រាប់ ប្រាយអាណា ដបុលយូ អាយុ ១៥ ឆ្នាំ សន្និសីទដើម្បីកម្លាំងនៃយុវជន និងការបោះជំរំរបស់ក្រុមយុវនារី បានជួយនាងបើកដួងចិត្ត ហើយនិយាយជាមួយមនុស្សដទៃ ។ នាងនិយាយថា « ជារឿយៗគ្រួសារខ្ញុំប្តូរទីលំនៅ ហើយ



*« ផ្នែកដែលខ្ញុំចូលចិត្តនៅក្នុងសន្និសីទដើម្បីកម្លាំងនៃយុវជនគឺ កីឡា ការរាំ និងការប្រជុំក្រុមគឺជាការប្រជុំធម្មនិដ្ឋាន និងការរំឭកឡើងវិញនៅពេលព្រឹក ។ វាជួយខ្ញុំឲ្យក្លាយជាមនុស្សកាន់តែមានប្រយោជន៍ និងអត់ធ្មត់ ហើយមានអំណរគុណចំពោះព្រះគម្ពីរកាន់តែច្រើនឡើង » ។*
**—ហាហ្គ ធី អាយុ ១៤ ឆ្នាំ**



នៅតាមផ្លូវទៅសន្និសីទដើម្បីកម្លាំងនៃយុវជននៅទីក្រុងស្តុតហ្គាត ប្រទេសអាល្លឺម៉ង់ ។



នៅសន្និសីទដើម្បីកម្លាំងនៃយុវជន ការប្រកបពាក្យ « ចូរសូម » មកពីយ៉ាកុប ១:៥ ។

« ឈរមាំមួនហើយព្រមទាំងមានចិត្តមានគំនិតតែមួយ »

ភីលីព ១:២៧





អ៊ីរីនី អេស សម្តែងនៅសន្និសីទដើម្បីកម្លាំងនៃយុវជន ។



*« នៅសន្និសីទដើម្បីកម្លាំងនៃយុវជន យើងបានចាប់ផ្តើមក្រុមមួយ ហើយវាបានពង្រឹងពួកយើង ។ វាបានជួយសម្រួចសម្រាំង និងជះឥទ្ធិពលដល់កម្មវិធីយុវវ័យនៅក្នុងប្រទេសក្រិក ដោយសារឥឡូវនេះយើងស្គាល់គ្នាបានច្បាស់ជាងមុន » ។*
**—អាឡិចស៊ីស អេច អាយុ ១៨ ឆ្នាំ**



*« ការច្រៀងនៅលើវេទិកាក្នុងសន្និសីទដើម្បីកម្លាំងនៃយុវជនគឺជារឿងមួយដ៏ក្លាហានបំផុតដែលខ្ញុំធ្លាប់ធ្វើ ហើយគឺជាគ្រាដ៏ពិសេសបំផុតដែលខ្ញុំធ្លាប់មាន ។ នៅគ្រានោះ ខ្ញុំបានរៀនថា យើងមានសារៈសំខាន់ខ្លាំងប៉ុណ្ណានៅក្នុងពិភពលោកដ៏ស្រស់ស្អាតនេះ » ។*
**—អ៊ីរីនី អេស អាយុ ១៧ ឆ្នាំ**



*« នៅឯការបោះជំរំរបស់ក្រុមយុវនារី ខ្ញុំបានរៀនថា ជីវិតនេះគឺដូចជាកីឡារត់ម៉ារ៉ាតុន ។ វាជួយខ្ញុំបង្កើនសេចក្ដីជំនឿខ្ញុំ ដោយសារដឹងថា យើងត្រូវបន្តដើរលើផ្លូវត្រូវ គឺដូចជាយើងកំពុងរត់កីឡាម៉ារ៉ាតុនដែរ ។ បទពិសោធន៍នោះជួយខ្ញុំបង្កើនទីបន្ទាល់របស់ខ្ញុំហើយបន្តមានសេចក្ដីជំនឿព្រមទាំងបន្តនៅលើផ្លូវត្រូវ » ។*
—វីនីហ្វ្រីក ខេ អាយុ ១៤ ឆ្នាំ

# « ជីវិតគឺជាកីឡារត់ម៉ារ៉ាតុន ពុំមែនជាការរត់ប្រណាំងទេ » ។

បាវចនាការបោះជំរំក្រុមយុវនារី



*ក្រុមយុវនារីនៅទីក្រុងម៉ារ៉ាតុងប្រទេសក្រិក ។*




*« យើងទាំងអស់គ្នាពិសេសណាស់ គឺដូចជាគ្រួសនៅលើឆ្នេរសមុទ្រដែលមានលក្ខណៈពិសេសរៀងៗខ្លួនផងដែរ » ។*
—ប្រាយអាណា ដបុលយូ



*« ការមើលព្រះអាទិត្យរះនាំឲ្យមានចិត្តស្ងប់ វិញ្ញាណស្រស់ស្រាយ » ។* —លីស៊ី ធី

ខ្ញុំពិបាកនឹងមានទំនាក់ទំនងជាមួយមនុស្សដទៃ ដោយសារខ្ញុំអៀន ។ ប៉ុន្តែដោយសារខ្ញុំមានភាពជិតស្និទ្ធជាមួយក្រុមរបស់យើងនៅសន្និសីទដើម្បីកម្លាំងនៃយុវជន នោះខ្ញុំបានរាប់អានមិត្តល្អៗមួយចំនួន ។ អំឡុងពេលការប្រជុំថ្លែងទីបន្ទាល់ យើងបានចែកចាយអារម្មណ៍យើង ហើយខ្ញុំដឹងថា មនុស្សផ្សេងទៀតក៏ទទួលអារម្មណ៍ដែលខ្ញុំបានទទួលផងដែរ » ។

ម៉ារី អេច អាយុ ១៧ ឆ្នាំ ចាំពីបាវចនាការបោះជំរំនោះគឺ « ជីវិតគឺជាកីឡារត់ម៉ារ៉ាតុន ពុំមែនជាការរត់ប្រណាំងទេ » ។ នាងនិយាយថា ពួកយុវនារី និងថ្នាក់ដឹកនាំរបស់ពួកគេបានពិភាក្សាអំពីសារៈសំខាន់នៃការស៊ូទ្រាំ និងការបញ្ចប់ការប្រកួតនោះ ។ « វារំឭកខ្ញុំថា ខ្ញុំអាចស៊ូទ្រាំបាន កំណត់ល្បឿនរត់របស់ខ្ញុំហើយបន្តផ្ដោតចិត្តលើទីផ្ដាច់ព្រ័ត្ត ។ នោះខ្ញុំអាចសម្រេចបាននូវកិច្ចការដែលព្រះវរបិតាសួគ៌ត្រូវការឲ្យខ្ញុំធ្វើ » ។

ផ្នែកដ៏ល្អបំផុតមួយនៃការបោះជំរំនោះគឺ ការប្រជុំធម្មនិដ្ឋានពេលព្រះអាទិត្យរះនៅឆ្នេរសមុទ្រនៅព្រឹកថ្ងៃចុងក្រោយនៃការបោះជំរំនោះ ។ លីស៊ី ធី អាយុ ១៧ ឆ្នាំ និយាយថា « យើងបានយកព្រះគម្ពីរយើង យើងមានការប្រជុំធម្មនិដ្ឋាន និងបានមើលព្រះអាទិត្យរះ ។ យើងទាំងអស់គ្នាទទួលអារម្មណ៍នៃក្ដីស្រឡាញ់របស់ព្រះ ។ យើងបានចំណាយពេលជាមួយគ្នាក្នុងកម្មវិធីនោះ តាំងពីដើមរហូតដល់ចប់ » ។

## ការប្រឈមមុខនឹងអនាគតដោយគ្មានភ័យខ្លាច

អ៊ីរីនី អេស អាយុ ១៧ ឆ្នាំ និយាយថា « សម្រាប់សន្និសីទដើម្បីកម្លាំងនៃយុវជន និងការបោះជំរំរបស់ក្រុមយុវនារី នោះខ្ញុំបានរៀនច្រើនអំពីដំណឹងល្អ និងរបៀបដែលដំណឹងល្អអាចជួយខ្ញុំក្នុងជីវិតខ្ញុំ ។ ខ្ញុំបានរាប់អានមិត្តភក្ដិជាច្រើននាក់ ហើយរៀនពីសារៈសំខាន់ដ៏អស្ចារ្យដើម្បីបង្ហាញគំនិត និងអារម្មណ៍របស់ខ្ញុំ ។ ខ្ញុំទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធយ៉ាងខ្លាំង និងទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គសង្គ្រោះរបស់យើងគឺព្រះយេស៊ូវគ្រីស្ទ » ។

នាងបាននិយាយថា ការនៅជាមួយពួកយុវវ័យបរិសុទ្ធថ្ងៃចុងក្រោយផ្សេងទៀត បានពង្រឹងទំនុកចិត្តរបស់នាង ។ ម៉ាណាសេ អេ អាយុ ១៧ និយាយថា « ពីមុនសន្និសីទដើម្បីកម្លាំងនៃយុវជន ខ្ញុំពុំអាចមើលឃើញពីអ្វីៗដ៏ល្អ និង



*ការបោះជំរំរបស់ក្រុមយុវនារីឆ្នាំ ២០១៧ – ការបោះជំរំដំបូងគេនៅក្នុងប្រទេសក្រិក ។*

ស្រស់ស្អាតដែលព្រះបានបង្កើតសម្រាប់យើង និងផែនការដែលទ្រង់កំពុងតែបង្កើតសម្រាប់យើងឡើយ ។

យើងពុំគួរទទួលឥទ្ធិពលពីនរណាម្នាក់ ឬអ្វីមួយផ្សេងទៀតដែលនៅជុំវិញយើង ដែលនឹងព្យាយាមទាញយើងចេញពីការរស់នៅតាមដំណឹងល្អឡើយ ។ ដំណឹងល្អគឺដូចគ្នានៅគ្រប់ទីកន្លែង ហើយយើងគួរតែបន្តនៅលើផ្លូវត្រឹមត្រូវ » ។

ហើយទោះបីយើងរស់នៅប្រទេសក្រិក ឬកន្លែងផ្សេងទៀតក្នុងពិភពលោកនេះ ការចែកចាយសេចក្ដីល្អនោះជាមួយគ្នាធ្វើឲ្យយើងមានភាពសាមគ្គីគ្នាក្នុងវិញ្ញាណ ។ ■

## សាសនាចក្រនៅក្នុងប្រទេសក្រិក



នៅដើមទសវត្សរ៍ឆ្នាំ ១៩០០ រីហ្គាស ប៉ូហ្វានទីស អ្នកបោះពុម្ពមកពីទីក្រុងអាថែន បានផ្ញើសំណើមួយទៅថ្នាក់ដឹកនាំនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដើម្បីបានព័ត៌មាន ។ ប្រធានបេសកកម្មរបស់សាសនាចក្រនៅប្រទេសធួកគី បានបង្រៀនប៉ូហ្វានទីស ហើយគាត់បានទទួលបុណ្យជ្រមុជទឹកនៅក្នុងខែតុលា ឆ្នាំ ១៩០៥ ។



សាសនាចក្របានរីកចម្រើនបន្តិចនៅក្នុងប្រទេសក្រិករហូតដល់ឆ្នាំ ១៩៥០ ពេលសមាជិកអាមេរិកកាំង-ក្រិក នៅទីក្រុង សលត៍ លេក រដ្ឋ យូថាហ៍ ស. រ. អា. បានរៀបចំសង្គមពួកបរិសុទ្ធថ្ងៃចុងក្រោយ ហេឡិននិក ដើម្បីបន្តមរតករបស់ពួកគេ និងរក្សាចំណងទំនាក់ទំនងជាមួយស្រុកកំណើតរបស់ពួកគេ ។



ថ្នាក់ដឹកនាំទាំងឡាយរបស់សាសនាចក្របានរៀបចំក្រុមជំនុំតូចមួយនៅទីក្រុងអាថែនក្នុងឆ្នាំ ១៩៦៥ ហើយបានរៀបចំវាសារជាថ្មីក្នុងឆ្នាំ ១៩៦៧ ។ ពួកគេបានបង្កើតបេសកកម្មអាថែនក្រិកនៅក្នុងខែ កក្កដា ឆ្នាំ ១៩៩០ ហើយបានបញ្ចប់ការសាងសង់សាលាប្រជុំដំបូងគេនៅប្រទេសក្រិកក្នុងខែ ឧសភា ឆ្នាំ ១៩៩៩ ។





*ទីក្រុងអាថែន ប្រទេសក្រិក សាលាប្រជុំនៅហាឡែនដ្រី*

**សមាជិកភាពរបស់សាសនាចក្រ ៖ ៨០២**

**ក្រុមជំនុំ ៖ ៣**

រូបតំណាងបុណ្យជ្រមុជទឹក និងព្រះវិហារ មកពី GETTY IMAGES



*« ខ្ញុំពិតជាចូលចិត្តមើលពីសោភ័ណ្ឌភាពនៃការនៅជាមួយពួកយុវវ័យដែលមានជំនឿដូចគ្នា ។ ខ្ញុំមានអារម្មណ៍ថា យើងទាំងអស់គ្នាមានទំនាក់ទំនងគ្នាក្នុងរបៀបពិសេសមួយ គឺពិសេសជាងការគ្រាន់តែស្គាល់ឈ្មោះគ្នាទៅទៀត » ។*

**—ប៉ាវលុស ខេ អាយុ ១៥ ឆ្នាំ**



*« ខ្ញុំរីករាយដែលខ្ញុំមានឱកាសជួបជាមួយយុវវ័យផ្សេងទៀត ដែលធ្វើកិច្ចការដូចគ្នាដែលខ្ញុំធ្វើរៀងរាល់ថ្ងៃ » ។*

**—យ៉ូស្វេ ខេ អាយុ ១៧ ឆ្នាំ**



*« សន្និសីទដើម្បីកម្លាំងនៃយុវជន និងការបោះជំរំរបស់ក្រុមយុវនារី ទទួលអារម្មណ៍ដូចគ្នា មិនថាអ្នកទៅណានៅក្នុងពិភពលោកនេះទេ ។ ខ្ញុំរីករាយនឹងការបោះជំរំរបស់ក្រុមយុវនារីតូចៗ ដោយសារវាងាយទាក់ទងគ្នាជាង » ។*

**—អូលីវៀ អេច អាយុ ១៥ ឆ្នាំ**



*« ខ្ញុំពុំមែនជាសមាជិកសាសនាចក្រទេ ប៉ុន្តែខ្ញុំមករៀនរាល់សប្ដាហ៍ដែលខ្ញុំអាចមកបាន ។ ខ្ញុំពេញចិត្តនឹងអ្វីដែលក្រុមយុវនារីឈរការពារ » ។*

**—អ៊ីរេនី ស៊ី អាយុ ១៤ ឆ្នាំ**



# « តើពររបស់លោកអយ្យកោអាចជួយខ្ញុំឲ្យធ្វើការសម្រេចចិត្តដោយរបៀបណា ? »

*« ពររបស់លោកអយ្យកោគឺជាវិវរណៈមួយដល់អ្នកទទួល វាគឺជាប្រភពមួយនៃការណែនាំពេញមួយជីវិតរបស់បុគ្គលម្នាក់ ដើម្បីការពារ បំផុសគំនិត និងជំរុញចិត្តឲ្យធ្វើសកម្មភាព និងសេចក្តីសុចរិត ។ ពររបស់លោកអយ្យកោពិតជាមានជំពូកនានាមកពីសៀវភៅរបស់អ្នកស្តីពីភាពអស់កល្បជានិច្ចនានាដែលអាចកើតមាន ។. . .*

*. . .វាគឺជាលីអាហូណានៃពន្លឺដើម្បីដឹកនាំអ្នកយ៉ាងត្រឹមត្រូវឆ្ពោះទៅផ្ទះសួគ៌របស់អ្នកវិញ » ។*

ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) « Your Patriarchal Blessing: A Liahona of Light » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៦៥, ៦៧ ។



**លីអាហូណាផ្ទាល់ខ្លួនរបស់យើង**

ពររបស់លោកអយ្យកោគឺជាមធ្យោបាយមួយ ដែលព្រះវរបិតាសួគ៌ជួយយើងឲ្យដឹងពីជីវិតមុនឆាកជីវិតនេះ ជីវិតរមែងស្លាប់ និងអត្តសញ្ញាណដ៏អស់កល្បជានិច្ចរបស់យើង ។ តាមរយៈការដឹងអំពីសេចក្តីពិតពិសេសទាំងបីនេះអំពីខ្លួនយើង នោះវាជួយយើងឲ្យធ្វើតាមផែនការព្រះដែលបានរៀបចំសម្រាប់យើង ។ យើងដឹងថា យើងជានរណា ហេតុអ្វីយើងនៅទីនេះ និងទីកន្លែងដែលយើងនឹងទៅ ។ ដូចជាលីអាហូណាដែលបានដំណើរការស្របតាមសេចក្តីជំនឿ និងភាពឧស្សាហ៍ព្យាយាមរបស់នីហ្វៃ និងគ្រួសារលោកក្នុងការធ្វើតាមការបង្ហាញរបស់វាដែរ ( សូមមើល នីហ្វៃទី ១ ១៦:២៨ ) នោះយើងក៏អាចមានចិត្តស្មោះត្រង់ និងឧស្សាហ៍ព្យាយាមក្នុងការធ្វើតាមលីអាហូណាផ្ទាល់ខ្លួនយើង និងការបង្ហាញរបស់វាដែលនឹងដឹកនាំយើងឲ្យឆ្ពោះទៅរកសក្តានុពលនៃភាពជាព្រះរបស់យើង ។

*អែលឌើរ យូថៃ អាយុ ២០ ឆ្នាំ បេសកកម្ម អាហ្សង់ទីន សាលតា*



**ទស្សនវិស័យអស់កល្បជានិច្ច**

ពេលណាដែលខ្ញុំមានអារម្មណ៍ថា គ្មានតម្រុយអ្វីសោះក្នុងការសម្រេចចិត្ត នោះខ្ញុំបើកពររបស់លោកអយ្យកោខ្ញុំ ហើយពិចារណាវិវរណៈមកពីព្រះនៅក្នុងនោះ ។ ហើយក្រោយមកការសម្រេចចិត្តគឺមានភាពងាយស្រួល ។ វាពុំគ្រាន់តែជួយខ្ញុំឲ្យស៊ូទ្រាំនឹងជីវិតលើផែនដីរបស់ខ្ញុំ និងទទួលបានពរជ័យដែលបានសន្យានោះទេ វាថែមទាំងរំឭកខ្ញុំអំពីការរៀបចំខ្លួនខ្ញុំ ឲ្យមានភាពស័ក្តិសមចូលនគររបស់ទ្រង់នៅថ្ងៃខាងមុខផងដែរ ។ វាជួយខ្ញុំឲ្យបន្តបង្កើនសេចក្តីជំនឿទុកចិត្តលើព្រះទ័យរបស់ព្រះអម្ចាស់ ហើយរស់នៅជាមួយទស្សនវិស័យអស់កល្បជានិច្ចមួយ ។

*អាបេហ្គែល អេហ្វ អាយុ ១៨ ឆ្នាំ ទីក្រុងកាហ្គាយ៉ាន វ៉ាលី ប្រទេសហ្វីលីពីន*



### ការទូន្មានសួគ៌ា

ពររបស់លោកអយ្យកោផ្ដល់ការទូន្មានពីព្រះវរបិតាសួគ៌របស់ខ្ញុំ ។ ប្រសិនបើខ្ញុំធ្វើតាមការទូន្មាននោះ ខ្ញុំដឹងថា ខ្ញុំនឹងទទួលវិវរណៈស្ដីពីការសម្រេចចិត្តដែលខ្ញុំត្រូវធ្វើ ។ ទ្រង់ឆ្លើយសំណួរមួយចំនួនរបស់ខ្ញុំ ពីមុនខ្ញុំសួរសំណួរនោះទៅទៀត ។

*កាមី អេច អាយុ ១៦ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា*

### សូមស្ដាប់ព្រះវិញ្ញាណ

ប្រសិនបើអ្នកកំពុងស្វែងរកការលួងលោម និងការណែនាំ ឬស្វែងរកចម្លើយចំពោះសំណួរក្នុងគ្រាអាសន្ន អ្នកអាចអធិស្ឋានដោយស្មោះសរអំពីវា ហើយអានពររបស់លោកអយ្យកោរបស់អ្នក ដោយស្មោះអស់ពីចិត្ត អំឡុងពេលស្ដាប់តាមព្រះវិញ្ញាណនោះ ។ ការស្រាវជ្រាវបទគម្ពីរក៏មានប្រយោជន៍ផងដែរ ។ ខ្ញុំជឿថា ប្រសិនបើអ្នកធ្វើបែបនេះដោយសេចក្ដីជំនឿពិត នោះព្រះអម្ចាស់នឹងឆ្លើយតបដល់អ្នកតាមពេលវេលា និងតាមរបៀបដ៏ល្អបំផុតរបស់ទ្រង់ ។

*ខេស្សៀ ប៊ី អាយុ ១៥ ឆ្នាំ រដ្ឋ ហាវ៉ៃ ស.រ.អា.*

### ពរជ័យដែលបានសន្យា

ពររបស់លោកអយ្យកោប្រាប់យើងនូវអ្វីដែលព្រះសព្វព្រះទ័យដើម្បីប្រទានពរដល់យើង ។ ទ្រង់ប្រទានដល់យើងនូវការព្រមាន និងពន្យល់របៀបដែលយើងអាចក្លាយកាន់តែដូចជាទ្រង់ ។ ពេលយើងដឹងអ្វីដែលព្រះវរបិតាសួគ៌រៀបចំនៅក្នុងឃ្លាំងសម្រាប់យើង និងរបៀបទទួលបានវា នោះយើងជ្រើសរើស ហើយធ្វើសកម្មភាពស្របតាមការដែលយើងទទួលវា ។

*ហាន់ធើរ អេច អាយុ ១៨ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា*

*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និងទស្សនវិស័យមិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*



## ក្នុងនាមជាយុវនារីម្នាក់ តើខ្ញុំគួរតែផ្ដោតចិត្តទុកដាក់លើការអប់រំ និងវិជ្ជាជីវៈច្រើនជាង ឬផ្ដោតចិត្តទុកដាក់ទៅលើការធ្វើជាភរិយា និងម្ដាយច្រើនជាង ?

យើងដឹងថា « ក្រុមគ្រួសារជាផ្នែកសំខាន់មួយនៃផែនការរបស់ព្រះដ៏បង្កបង្កើត » ហើយថា « ម្ដាយមានភារកិច្ចសំខាន់ ដើម្បីថែរក្សាបីបាច់កូនចៅរបស់ខ្លួន » ។[១] ហើយយើងក៏ដឹងផងដែរថា ចំពោះហេតុផលល្អៗមួយចំនួន ទាំងបុរស និងស្ត្រី នោះព្យាការីបានទូន្មានឲ្យទទួលការអប់រំ ។[២] ក្រៅពីនេះ យើងដឹងថា ស្ត្រីជាច្រើននឹងត្រូវការ ឬចង់ចាប់យកវិជ្ជាជីវៈនានា ។

ប្រធាន ដាល្លិន អេក អូក ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា សម្រាប់ស្ត្រី ជម្រើសពុំមែនរវាងគ្រួសារ ឬការអប់រំ និងវិជ្ជាជីវៈនោះទេ ។ លោកបានមានប្រសាសន៍ថា « ពេលវេលាទេដែលជាអ្វីដែលយើងត្រូវជ្រើសរើសនោះ ។ ហើយយើងត្រូវស្វែងរកការបំផុសគំនិតពីព្រះអម្ចាស់ និងការបង្រៀនរបស់អ្នកបម្រើទ្រង់ក្នុងការធ្វើរឿងនោះ » ។[៣]

ដាក់ផែនការដើម្បីទទួលការអប់រំ និងផែនការដើម្បីមានគ្រួសារ ។ អ្នកក៏អាចធ្វើផែនការដើម្បីមានវិជ្ជាជីវៈមួយផងដែរ ។ នៅក្នុងរឿងទាំងនេះ ការផ្ដោតចិត្តទុកដាក់របស់អ្នកគួរតែទៅលើការធ្វើតាមផែនការរបស់ព្រះវរបិតាសួគ៌ ហើយស្វែងរកព្រះទ័យរបស់ទ្រង់ ។

**កំណត់ចំណាំ**

១. « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » familyproclamation.lds.org ។
២. សូមមើល *ដើម្បីកម្លាំងនៃយុវជន* ( ឆ្នាំ ២០១១ ) ទំព័រ ៩ ។
៣. ដាល្លិន អេក អូក, ព្រឹត្តិការណ៍សំណេះសំណាលជាមួយអែលឌើរអូក និងអែលឌើរបាឡឺដ ( ព្រឹត្តិការណ៍យុវមជ្ឈិមវ័យនៅលីវទូទាំងពិភពលោក ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៧ ) broadcasts.lds.org ។

នៅគេហទំព័រ **lds.org/go/41961** យុវមជ្ឈិមវ័យម្នាក់ចែកចាយរឿងរបស់គាត់ស្ដីពីភាពពុំប្រាកដប្រជា ប្រសិនបើគាត់គួរតែផ្ដោតចិត្តទុកដាក់លើវិជ្ជាជីវៈ ឬគ្រួសាររបស់គាត់ ។ សូមមើលអ្វីដែលប្រធាន រ័សុល អិម ណិលសុន បានមានប្រសាសន៍ទៅកាន់នាង ។

### *តើអ្នកគិតដូចម្ដេច ?*

« ខ្ញុំមានការលំបាកទទួលចម្លើយចំពោះការអធិស្ឋាន ។ តើខ្ញុំដឹងថា ចម្លើយនោះមកពីព្រះដោយរបៀបណា ? »

ប្រសិនបើអ្នកមានបំណងឆ្លើយនឹងសំណួរនេះ សូមផ្ញើចម្លើយរបស់អ្នក និងរូបថតមានគុណភាពច្បាស់មួយសន្លឹកឲ្យបានត្រឹមថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៩ ទៅកាន់គេហទំព័រ liahona.lds.org ( សូមចុច « Submit an Article » or Feedback ) ។ ឬអ៊ីម៉ែលចម្លើយ និងរូបថតរបស់អ្នកទៅកាន់ liahona@ldschurch.org ។ សូមដាក់ឈ្មោះពេញ និងឈ្មោះវួដ ព្រមទាំងស្តេក ( ឬសាខា និងមណ្ឌល ) របស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

# សាកល្បង
# ប្រពៃណីបុណ្យអ៊ីស្ទើរថ្មីៗមួយចំនួន



ដោយ ដេវីឌ ឌីកសុន
ទស្សនាវដ្ដីសាសនាចក្រ

ជាទូទៅបុណ្យគ្រីស្ទម៉ាស់ទទួលបានការចាប់អារម្មណ៍ច្រើន ពេលដល់រដូវកាលនោះ ។ ប៉ុន្តែបើគ្មានព្រឹត្តិការណ៍ដែលកើតឡើងយូរអង្វែងមកនេះ ដែលយើងសាទរដល់បុណ្យអ៊ីស្ទើរនីមួយៗទេ នោះបុណ្យគ្រីស្ទម៉ាស់នឹងពុំមានឡើយ ។

មានម្ដងនោះប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី ( ១៩១០–២០០៨ ) បានបង្រៀនថា « វានឹងគ្មានបុណ្យគ្រីស្ទម៉ាស់ឡើយ ប្រសិនបើគ្មានបុណ្យអ៊ីស្ទើរនោះ ។ ព្រះឱរសយេស៊ូវនៃភូមិបេថ្លេហិមនឹងក្លាយជាទារកធម្មតាម្នាក់ ប្រសិនបើគ្មានព្រះគ្រីស្ទដ៏ប្រោសលោះនៃសួនច្បារគែតសាម៉ានី និងកាល់វ៉ារី និងការពិតដ៏ជោគជ័យនៃការរស់ឡើងវិញនោះ » ។[១]

នេះជាប្រពៃណីមួយចំនួនដែលអ្នកអាចពិចារណាបន្ថែមទៅលើការសាទរជាប្រចាំឆ្នាំរបស់អ្នក ៖



១

## ទៅច្រៀងចម្រៀងបុណ្យអ៊ីស្ទើរ

ទុកចម្រៀងកំប្លុកកំប្លែងអំពីសត្វរមាំង និងម្រេញគង្វាលមួយអន្លើរសិន ចម្រៀងបុណ្យគ្រីស្ទម៉ាស់ទាំងអស់គឺស្ដីពីព្រះយេស៊ូវគ្រីស្ទ ។ បុណ្យអ៊ីស្ទើរគឺជាគ្រាដ៏ល្អបំផុតសម្រាប់តន្ត្រីស្ដីពីព្រះអង្គសង្គ្រោះ មែនហើយថែមទាំងអាចច្រៀងវានៅខាងមុខទ្វារផ្ទះអ្នកជិតខាងរបស់អ្នកផងដែរ ។

ប្រសិនបើអ្នកពុំប្រាកដចិត្តទេនោះ សូមពិនិត្យមើលវគ្គ « ប្រធានបទ » នៃសៀវភៅទំនុកតម្កើងក្រោមពាក្យ « បុណ្យអ៊ីស្ទើរ » និង « ដង្វាយធួន » សម្រាប់បទចម្រៀងទាំងនោះ ។ ចម្រៀងណាដែលសាទរដល់ព្រះយេស៊ូវគ្រីស្ទគឺត្រូវនឹងចម្រៀងបុណ្យអ៊ីស្ទើរហើយ ។



២

## អភ័យទោសដល់អ្នកដទៃ

តើអ្នកមានអំណរគុណចំពោះអំណោយទាននៃការប្រែចិត្តញឹកញាប់ប៉ុណ្ណា ? បុណ្យអ៊ីស្ទើរផ្ដល់ឱកាសឲ្យយើងគិតបន្ថែមទៀតពីរបៀបយើងបង្ហាញវិញ្ញាណនៃការអភ័យទោសដូចគ្នានោះចំពោះមនុស្សដទៃ ។

ព្រះយេស៊ូវបានបង្រៀនថា ៖ « ហេតុដូច្នោះហើយ យើងប្រាប់អ្នកថា អ្នកត្រូវអត់ទោសដល់គ្នាទៅវិញទៅមក ។ . . .

យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណា ដែលយើងនឹងអត់ទោស ប៉ុន្តែរីឯអ្នកវិញ គឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់ » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:៩–១០ ) ។

សួរខ្លួនអ្នកថា ៖ តើអ្នកកំពុងចងកំហឹងចំពោះនរណា ? សូមអធិស្ឋានទូលសូមកម្លាំងដើម្បីអភ័យទោសដល់បុគ្គលនេះ ហើយទុកឲ្យព្រះអង្គសង្គ្រោះជួយឲ្យអារម្មណ៍ឈឺចាប់ទាំងនោះរសាយបាត់អស់ ។



៣

## សម្ដែងល្ខោន សម្ដែងរឿង ឬការសម្ដែងផ្សេងៗ

អ្នកអាចរៀបចំការសម្ដែងបុណ្យអ៊ីស្ទើរមួយ ។ ឧទាហរណ៍សាមញ្ញមួយគឺការអានព្រះគម្ពីរសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ឬការប្រគំតន្ត្រីសហគមន៍ដែលមានការច្រៀងអមជាមួយ ។

រូបភាពលម្អិតមកពី *FOR UNTO US A CHILD IS BORN* ដោយ លីន ផល់ម៉ាន់ វ៉ែនហ្វៀរ



៤

## ទៅផ្នូរមនុស្សជាទីស្រឡាញ់

ដោយសារព្រះយេស៊ូវគ្រីស្ទ សេចក្ដីស្លាប់បានបាត់បង់ទ្រនិចរបស់វា ( សូមមើល កូរិនថូសទី ១ ១៥:៥៥ ) ។ សូមចំណាយពេលទៅផ្នូររបស់មនុស្សជាទីស្រឡាញ់ ដើម្បីពិចារណាអំពីព័ត៌មានដ៏អស្ចារ្យនេះ ។

អ្នកអាចអានខគម្ពីរដែលអ្នកពេញចិត្តមួយចំនួនឲ្យឮៗ ដែលទាក់ទងនឹងការរស់ឡើងវិញ ពេលអ្នកទៅលេងផ្នូរទាំងនោះ ។ ខគម្ពីរមួយចំនួន ( នៃខគម្ពីរ *ជាច្រើន* ) ដើម្បីពិចារណាសម្រាប់រឿងនេះគឺ កូរិនថូសទី ១ ១៥:២០–២២; អាលម៉ា ១១:៤២–៤៤ និង គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:១៤–១៦ ។



៥

## ចូរធ្វើខ្លួនឲ្យបានប្រសើរឡើងបន្តិច

បុណ្យអ៊ីស្ទើរផ្ដល់កិត្តិយសដល់ព្រឹត្តិការណ៍នៃច្បារគែតសេម៉ានី អ្វីដែលបានកើតឡើងនៅលើឈើឆ្កាង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះនៅថ្ងៃទីបី ហើយក្រោយមកការងារបម្រើរបស់ទ្រង់រយៈពេល ៤០ ថ្ងៃ ពីមុនការយាងទៅស្ថានសួគ៌វិញ ។

ក្រៅពីនេះ មិនយូរប៉ុន្មានបន្ទាប់ពីការយាងទៅកាន់ស្ថានសួគ៌ ព្រះយេស៊ូវគ្រីស្ទបានបង្ហាញព្រះកាយដល់ពួកសាសន៍នីហ្វៃ ហើយប្រទានការងារបម្រើដល់ពួកគេ ( សូមមើល នីហ្វៃទី ៣ ១១–២៨ ) ។ មានចំណុចជាច្រើនដែលត្រូវសាទរ ។

ហេតុអ្វីពុំពង្រីកពេលវេលានៃការសាទររបស់អ្នកនៅរដូវកាលបុណ្យអ៊ីស្ទើរ ? ចូរឲ្យព្រលឹងអ្នកអរកោតរីករាយកាន់តែយូរនៅក្នុងអព្ភូតហេតុនៃបុណ្យអ៊ីស្ទើរ ។ សូមខំប្រឹងដោយការគិតគូរដើម្បីក្លាយកាន់តែដូចព្រះគ្រីស្ទ អំឡុងពេល ៤០ ថ្ងៃ បន្ទាប់ពីបុណ្យអ៊ីស្ទើរ ។ សម្រាប់ការបំផុសគំនិត សូមពិចារណាអំពីការអញ្ជើញខាងក្រោមមកពីប្រធាន រ័សុល អិម ណិលសុន ៖ « ថ្វាយផ្នែកមួយនៃពេលវេលារបស់អ្នករាល់សប្ដាហ៍ដើម្បីសិក្សា *អ្វីៗគ្រប់យ៉ាង* ដែលព្រះយេស៊ូវបានមានបន្ទូល និងបានធ្វើដូចបានកត់ត្រានៅក្នុងព្រះគម្ពីរសញ្ញាចាស់ ដ្បិតទ្រង់គឺជាព្រះយេហូវ៉ានៃព្រះគម្ពីរសញ្ញាចាស់ ។ សិក្សាពីក្រឹត្យវិន័យទ្រង់ដូចបានកត់ត្រានៅក្នុងព្រះគម្ពីរសញ្ញាថ្មី ដ្បិតទ្រង់គឺជាព្រះគ្រីស្ទក្នុងព្រះគម្ពីរសញ្ញាថ្មី ។ សូមសិក្សាគោលលទ្ធិរបស់ទ្រង់ដូចមានកត់ត្រានៅក្នុងព្រះគម្ពីរមរមន ដ្បិតគ្មានគម្ពីរណាដែលបានបើកសម្ដែងពីបេសកកម្ម និងការងារបម្រើរបស់ទ្រង់ច្បាស់លាស់ជាងព្រះគម្ពីរមរមនឡើយ ។ ហើយសូមសិក្សាពីព្រះបន្ទូលទ្រង់ដូចបានកត់ត្រានៅក្នុងព្រះគម្ពីរគោលលទ្ធិ និងសេចក្ដីសញ្ញា ដ្បិតទ្រង់បន្តបង្រៀនរាស្ត្ររបស់ទ្រង់នៅក្នុងសម័យកាន់កាប់ត្រួតត្រានេះ » ។[២]

## ប្រពៃណីរបស់អ្នកកំពុងរង់ចាំ

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា « ដើម្បីស្វែងរកជំនាន់ដ៏សំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្រ យើងត្រូវតែត្រឡប់ទៅកាន់ពេលល្ងាចមួយជិត ២០០០ ឆ្នាំមុននៅសួនច្បារគែតសេម៉ានី នៅពេលដែលព្រះយេស៊ូវគ្រីស្ទបានលុតជង្គង់អធិស្ឋានដោយមុតមាំ ហើយថ្វាយព្រះអង្គទ្រង់ជាការលោះសម្រាប់អំពើបាបរបស់យើង » ។[៣]

ព្រឹត្តការណ៍សំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្រមានតម្លៃ ដើម្បីឆ្លៀតពេលពិចារណាជារៀងរាល់ឆ្នាំ ។ ប្រពៃណីជួយយើងឲ្យធ្វើបែបនោះ ទោះបីជាប្រពៃណីមួយដែលចេញពីបញ្ជីនេះ ឬប្រពៃណីណាមួយដែលអ្នកជ្រើសរើសដោយផ្ទាល់ខ្លួនក្ដី ។

តើអ្នកនឹងបន្ថែមអ្វីខ្លះក្នុងឆ្នាំនេះ ? ■

*នៅបុណ្យអ៊ីស្ទើរនេះ សូមចំណាយពេលមួយចំនួនបន្ថែមទៀត ដើម្បីចងចាំពីអំណោយទានដ៏មហិមាបំផុតដែលបានប្រទានមក ។*

រូបគំនូរដកស្រង់ពី *ព្រះយេស៊ូវគ្រីស្ទយាងមកទ្វីបអាមេរិក* ដោយ ចន ស្កុត

**កំណត់ចំណាំ**

១. ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី « The Wondrous and True Story of Christmas » *Ensign* ខែ ធ្នូ ឆ្នាំ ២០០០ ទំព័រ ៥ ។
២. រ័សុល អិម ណិលសុន « Prophets, Leadership, and Divine Law » ( ការប្រជុំធម្មនិដ្ឋានសម្រាប់យុវមជ្ឈិមវ័យទូទាំងពិភពលោក ថ្ងៃទី ៨ ខែ មករា ឆ្នាំ ២០១៧ ) គេហទំព័រ broadcasts.lds.org ។
៣. ឌៀថើរ អេស្វ អុជដូហ្វ « Behold the Man! » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៨ ។

# ការបង្ហាញដ៏អស្ចារ្យបំផុតអំពីសេចក្តីស្រឡាញ់របស់ព្រះ

ដោយប្រធាន អិម រ័សុល បាឡឺដ
ប្រធានស្តីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

---

ព្រះ បង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់យើង តាមរយៈការប្រទាននូវការណែនាំ ដែលយើងត្រូវការដើម្បីរីកចម្រើន និងឈានដល់សក្តានុពលរបស់យើង ។ ទ្រង់ស្គាល់យើង សក្តានុពលយើងច្បាស់បំផុត ហើយភាពអស់កល្បជានិច្ចរបស់យើងដែលអាចកើតមានឡើងដល់យើង បានផ្តល់ដល់យើងនូវឱវាទ និងបទបញ្ញត្តិដ៏ទេវភាពនៅក្នុងសៀវភៅណែនាំរបស់ទ្រង់—គឺព្រះគម្ពីរដ៏បរិសុទ្ធ ។ ពេលយើងយល់ ហើយធ្វើតាមការណែនាំទាំងនេះ ជីវិតរបស់យើងមានគោលបំណង និងអត្ថន័យ ។ យើងរៀនថា អង្គបង្កបង្កើតរបស់យើងស្រឡាញ់យើង ហើយមានព្រះទ័យប្រទានសុភមង្គលដល់យើង ។ នៅក្នុងការបង្ហាញសេចក្តីស្រឡាញ់ដ៏ទេវភាពដែលពុំអាចប្រៀបផ្ទឹមបានសម្រាប់យើង នោះទ្រង់បានបញ្ជូនព្រះរាជបុត្រាទ្រង់តែមួយ គឺព្រះយេស៊ូវគ្រីស្ទ ។

« ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ។

ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជម្រះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ » ( យ៉ូហាន ៣:១៦–១៧ ) ។

ព្រះយេស៊ូវបានប្រសូតមកក្នុងជីវិតរមែងស្លាប់នេះ ។ ទ្រង់បានដឹកនាំជីវិតដ៏ឥតខ្ចោះ ហើយដោយការធ្វើបែបនោះ ទ្រង់បានគូសផ្លូវឲ្យយើងដើរតាម ។ ទ្រង់បានបង្រៀនសិស្សទ្រង់ថា ៖ « ខ្ញុំជាពន្លឺលោកីយ៍អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្តីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ »។ ( យ៉ូហាន ៨:១២ ) ។

យើងអាចចាប់ផ្តើមយល់ពីជម្រៅនៃសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទសម្រាប់យើង ពេលយើងពិចារណាថា ទ្រង់មានព្រះទ័យធ្វើពលិកម្មធួន ហើយរងការឈឺចាប់សម្រាប់អំពើបាបយើង « គឺជាសេចក្តីវេទនា ដែលបណ្តាលឲ្យ [ ទ្រង់ ] គឺជាព្រះដែលមហិមាលើអ្វីៗទាំងអស់ត្រូវញ័រដោយសារតែការឈឺចាប់ ហើយត្រូវច្រួចលោហិតចេញពីគ្រប់រន្ធញើស ហើយត្រូវរងទុក្ខព្រមទាំងរូបកាយ និងវិញ្ញាណផង » ( គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:១៨ ) ។

នៅបុណ្យអ៊ីស្ទើរនេះ ចូរយើងថ្លែងអំណរគុណជាពិសេសដល់ព្រះ ចំពោះដង្វាយធួន និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះរាជបុត្រាសំណព្វគឺព្រះយេស៊ូវគ្រីស្ទ ។ ដ្បិតនៅក្នុងទ្រង់ ដោយសារទ្រង់ និងតាមរយៈទ្រង់ លក្ខខណ្ឌនៃជីវិតរមែងស្លាប់បណ្តោះអាសន្ននេះ អាចត្រូវបានធ្វើឲ្យទៅជាអចិន្ត្រៃ ឲ្យមានភាពល្អឥតខ្ចោះ ដែលរកពាក្យណាមកថ្លែងពីអំណរយើងបានឡើយ ។

លក្ខណៈដ៏អស្ចារ្យទាំងអស់គឺជាផ្នែកមួយនៃព្រះចេស្តាដ៏ទេវភាពរបស់ទ្រង់ និងការបង្ហាញនៃសេចក្តីស្រឡាញ់របស់ទ្រង់ ។ ប៉ុន្តែអព្ភូតហេតុដ៏មហិមាទាំងអស់កំពុងរង់ចាំយើង ។ វានឹងកើតមានឡើងដោយព្រះចេស្តារបស់ទ្រង់ នៅពេលយើងនឹងងើបចេញពីសេចក្តីស្លាប់ និងផ្លូវទៅកាន់ពិភពថ្មីមួយ ដែលនឹងមិនកន្លងផុតទៅឡើយ ជាកន្លែងដែលយើងនៅជាមួយទ្រង់ និងព្រះវរបិតាដែលគង់នៅស្ថានសួគ៌ជារៀងរហូតតទៅ ប្រសិនបើយើងស័ក្តិសម ។ ■

*ដកស្រង់ចេញពីសុន្ទរកថាសន្និសីទទូទៅខែ មេសា ឆ្នាំ ១៩៨៨ ។*

ប្រែសម្រួលដោយ អេនឌ្រូ វ៉ូប៊ែក

បានធ្វើការឲ្យ **កន្លែងលក់រថយន្ត** របស់ឪពុកលោកនៅដើមទសវត្សរ៍ឆ្នាំ ១៩៥០ ហើយជា **កំពូលអ្នកលក់** ។

កើតនៅថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៨២ នៅ **ទីក្រុងសលត៍ លេក រដ្ឋ យូថាហ៍** ។

បានសិក្សានៅ **សាកលវិទ្យាល័យ យូថាហ៍** ។

# ប្រធាន អិម រ័សុល បាឡឺដ



បានបម្រើបេសកកម្មពេញម៉ោងនៅ **ប្រទេស អង់គ្លេស** ។



ជីតា ៖ អែលឌើរ មែលវិន ជេ បាឡឺដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

ជីតា ៖ អែលឌើរ ហៃរ៉ាំ ម៉ាក ស្មីធ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

បានបម្រើជា **ប្រធានបេសកកម្ម** នៅបេសកកម្ម កាណាដា តូរ៉ុនតូ ពីឆ្នាំ ១៩៧៤ ទៅ ១៩៧៧ ។

បានជួបភរិយារបស់លោក បាបារ៉ា បូវែន សាកលវិទ្យាល័យ យូថាហ៍ នៅក្នុងកម្មវិធី **« Hello Day Dance »** ។

បានរៀបអាពាហ៍ពិពាហ៍នឹង **បាបារ៉ា បូវ៉ែន** នៅក្នុងព្រះវិហារបរិសុទ្ធសលត៍ លេក នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៥១ ។

បានគាំទ្រជា **កូរ៉ុមនៃពួកសាវកដប់ពីរនាក់** នៅថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៨៥ ។

មានកូន **៧** នាក់,

ចៅ **៤៣** នាក់,

ចៅទួត **៩១** នាក់ ។

បន្ទាប់ពីសន្និសីទទូទៅខែ តុលា ឆ្នាំ ១៩៨០ លោកបានសរសេរសំបុត្រជាង

**៦០០**

សំបុត្រលើកទឹកចិត្តដល់សមាជិកដែលកំពុងមានការលំបាកក្នុងការមានទីបន្ទាល់របស់ពួកគេ ។

ទុកកញ្ចប់ **នំអូរីអូ** នៅលើតុធ្វើការរបស់លោក ដើម្បីទុកជាការចងចាំពីកុមារម្នាក់ដែលបានធ្វើដំណើរដ៏សែនឆ្ងាយទៅកាន់ជំរំកៀសខ្លួន បានទទួលនំយុកឃីមួយកញ្ចប់ ហើយបានឲ្យនំយុកឃីមួយទៅប្រធានបាឡឺដមុនគេ ។

ញែកចេញជា **ប្រធានស្ដីទី** ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៨ ។

**ទំព័របន្ថែមទៀតសម្រាប់កុមារ**

សូមយកទស្សនាវដ្ដី *ប្រិយមិត្ត* ថ្មី ប្រើប្រាស់ឲ្យបានល្អ ។ ប្រសិនបើអ្នកគ្មានកូននៅផ្ទះទេនោះ អ្នកអាច ៖

- ចែកចាយទស្សនាវដ្ដី *ប្រិយមិត្ត* ជាមួយគ្រួសារដែលពុំបានទទួលទស្សនាវដ្ដី *លីអាហូណា* ។
- ឲ្យទស្សនាវដ្ដីប្រិយមិត្តទៅមិត្តភក្តិ ឬអ្នកជិតខាង ។
- ឲ្យទស្សនាវដ្ដីប្រិយមិត្តទៅអ្នកដឹកនាំថ្នាក់អង្គការបឋមសិក្សា ឬគ្រូបង្រៀន ។




យុវមជ្ឈិមវ័យ
តើត្រូវការជំនួយជាមួយនឹងការសម្រេចចិត្តធំៗឬ ?
៤២

យុវវ័យ
ការស្វែងរកភាពសុខសាន្តសម្រាប់ខ្លួនឯង និងមនុស្សដទៃ
៥២

បុណ្យអ៊ីស្ទើរ
ប្រពៃណីថ្មី
៦២

CAMBODIAN
4 02186 04258 2

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ប្រិយមិត្ត

ខែ មេសា ឆ្នាំ ២០១៩

វគ្គរបស់កុមារនៅក្នុងទស្សនាវដ្ដី *លីអាហូណា* ដែលបោះពុម្ពដោយ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



ដំណើររឿងនៃ
## បុណ្យអ៊ីស្ទើរ
សូមមើលទំព័រ ៤–៦

សារលិខិតគណៈប្រធានទីមួយ



ដោយប្រធាន រ័សុល អិម ណិលសុន

# អំណោយដ៏មហិមារបស់ព្រះ



ថ្ងៃមួយស៊ីស្ទើរណិលសុន និងខ្ញុំបានឃើញត្រីនៅតំបន់ត្រូពិចមួយចំនួននៅអាងចិញ្ចឹមត្រី ។ ត្រីទាំងនោះមានពណ៌ស្រស់ឆើតឆាយ ហើយមានរាង និងទំហំខុសៗគ្នា ហែលយ៉ាងលឿនចុះឡើង ។ ខ្ញុំបានសួរកម្មករនៅក្បែរនោះថា « តើនរណាឲ្យចំណីត្រីដ៏ស្រស់ស្អាតទាំងនោះ ? »

នាងបានឆ្លើយថា « គឺខ្ញុំ » ។

បន្ទាប់មក ខ្ញុំសួរថា « តើត្រីទាំងនេះធ្លាប់អរគុណអ្នកទេ ? »

នាងបានឆ្លើយថា « មិនទាន់ទេ ! » ។

មនុស្សមួយចំនួនគឺដូចជាត្រីនោះអញ្ចឹងដែរ ។ ពួកវាពុំដឹងពីសេចក្ដីស្រឡាញ់របស់ព្រះ និងសេចក្ដីល្អរបស់ទ្រង់ដល់ពួកវាឡើយ ។ តើវាកាន់តែប្រសើរយ៉ាងណាទៅ បើមនុស្សទាំងអស់អាចដឹងពីសេចក្ដីស្រឡាញ់នៃព្រះកាន់តែច្រើន ហើយបង្ហាញការដឹងគុណដល់ទ្រង់នោះ ។

**សូមមានអំណរគុណចំពោះព្រះយេស៊ូវគ្រីស្ទ ។**

ព្រះបានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទដើម្បីមកជួយយើង ។ ទ្រង់បានធ្វើបែបនោះដោយសារទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ។

ព្រះយេស៊ូវបានយាងមកដើម្បី **ប្រោសលោះ** យើង ។

ដោយសារ **ដង្វាយធួន** របសទ្រង់ នោះយើងអាចរស់ឡើងវិញបន្ទាប់ពីយើងស្លាប់ ។

ដោយសារដង្វាយធួនរបស់ទ្រង់ នោះយើងអាចត្រឡប់ទៅរស់នៅជាមួយនឹងព្រះវរបិតាសួគ៌វិញជារៀងរហូត ។

ព្រះយេស៊ូវបានពន្យល់ថា ៖

> « ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត ៖ អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញ ៖ ឯអ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ នោះមិនត្រូវស្លាប់ឡើយ »
> ( យ៉ូហាន ១១:២៥-២៦ ) ។

នេះហើយគឺជាសារលិខិតដ៏អស្ចារ្យនៃបុណ្យអ៊ីស្ទើរ ! ●

**ប្រោសលោះ ៖**
បង់ថ្លៃសម្រាប់អំពើបាបរបស់យើង ដើម្បីយើងអាចត្រឡប់ទៅកាន់ព្រះវិញ

**ដង្វាយធួន ៖**
ពេលព្រះយេស៊ូវរងទុក្ខសម្រាប់អំពើបាបរបស់យើងនៅក្នុងសួនច្បារគែតសេម៉ានី និងសុគតនៅលើឈើឆ្កាងត្រង់កាល់វ៉ារី

*ដកស្រង់ចេញពី « Thanks Be to God »*
Liahona *ខែ ឧសភា ឆ្នាំ ២០១២ ទំព័រ ៧៧–៨០ ។*




## ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ

ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញនៅព្រឹកបុណ្យអ៊ីស្ទើរ ។ សូមអានប្រយោគនានាដើម្បីរកមើលនូវអ្វីដែលទ្រង់បានធ្វើសម្រាប់ពួកយើង ។ សូមផាត់ពណ៌នៅក្នុងកាំរស្មីព្រះអាទិត្យបន្ទាប់ពីអ្នកអានប្រយោគនីមួយៗ ។ បន្ទាប់មក សូមផាត់ពណ៌រូបភាពទាំងអស់ ។

ខាងឆ្វេង ៖ គំនូរព្រាងដោយ ស៊ីឌី ប៊ូកាវ៉េ ខាងស្ដាំ ៖ គំនូរព្រាងដោយ ប៉ូល ម៉ាន់

# ដំណើររឿងនៃបុណ្យអ៊ីស្ទើរ



ព្រះយេស៊ូវស្រឡាញ់មិត្តភក្តិរបស់ទ្រង់ ។ ទ្រង់បានលាងជើងរបស់ពួកគេ ។ បន្ទាប់មក ទ្រង់បានឲ្យពួកគេទទួលទានសាក្រាម៉ង់ ។ ទ្រង់បានប្រាប់ពួកគេឲ្យចងចាំទ្រង់ ។ ទ្រង់បានប្រាប់ពួកគេឲ្យស្រឡាញ់គ្នាទៅវិញទៅមក ។



បន្ទាប់មក ព្រះយេស៊ូវបានយាងទៅក្នុងសួនច្បារមួយ ។ ទ្រង់បានអធិស្ឋានសម្រាប់ពួកយើងទាំងអស់គ្នា ។ ទ្រង់បានទទួលអារម្មណ៍នៃក្តីឈឺចាប់នៃជំងឺរបស់យើង ។ ទ្រង់បានទទួលអារម្មណ៍នៃក្តីឈឺចាប់នៃអំពើបាបរបស់យើង ។

មនុស្សដែលមានកំហឹងបានចាប់ព្រះយេស៊ូវ យកទៅ ។ ពួកគេបានធ្វើបាបទ្រង់ ។ ទ្រង់បានសុគតនៅលើឈើឆ្កាងសម្រាប់ពួកយើង ។ មិត្តភក្តិរបស់ទ្រង់បានបញ្ចុះព្រះសពរបស់ទ្រង់នៅក្នុងផ្នូរ ។





បីថ្ងៃក្រោយមក មិត្តភក្តិរបស់ទ្រង់បានត្រឡប់មកឯផ្នូរវិញ ។ ផ្នូរនោះនៅទទេស្អាត ! ពួកទេវតាបានប្រាប់ពួកគេថា « ទ្រង់បានមានព្រះជន្មរស់ឡើងវិញហើយ » ។ ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញម្តងទៀត ! ដោយសារតែព្រះយេស៊ូវ នោះយើងទាំងអស់គ្នានឹងរស់ឡើងវិញម្តងទៀតបន្ទាប់ពីយើងស្លាប់ !



ព្រះយេស៊ូវស្រឡាញ់ខ្ញុំ ។ ខ្ញុំអាចធ្វើឲ្យថ្ងៃបុណ្យអ៊ីស្ទើរពិសេសបានតាមរយៈការចងចាំពីទ្រង់ ។●

*សូមអានអំពីព្រឹកនៃបុណ្យអ៊ីស្ទើរនៅក្នុង ម៉ាថាយ ២៨ ។*

# ពេលខ្ញុំមករកទ្រង់វិញ

ដោយរីករាយ ♩ = ៩០–៩៦

ទំនុកបទ និង ទំនុកភ្លេងដោយ សាលី ឌីហ្វដ




© 2019 by Sally DeFord. All rights reserved.
បទចម្រៀងនេះ អាចថតចម្លងយកមកប្រើប្រាស់បន្ទាប់បន្សំនៅក្នុងសាសនាចក្រ និងក្នុងគេហដ្ឋាន ពុំមែនសម្រាប់ធ្វើអាជីវកម្មឡើយ។
សេចក្តីប្រកាសនេះត្រូវតែបិទនៅលើសំណៅថតចម្លងនីមួយៗ ។




ដោយ ផេន ម៉ាកប្រាយដ៏
ផ្អែកទៅលើដំណើររឿងពិត

*« ប្រព្រឹត្តសេចក្តីល្អតែប៉ុណ្ណោះ » ( កូរិនថូសទី ២ ១៣:៧ ) ។*

ម៉ាក់បាននិយាយថា « ម៉ាក់ត្រូវការកូនមើលថៃប្អូន ។ ប៉ារបស់កូន និងម៉ាក់នឹងទៅជួយមនុស្សម្នាក់ដែលឈឺ » ។

ខ្ញុំបានងើយមុខមើលគាត់ពេលកំពុងជូលកម្រាលឥដ្ឋផ្ទះតូចរបស់យើង ហើយងក់ក្បាល ។ ម៉ាក់គឺជាប្រធានសមាគមន៍សង្គ្រោះ ហើយជារឿយៗគាត់បានទៅសួរសុខទុក្ខបងប្អូនស្រីនៅក្នុងវួដរបស់យើង ។

ម៉ាក់បាននិយាយទាំងថើបសក់ក្បាលខ្ញុំថា « អរគុណអាលីន ។ ចនកំពុងគេង ។ ហើយមានម្សៅធ្វើនំប៉័ងនៅលើតុ ។ សុំកុំប៉ះពាល់វា » ។

ខ្ញុំបានមើលម៉ាក់ និងប៉ាតាមមាត់ទ្វារ ពេលពួកគេជិះរទេះមានដំបូងទៅតាមផ្លូវដីហុយ ។ ខ្ញុំមានអារម្មណ៍មោទនភាពដែលម៉ាក់បានទុកចិត្តខ្ញុំ ។

ពេលខ្ញុំបោសសម្អាតផ្ទះបាយ ខ្ញុំបានឈប់ ហើយមើលទៅម្សៅធ្វើនំប៉័ងនោះ ។ ខ្ញុំពុំអាចទ្រាំនឹងរង់ចាំឲ្យម៉ាក់ធ្វើនំប៉័ងយប់នេះឡើយ ។ ជាទូទៅ យើងបរិភោគនំប៉័ងស្រស់ៗជាមួយដំណាប់ដែលយើងធ្វើ ។ ប៉ុន្តែយើងបានអស់ដំណាប់បីខែមកហើយ ។

ដំណាប់ ! គំនិតនេះបានធ្វើឲ្យខ្ញុំឃ្លានអ្វីមួយផ្អែមៗ ។ ខ្ញុំបានក្រឡេកមើលទៅក្រឡស្ករដែលនៅលើធ្នើរខ្ពស់ ។ ខ្ញុំដឹងថា ម៉ាក់បានទុកវាដើម្បីធ្វើដំណាប់បន្ថែមទៀត ។

ប៉ុន្តែពេលណាខ្ញុំគិតអំពីស្ករ នោះខ្ញុំកាន់តែឃ្លាន ។ ទីបំផុត ខ្ញុំបានទាញកៅអីដាក់ឡើងលើតុ ហើយឈោងយកវា ។ ម្រាមដៃរបស់ខ្ញុំស្ទើរតែប៉ះក្រឡស្ករនោះ ។ ខ្ញុំបានទាញវាមកក្បែរគែមធ្នើរ ។ . . .

បន្ទាប់មក ក្រឡនោះបានរអិលធ្លាក់ចុះពីធ្នើរ ។ ខ្ញុំបានព្យាយាមចាប់វា ប៉ុន្តែវាបានធ្លាក់ឮសំឡេងយ៉ាងខ្លាំងនៅចំកណ្តាលម្សៅធ្វើនំប៉័ង ។ ស្ករបានខ្ចាយពេញលើនំប៉័ង និងតុ ព្រមទាំងលើកម្រាលឥដ្ឋផងដែរ ។

ខ្ញុំបានស្រែក « អ៊ូ អត់ទេ ! » វាបានធ្វើឲ្យប្អូនប្រុសខ្ញុំភ្ញាក់ ។ គាត់បានចាប់ផ្តើមយំ ។ ខ្ញុំ ក៏ចង់យំដែរ ។ តើម៉ាក់នឹងនិយាយដូចម្តេចអំពីភាពរញ៉េរញ៉ៃនេះ ?

បន្ទាប់ពីខ្ញុំបានលួងចនហើយ ខ្ញុំបានខំសម្អាតស្ករដែលខ្ចាយនោះ ។ ខ្ញុំ

# ភាពទៀងត្រង់ដ៏ផ្អែមល្ហែម



បានទាញក្រឡនោះចេញពីម្សៅ ហើយលាងសម្អាតវា ។ ខ្ញុំបានបោសសម្អាតស្ករចេញពីតុ និងកម្រាលឥដ្ឋ ។ ប៉ុន្តែខ្ញុំពុំអាចធ្វើអ្វីមួយដើម្បីយកស្ករចេញពីម្សៅបានឡើយ ។

ខ្ញុំបានគិតពីការទុកក្រឡស្ករទៅលើធ្នើរវិញ ។ ប្រហែលជាម៉ាក់មិនចាំថា អស់ស្ករទេ ។ ប៉ុន្តែខ្ញុំដឹងថា ធ្វើបែបនេះពុំត្រូវទេ ។ ដូច្នេះខ្ញុំបានទុកក្រឡនេះនៅលើតុ ហើយរង់ចាំរហូតដល់ម៉ាក់ និងប៉ាត្រឡប់មកផ្ទះវិញ ។

ពេលពួកគាត់មកដល់ផ្ទះ ម៉ាក់បានឃើញក្រឡស្ករភ្លាម ។

ខ្ញុំបានដកដង្ហើមធំ ។ « កូនគ្រាន់តែចង់ភ្លក់រសជាតិស្ករ ! តែកូនបានប៉ះក្រឡស្ករធ្លាក់ចុះពីធ្នើរ ។ កូនបានព្យាយាមសម្អាតវា ប៉ុន្តែកូនពុំអាចយកស្ករចេញពីម្សៅធ្វើនំប៉័ងបានទេ » ។ ខ្ញុំបាននិយាយយ៉ាងលឿន ខណៈដែលខ្ញុំឱនមុខចុះទៅកម្រាលឥដ្ឋ ។

ម៉ាក់បាននៅស្ងៀមមួយសន្ទុះ ។

ខ្ញុំបាននិយាយខ្សឹបៗថា « ឲ្យកូនសុំទោស » ។

ម៉ាក់បានដកដង្ហើមធំ ។ គាត់បាននិយាយថា « អញ្ចឹងម៉ាក់គិតថា នំប៉័ងនឹងមានរសជាតិផ្អែមខ្លាំងហើយយប់នេះ ។ ខ្ញុំបានងើយមើលទៅគាត់ ។ គាត់បានញញឹមបន្តិចដាក់ខ្ញុំ ។ « អរគុណដែលកូនបានប្រាប់នូវអ្វីដែលបានកើតឡើង ។

ពេលយើងបរិភោគនំប៉័ងផ្អែមនាយប់នោះ ម៉ាក់ និងប៉ា ព្រមទាំងខ្ញុំបាននិយាយគ្នាអំពីភាពទៀងត្រង់ ។

ប៉ាបាននិយាយថា « យើងទាំងអស់គ្នាធ្វើខុសច្រើននៅក្នុងជីវិត ។ ប៉ុន្តែពេលយើងមានចិត្តទៀងត្រង់ ហើយព្យាយាមប្រែចិត្ត នោះព្រះវរបិតាសួគ៌ និងព្រះយេស៊ូវសព្វព្រះទ័យ ។ យើងនឹងមានពរជានិច្ចសម្រាប់ការមានចិត្តទៀងត្រង់—ទោះបីវាហាក់ដូចជាលំបាកនៅពេលដំបូងក្ដី » ។

ខ្ញុំនៅតែស្ដាយ ដែលខ្ញុំបានធ្វើឲ្យកំពប់ស្ករ ។ ខ្ញុំបានដឹងថា យើងប្រហែលជាគ្មានដំណាប់ច្រើនទេនាឆ្នាំនេះ ដោយសារតែកំហុសរបស់ខ្ញុំ ។ ប៉ុន្តែខ្ញុំរីករាយដែលខ្ញុំបាននិយាយការពិត ។ នោះគឺជាអារម្មណ៍ដ៏ផ្អែមល្ហែមមួយ ដែលទោះជាមានស្ករប៉ុន្មានក៏មិនអាចធ្វើឲ្យវាផ្អែមដូចនេះឡើយ ។●

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋខូឡូរ៉ាដូ ស.រ.អា. ។*



« ការគោរពព្រះបញ្ញត្តិនាំមកនូវពរជ័យ គ្រប់ពេល ! ការរំលងព្រះបញ្ញត្តិនាំមកនូវការបាត់បង់ពរជ័យ គ្រប់ពេល ! »

**ប្រធាន រ័សុល អិម ណិលសុន « ចូរបង្ហាញសេចក្ដីជំនឿអ្នក » *Liahona* ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៣០ ។**

ពួកសាវកនៅជុំវិញពិភពលោក

# អែលឌើរបែដណា ទៅទស្សនាប្រទេសឥណ្ឌា

អែលឌើរ ដាវីឌ អេ បែដណា បានធ្វើដំណើរជាមួយភរិយាលោក ស៊ូសាន បែដណា ដើម្បីចែកចាយទីបន្ទាល់របស់លោកអំពីព្រះយេស៊ូវគ្រីស្ទ ជាមួយសមាជិកនៃសាសនាចក្រក្នុងប្រទេសឥណ្ឌា ។ ប្រទេសឥណ្ឌាគឺជាប្រទេសមួយនៅក្នុងចំណោមប្រទេសដែលធំបំផុតនៅក្នុងពិភពលោក ។ ហើយមិនយូរឡើយ ប្រទេសនេះនឹងមានព្រះវិហារបរិសុទ្ធដំបូងមួយ !



អែលឌើរ និង ស៊ីស្ទើរ បែដណា បានទៅទីក្រុងរ៉ាចាមុនដ្រាយ ។ គ្មានសាវកណាម្នាក់ធ្លាប់ទៅទីនោះពីមុនឡើយ ។





កុមារបានចាប់ដៃអែលឌើរបែដណា ។



នៅក្នុងការប្រជុំនៅក្នុងទីក្រុង ហៃឌើរ៉ាបេត កុមារីនេះបានសួរសំណួរមួយដល់អែលឌើរបែដណា ។



« កាលណាខ្ញុំបានធ្វើដំណើរកាន់តែច្រើននៅជុំវិញពិភពលោក នោះខ្ញុំធ្វើទស្សនកិច្ចប្រទេសកាន់តែច្រើន មនុស្សកាន់តែច្រើនដែលខ្ញុំមានពរដើម្បីរៀនពីពួកគេ ហើយខ្ញុំកាន់តែឃើញថានៅលើពិភពលោកទាំងមូលមនុស្សគឺមានលក្ខណៈទូទៅដូចគ្នា » ។





សមាជិកគ្រប់រូបមានចិត្តរីករាយដែលបានស្ដាប់ទីបន្ទាល់នៃសាវកម្នាក់របស់ព្រះ !

## ផ្គូផ្គងសត្វដំរី

នៅប្រទេសឥណ្ឌាមានដំរីប្រហែលជា ៣០០០០ ក្បាល ។ តើអ្នកអាចរកឃើញដំរីដូចគ្នាប៉ុន្មានគូនៅក្នុងរូបខាងក្រោមនេះ ?
តើសត្វអ្វីខ្លះដែលអ្នកចូលចិត្ត ដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានបង្កើតមក ?





# ពួកព្យាការី និង ពួកសាវករបស់យើង

ព្រះយេស៊ូវគ្រីស្ទដឹកនាំសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ តាមរយៈពួកព្យាការី និងពួកសាវក ។ សូមអានពីពួកលោកដូចតទៅនេះ ។ បន្ទាប់មក សូមកាត់រូបនៅលើ ទំព័រ ២២៣ ហើយបិទវានៅក្នុងកន្លែងនៅលើតារាង ។ សូមបិទបង់ស្អិតនៅផ្នែកខាងលើរូបភាពនីមួយៗ ដើម្បីឲ្យអ្នកអាចលើករូបភាពទាំងនោះ អានសេចក្ដីពិតដែលមាននៅពីក្រោមវា !

- បានសម្អាតហាងដុសដុលរទ្យុដែលជាការងារមុនគេបង្អស់របស់លោក
- ជាមេធាវី និង ចៅក្រមកំពូលនៅរដ្ឋយូថាហ៍
- ធ្លាប់ធ្វើជាប្រធានសាកលវិទ្យាល័យព្រិកហាំយ៉ង់

**ប្រធាន ដាល្លិន អេក អូក**
*ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ*

- ជាវេជ្ជបណ្ឌិតវះកាត់បេះដូង
- បានសិក្សាភាសាបីបួន រួមទាំងភាសាចិន
- មានកូន ១០ នាក់ ៖ ស្រី ៩ នាក់ និងប្រុសម្នាក់

**ប្រធាន រ័សុល អិម ណិលសុន**
*ប្រធានទី ១៧ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ*

- បានលេងកីឡាបាល់បោះនៅវិទ្យាល័យ
- បានរៀនរូបវិទ្យាពីឪពុករបស់លោកនៅលើតុរាងឡើងគ្រួសាររបស់ពួកគាត់
- ធ្វើជាប្រធានមហាវិទ្យាល័យរីក ឥឡូវជាសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ–អៃដាហូ

**ប្រធាន ហិនរី បី អាវរិង**
*ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយ*

- ត្រូវបានគេដាក់ងារថា ជា « លោកប៊ីស្សព » នៅក្នុងមហាវិទ្យាល័យដោយព្រោះបទដ្ឋានដ៏ខ្ពស់របស់លោក
- បានបើកហាងលក់ឡាន
- បានបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅប្រទេសអង់គ្លេស ហើយបម្រើជាប្រធានបេសកកម្មនៅទីក្រុងតូរ៉ុនតូ ប្រទេសកាណាដា

**ប្រធាន អិម រ័សុល បាឡឺដ**
*ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- គឺជាដៃគូបេសកកម្មជាមួយអែលឌើរ យុក នៅក្នុងប្រទេសអង់គ្លេស
- បានធ្វើការឲ្យប្រពន្ធ័អប់រំសាសនាចក្រ
- ជាប្រធាននៃសាកលវិទ្យាល័យ ប៊ី.វ៉ាយ.យូ

**អែលឌើរ ជេហ្វ្រី អ័រ ហូឡិន**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ធ្លាប់ជាជនភៀសខ្លួនពីរដងកាលនៅក្មេង
- ធ្លាប់ជាមេបញ្ជាការលើអ្នកបើកយន្តហោះ
- ចូលចិត្តលេងជិះស្គីជាមួយកូន និងចៅៗរបស់លោក

**អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ធ្លាប់ជាកីឡាករវាយកូនបាល់នៅក្នុងក្រុមបាល់ឱបក្នុងវិទ្យាល័យរបស់លោក
- បន្ទាប់ពី បម្រើបេសកកម្មនៅក្នុងប្រទេសអាល្លឺម៉ង់ លោកបានជម្រុញឪពុកលោកចូលជាសមាជិកនៃសាសនាចក្រ
- ធ្លាប់ជាប្រធានមហាវិទ្យាល័យរីក ពេលមហាវិទ្យាល័យនេះក្លាយជាសាកលវិទ្យាល័យ ប៊ី វ៉ាយ យូ–អៃដាហូ

**អែលឌើរ ដាវីឌ អេ បែដណា**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានទទួលទីបន្ទាល់បន្ទាប់ពីសិក្សាព្រះគម្ពីរ និងអធិស្ឋានជាមួយបងប្រុសរបស់លោក
- បានជួបអនាគតភរិយាលោកនៅក្នុងកម្មវិធីសម្ដែងទេពកោសល្យនៅវិទ្យាល័យ
- បានបម្រើជាថ្នាក់ដឹកនាំនៅក្នុងប្រទេសហ្វីលីពីន និង កោះ ប៉ាស៊ីហ្វិក



**អែលឌើរ ឃ្វីនធិន អិល យុក**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានធ្វើនំប៉័ងសម្រាប់គ្រួសារខ្លួននៅពេលលោកធំពេញវ័យ
- បានចូលរួមនៅក្នុងការលេងល្ខោនភ្លេងម្យ៉ូសិកនៅក្នុងរដ្ឋ ន្យូ យ៉ោក កាលនៅវ័យជំទង់
- បានធ្វើការជាមេធាវី ពីមុនត្រូវបានហៅឲ្យធ្វើជាសាវក



**អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានចម្រើនវ័យធំឡើងនៅក្នុងកសិដ្ឋានចិញ្ចឹមគោក្នុងរដ្ឋ អៃដាហូ ស.រ.អា.
- បានបម្រើជាអ្នកផ្សព្វផ្សាយសាសនា និងជាប្រធានបេសកកម្មក្នុងប្រទេសបារាំង
-ចេះនិយាយភាសាបារាំង ភាសាព័រទុយហ្គាល ភាសាអេស្ប៉ាញ និងភាសាអង់គ្លេស



**អែលឌើរ នែល អិល អាន់ឌើរសិន**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ធ្លាប់ជាប្រធានបេសកកម្មនៅក្នុងទីក្រុង ន្យូ យ៉ោក ស.រ.អា.
- បាវចនារបស់លោកគឺ « គឺជាមនុស្សទេដែលសំខាន់បំផុត »
- បានឧទ្ទិសឆ្លងអគារព្រះវិហារបរិសុទ្ធថ្ងៃចុងក្រោយដំបូងគេនៅសាធារណៈរដ្ឋឆែក



**អែលឌើរ រ៉ូណល អេ រ៉ាសបាន**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- បានបម្រើជាអ្នកផ្សព្វផ្សាយសាសនា ហើយក្រោយមកជាប្រធានបេសកកម្មក្នុងប្រទេសជប៉ុន
- បានចាប់ផ្ដើមអាជីវកម្មមួយផ្នែកសាងសង់អាគារ និងលក់ឧបករណ៍ហាត់ប្រាណ
- បម្រើជាប៊ីស្សពលើសាសនាចក្រទាំងមូល



**អែលឌើរ ហ្គេរី អី ស្ទីវិនសុន**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ឈ្មោះកណ្ដាលរបស់លោកគឺ ហ្គាន់នើរ មានន័យថា « ទាហានដ៏អង់អាច »
- បានប្ដូរទីលំនៅពីរដ្ឋយូថាហ៍ជាមួយគ្រួសារលោកទៅរស់នៅប្រទេសស៊ុយអែត កាលលោកអាយុ ១១ ឆ្នាំ
- បម្រើការជាវេជ្ជបណ្ឌិតផ្នែកបេះដូង



**អែលឌើរ ឌេល ជី រេនឡាន់**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- ចូលចិត្តសត្វ រួមទាំងសត្វភេនឃ្វីនផងដែរ
- ចូលចិត្តជួបមនុស្សនៅក្នុងគ្រប់ប្រទេស
- មានកំណត់ត្រាពង្សប្រវត្តិរហូតដល់ហ្គង ត្រាហ្គន់ទីមួយនៅក្នុងឆ្នាំ ៨៣៧ នៃគ.ស. ។



**អែលឌើរ ហ្គេរិត ដបុលយូ ហ្គង**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

- មកពីប្រទេសប្រេស៊ីល ហើយបានបម្រើជាអ្នកផ្សព្វផ្សាយសាសនានៅទីនោះ និងជាប្រធានបេសកកម្មនៅប្រទេសព័រទុយហ្គាល់
- បានរៀនពីសាសនាចក្រជាមួយគ្រួសារលោកកាលលោកនៅក្មេង
- បានចាប់ផ្ដើមត្រៀមខ្លួនលោកជាស្រេចដើម្បីបម្រើបេសកកម្ម កាលលោកអាយុ ១២ ឆ្នាំ



**អែលឌើរ អ៊ូលីសេស សូរ៉េស**
*ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

សូមមើលចម្លើយរបស់អ្នកនៅលើគេហទំព័រ **lds.org/prophets-and-apostles** ។



# អាវធំដែលបាត់

ដោយ ស៊ែរឡា ខាញ៉ជ្រេដ
ផ្អែកទៅលើដំណើររឿងពិត

*« យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណា ដែលយើងនឹងអត់ទោស ប៉ុន្តែរីឯអ្នកវិញគឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់ » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១០ ) ។*

ប្រាដបាននិយាយថា « ម៉ាក់ ខ្ញុំបាត់អាវធំខ្ញុំហើយ ! វាដល់ពេលចេញពីព្រះវិហារត្រឡប់ទៅផ្ទះវិញ ប៉ុន្តែប្រាដពុំអាចរកឃើញអាវធំគាត់នៅលើស្នាព្យួរអាវឡើយ ។

ម្ដាយបានសួរ តើកូនប្រាកដទេថា កូនពិតជាបានព្យួរវានៅទីនេះ ? »

« បាទ ។ ខ្ញុំបានព្យួរវានៅទីនេះ » ។ អាវធំរបស់ប្រាដគឺពណ៌ខៀវ និងក្រហមស្រស់ ។ វាមិនគួរនឹងបាត់ទេ ។

ប៉ាបាននិយាយថា « ប្រហែលជាមានគេប្ដូរកន្លែងវាហើយ ។ តោះរកមើលជុំវិញអគារ » ។

ម៉ាក់ ប៉ា និង ប្រាដ បានបំបែកផ្លូវគ្នាដើរពិនិត្យមើលបន្ទប់ផ្សេងៗ ។ ពួកគេបានរកមើលនៅក្នុងប្រអប់ដាក់ឥវ៉ាន់រើសបាន នៅក្នុងសាលាជំនុំ នៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យរបស់ប្រាដ នៅក្នុងថ្នាក់អង្គការបឋមសិក្សា និងរកនៅលើស្នាព្យួរអាវនីមួយៗ ។ ពួកគេថែមទាំងរកមើលវានៅក្នុងបន្ទប់ទឹកទៀតផង ប៉ុន្តែពួកគេរកវាពុំឃើញឡើយ ។

ប៉ាបាននិយាយថា « ប្រហែលជានរណាម្នាក់បានយកវាច្រឡំហើយ ។ ប៉ាប្រាកដក្នុងចិត្តថា ពួកគេនឹងយកវាត្រឡប់មកវិញនៅសប្ដាហ៍ក្រោយ ពេលគេដឹងថា វាមិនមែនជារបស់ពួកគេ » ។

ម៉ាក់បាននិយាយថា « អំឡុងពេលនេះ កូនអាចពាក់អាវធំចាស់របស់កូនបាន » ។

ប្រាដបានធ្វើមុខក្រញ៉ូវ ។ គាត់មិនចូលចិត្តអាវធំចាស់របស់គាត់ទេ ។ វាស្ដើង ហើរពណ៌ ហើយតូចពេកសម្រាប់គាត់ ។ គាត់ស្រឡាញ់អាវធំ

រចនារូបភាពដោយ ហ្ដាយ ហ្វ្រានស៊ីស



ពណ៌ក្រហម និងខៀវថ្មីរបស់គាត់ ដែលធ្វើឲ្យគាត់មើលទៅដូចជាវីរៈបុរសម្នាក់ ។

ប្រាដបានគិតថា « ប្រហែលជាគេបានឃើញថា អាវធំរបស់ខ្ញុំស្អាត ហើយគេបានលួចវា » ។ តើរឿងនោះអាចកើតឡើងនៅព្រះវិហារយ៉ាងដូចម្ដេច ? គេស្មានថា មនុស្សគ្រប់រូបនៅទីនោះមានភាពទៀងត្រង់ ។ ប្រាដពុំអនុញ្ញាតឲ្យចោរម្នាក់នោះអាចយកអាវធំនោះឡើយ ។ គាត់មានផែនការមួយ ។ នៅសប្ដាហ៍បន្ទាប់ គាត់ពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ថា តើនរណាពាក់អាវធំរបស់គាត់ ។ ពេលនោះគាត់នឹងយកវាត្រឡប់មកវិញ ហើយស្រែកថា « ឈប់ភ្លាមទៅអាចោរ ! » ពួកគេនឹងសោកស្ដាយដែលពួកគេបានលួចវាទៅ ។

ប្រាដមិនអាចរង់ចាំដល់ថ្ងៃអាទិត្យដើម្បីអនុវត្តតាមផែនការគាត់ឡើយ ។ ប៉ុន្តែនៅសប្ដាហ៍បន្ទាប់ អាកាសធាតុក្ដៅដែលមិនគួរពាក់អាវធំឡើយ ហើយនៅសប្ដាហ៍បន្ទាប់អាកាសធាតុក៏ក្ដៅផងដែរ ។

នៅថ្ងៃអាទិត្យបន្ទាប់មកទៀត ប្រាដបានមើលក្មេងប្រុសទាំងអស់ក្នុងថ្នាក់អង្គការបឋមសិក្សាដោយការសង្ស័យ ។ តើក្មេងប្រុសខ្ពស់ម្នាក់នោះឬគឺជាចោរ ? ឬប្រហែលជាក្មេងស្រីនោះទេដឹង ? គាត់មានអារម្មណ៍ថា គាត់មិនអាចទុកចិត្តនរណាឡើយ ។ ប្រាដអត់ចូលចិត្តអារម្មណ៍បែបនោះទេ ។

បន្ទាប់ពីចប់ម៉ោងនៅព្រះវិហារ ប្រាដបានប្រញាប់ទៅជុំវិញអគារ ដោយមើលក្រុមគ្រួសារផ្សេងៗពាក់អាវធំរបស់ពួកគេ ។ ប៉ុន្តែគាត់ពុំឃើញអាវធំរបស់គាត់នៅកន្លែងណាទេ ។ គាត់ថែមទាំងបានពិនិត្យមើលប្រអប់ដាក់ឥវ៉ាន់រើសបានទៀត . . . ប៉ុន្តែអត់ឃើញអាវធំគាត់ទេ ។ តើវានៅឯណាទៅ ?

នៅតាមផ្លូវទៅផ្ទះវិញ ប្រាដបានគិតឃើញផែនការថ្មីមួយទៀត ។ គាត់បានអធិស្ឋាន ។ គាត់បានដឹងថា ព្រះវរបិតាសួគ៌រកឃើញវត្ថុដែលបាត់ ។ នៅយប់នោះ ប្រាដបានអធិស្ឋាន ហើយនិយាយថា « ឱព្រះវរបិតាសួគ៌អើយ សូមប្រាប់ទូលបង្គំថា តើនរណាបានយកអាវធំរបស់ទូលបង្គំ ។ ទូលបង្គំចង់បានវាត្រឡប់មកវិញ » ។

ប្រាដបានរង់ចាំមើលក្រែងមានឈ្មោះ ឬមុខរបស់ចោរផុសឡើងក្នុងចិត្តគាត់ ។ ប៉ុន្តែផ្ទុយទៅវិញ គាត់បានចាប់ផ្ដើមគិតអំពីមិត្តគាត់ម្នាក់ឈ្មោះខាល ។ ប្រាដតែងតែអង្គុយនៅក្បែរខាលនៅក្នុងថ្នាក់អង្គការបឋមសិក្សា ។ ពួកគេនិយាយរឿងកំប្លែង និងសើចច្រើនជាមួយគ្នា ។ ប៉ុន្តែខាលពុំបានមកព្រះវិហារពីរបីសប្ដាហ៍ហើយ ។ ប្រាដបាននឹកគាត់ ។

តើមានអ្វីកើតឡើងទៅ បើ *ខាល* បានយកអាវធំរបស់គាត់នោះ ? ប្រហែលជាខាលខ្លាចអត់ហ៊ានមកព្រះវិហារឥឡូវនេះ ដោយសារគាត់បានគិតថា ប្រាដពុំធ្វើមិត្តនឹងគាត់ទៀតទេ ។ ប្រាដចង់ឲ្យខាលមកព្រះវិហារវិញម្ដងទៀត ។ ប្រសិនបើខាលបានយកអាវធំគាត់មែន នោះប្រាដបានសម្រេចចិត្តថា គាត់នឹងពុំស្រែកដាក់ខាលទេ ។ គាត់នឹងអភ័យទោសឲ្យខាល ។

ប្រាដបានឡើងលើគ្រែ ដោយមានអារម្មណ៍ល្អជាងមុន ។

នៅថ្ងៃអាទិត្យបន្ទាប់ក្នុងថ្នាក់អង្គការបឋមសិក្សា ខាលពុំបាននៅក្នុងថ្នាក់ទេ ប៉ុន្តែមានក្មេងប្រុសថ្មី ម្នាក់នៅក្នុងថ្នាក់បឋមសិក្សា ។ គាត់ពាក់ក្រវ៉ាត់កក្រហមឆ្នូតខៀវ ។

ដោយអង្គុយនៅក្បែរក្មេងប្រុសថ្មីនោះ ប្រាដបាននិយាយថា « ក្រវ៉ាត់កស្អាតណាស់ ។ វាធ្វើឲ្យអ្នកមើលទៅដូចជាវីរៈបុរសអញ្ចឹង ។

ក្មេងប្រុសនោះបានញញឹម ។

ប្រាដបានញញឹមផងដែរ ។ គាត់ឈប់រកមើលចោរទៀតហើយ ។ គាត់រកមើលមិត្តភក្ដិវិញម្ដង ។●

*អ្នកនិពន្ធរស់នៅរដ្ឋ អ៊ែរអ៊្ហូវ៉ា ស.រ.អា. ។*

# សួស្ដីមកពី ប្រទេសអេស្តូនី !





ពួកយើងឈ្មោះ
ម៉ាហ្គោ និង ប៉ោឡូ ។ ឆ្នាំនេះយើង
ធ្វើដំណើរជុំវិញពិភពលោកដើម្បីរៀន
អំពីបុត្រាបុត្រីរបស់ព្រះ ។ សូមចូលរួម
ជាមួយពួកយើង ពេលយើងទៅលេង
ប្រទេសអេស្តូនី !





នេះជាទីក្រុងថាលីន រដ្ឋធានីប្រទេសអេស្តូនី ។ វាមានអាយុកាលប្រហែលជា ៨០០ ឆ្នាំហើយ ។ ប្រទេសអេស្តូនីមានកន្លែងធម្មជាតិជាច្រើន ដូចជាព្រៃឈើ និងវាលល្បាប់ ។ តាមពិតទៅ ជាងពាក់កណ្ដាលនៃប្រទេសអេស្តូនីគឺគ្របដណ្ដប់ដោយព្រៃឈើ ។ ប្រជាជនជាច្រើននាក់នៅក្នុងប្រទេសអេស្តូនី ចូលចិត្តចំណាយពេលវេលានៅក្នុងធម្មជាតិ ។

នេះគឺជារបៀបនិយាយថា « សួស្ដី » ជាភាសាអេស្តូនី

Tere!

ហើយនេះជារបៀបដែលអ្នកហៅឈ្មោះសាសនាចក្រ ៖

Viimse Aja Pühade Jeesuse Kristuse Kirik



ប្រទេសអេស្តូនីស្ថិតនៅក្នុងទ្វីបអឺរ៉ុបភាគខាងជើង ។ ប្រទេសនេះមានកោះជាង ២០០០ កោះ ។ ប្រជាជនចំនួនប្រមាណជា ១.៣ លាននាក់រស់នៅក្នុងប្រទេសអេស្តូនី ។



តើនៅប្រទេសអេស្តូនីគេបរិភោគអ្វីសម្រាប់អាហារពេលល្ងាច ? ប្រហែលជាសាច់ជ្រូក ឬផ្អកត្រីជាមួយដំឡូងបារាំង ស្ពៃក្ដោប ត្រឹមដូរ និងនំប៉័ងខ្មៅ ។ នោះគេហៅថា នំសាំងវិចស្ព្រាត ។

សាសនាចក្រនៅក្នុងប្រទេសអេស្តូនីតូច ប៉ុន្តែមានភាពរឹងមាំ ។ មានសមាជិកសាសនាចក្រប្រមាណជាមួយពាន់នាក់ ។ ព្រះវិហារបរិសុទ្ធដែលនៅជិតពួកគេបំផុតនោះគឺនៅ ហែលស៊ីនគី ហ្វាំងឡង់ ។





តើអ្នកចូលចិត្តច្រៀងនៅក្នុងថ្នាក់អង្គការបឋមសិក្សាទេ ?
រៀងរាល់ប្រាំឆ្នាំម្ដង ប្រជាជនអេស្តូនីជួបជុំគ្នានៅក្នុងពិធីបុណ្យដ៏ធំមួយ ដើម្បីសាទរដល់ប្រទេសរបស់គេជាមួយនឹងការច្រៀង និងការរាំ ។

## សូមជួបជាមួយបងប្អូនស្រីពីរនាក់មកពីប្រទេសអេស្តូនី !



នាយប់មួយ ពេលខ្ញុំចង់ចូលដេក ខ្ញុំបានបាត់តុកតាខ្លាឃ្មុំរបស់ខ្ញុំ ។ ខ្ញុំបានរកមើលវា ប៉ុន្តែខ្ញុំរកមិនឃើញទេ ។ ខ្ញុំបានអធិស្ឋាន ។ បន្ទាប់មក ខ្ញុំបានរកឃើញតុកតាខ្លាឃ្មុំរបស់ខ្ញុំវិញ ហើយខ្ញុំមានសុបិនល្អ ។

**បាយអែនកា ជេ អាយុ ៧ ឆ្នាំ**



គ្រួសារយើងចូលចិត្តបម្រើមនុស្សដទៃ ។ ការបម្រើជួយយើងឲ្យទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធដែលបានប្រទានអារម្មណ៍ដ៏កក់ក្ដៅនៃភាពសុខសាន្តដល់យើង ។ ប្អូនស្រីរបស់ខ្ញុំ និងខ្ញុំបានធ្វើអំណោយឲ្យមនុស្សដទៃ ដោយសារយើងចង់ឲ្យពួកគេទទួលអារម្មណ៍នៃក្ដីស្រឡាញ់ ។

**ភីបឺ ជេ អាយុ ១០ ឆ្នាំ**

តើប្អូនមកពីប្រទេសអេស្តូនីឬ ?
សូមសរសេរមកកាន់ពួកយើង ! ពួកយើងចង់ឮពីប្អូន។ ។





# អារម្មណ៍ថ្មីស្រឡាង

ដោយ ជេសីកា ឡាសិន
ផ្អែកទៅលើដំណើររឿងពិត

*ប្រទេសអេស្តូនី*

« ម៉ាក់មានរឿងភ្ញាក់ផ្អើលមួយ ! » *Ema* ( ម៉ាក់ ) បាននិយាយពេលគាត់បានទៅយកវ៉ាស្មុសពីសាលារៀន ។ ពួកគេបានដើរតាមបន្ទាត់ផ្លូវចង្អៀតដែលមានអគារចម្រុះពណ៌ជុំវិញ ។

តើយើងញ៉ាំ « *Rosolje* សម្រាប់អាហារពេលល្ងាចឬ ? » វ៉ាស្មុសបានទាយទាំងសង្ឃឹម ។ ពួកគេទើបតែបានបរិភោគវាកាលពីសប្តាហ៍មុនសម្រាប់ថ្ងៃខួបកំណើតគម្រប់ប្រាំពីរឆ្នាំរបស់គាត់ ។ ប៉ុន្តែគាត់អាចញ៉ាំសាឡាត់ដែលមានឆៃថាវ និងដំឡូងជាមួយម៉ាំត្រីហារ៉ុង ។

*Ema* បានងក់ក្បាលរបស់គាត់ទាំងញញឹម ។ « ម៉ាក់បានជួបយុវនារីពីរនាក់នៅលើឡានក្រុងកាលពីព្រឹកមិញ ។ ពួកគេជាអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេនឹងមកលេងយើងយប់នេះ ដើម្បីនិយាយអំពីព្រះវិហាររបស់ពួកគេ » ។

វ៉ាស្មុសបានមើលទៅលើដោយចិត្តចង់ដឹង ។ គាត់មិនធ្លាប់ជួបពួកអ្នកផ្សព្វផ្សាយសាសនាពីមុនទេ ។

គាត់បាននៅក្នុងបន្ទប់គេងរបស់គាត់ លេងឡានជ័ររបស់គាត់ ពេលពួកអ្នកផ្សព្វផ្សាយសាសនាបានមក ។ « *Tere*! *Tere*! សួស្តី » ពួកគេបានស្វាគមន៍ *Ema* ពេលពួកគេបានដើរចូលមកក្នុងផ្ទះ ។ ពួកគេបានដោះស្បែកជើងកវែងដ៏ធ្ងន់របស់ពួកគេ ហើយពាក់ស្បែកជើងផ្ទាត់ដែល *Ema* បានទុកសម្រាប់ភ្ញៀវ ។ *Ema* ឲ្យពួកគាត់អង្គុយលើសាឡុងពណ៌ទឹកក្រូច ។ ប៉ុន្តែវ៉ាស្មុសបានផ្អែកខ្នងនឹងទ្វារ ។

ស្ត្រីខ្ពស់ជាងគេម្នាក់បានឃើញគាត់ ហើយបានញញឹមដាក់គាត់ ។ ស្លាកឈ្មោះខ្មៅរបស់គាត់សរសេរថា Õde Craig ( ស៊ីស្ទើរ ក្រេក ) ។ គាត់បាននិយាយថា « ម៉ាក់របស់ក្មួយបានប្រាប់ពួកខ្ញុំថា ក្មួយទើបធ្វើខួបកំណើតរួច ។ ពួកខ្ញុំបានយកអ្វីមួយមកឲ្យក្មួយ ។ គាត់បានកាន់ប័ណ្ណតូចមកចេញមក ។ វ៉ាស្មុសបានមើលវាយ៉ាងជិត ។

វាជារូបភាពរបស់បុរសម្នាក់ ។ គាត់ពាក់រ៉ូបពណ៌ស ហើយដៃរបស់គាត់លាចេញក្រៅ ។

ស៊ីស្ទើរក្រេកបានសួរ « តើក្មួយដឹងថា រូបនេះជារូបនរណាទេ ? »

វ៉ាស្មុសពុំស្គាល់ឈ្មោះបុរសនោះទេ ។ គាត់មិនធ្លាប់ឃើញរូបនេះពីមុនទេ ។ ប៉ុន្តែបុរសនោះមើលទៅដូចជាមានចិត្តល្អ ហើយមានអំណាច ។ វ៉ាស្មុសបាននិយាយថា « ខ្ញុំគិតថា គាត់គឺជាស្តេច ! »

អ្នកផ្សព្វផ្សាយសាសនាទាំងពីរនាក់បានញញឹម ។ « ចាស៎ ទ្រង់ពិតជាស្តេចមែន ! ទ្រង់គឺជាស្តេចអស់ទាំងស្តេច ។ ព្រះនាមរបស់ទ្រង់គឺ

ព្រះយេស៊ូវគ្រីស្ទ » ។ ស៊ីស្ទើរក្រេកបានទាញយកសៀវភៅមួយក្បាលដែលមានគម្របពណ៌ខៀវ ។ « ហើយនេះគឺជាសៀវភៅមួយក្បាលដែលបង្រៀនអំពីទ្រង់ គឺព្រះគម្ពីរ *Mormoni Raamat* ។ ព្រះគម្ពីរមរមន » ។

គាត់ និង *Ema* បានចាប់ផ្ដើមបានអានព្រះគម្ពីរមរមនរៀងរាល់ថ្ងៃ ពីមុនគាត់ទៅសាលារៀន ។ អំឡុងពេលនៅសាលារៀន រ៉ាស្មុស និងសិស្សក្នុងថ្នាក់របស់គាត់បានដើរកម្សាន្ត នឹងគេងពេលថ្ងៃ ។ បន្ទាប់ពីចប់ពីសាលារៀន គាត់ និង *Ema* ជួបអ្នកផ្សព្វផ្សាយសាសនាជារឿយៗ ។ ពួកគេបាននិយាយជាមួយពួកអ្នកផ្សព្វផ្សាយសាសនាអំពីអ្វីដែលពួកគេបានអានពីព្រះគម្ពីរមរមន ។ ជួនកាល *Ema* ផ្ដល់អាហារ *kringel* ជានំប៉័ងលឿងក្រម៉ៅដល់ពួកគេទាំងអស់គ្នា ។ នៅថ្ងៃចុងសប្ដាហ៍ គាត់ និង *Ema* ជិះកង់ ឬដើរលំហែនៅលើឆ្នេរសមុទ្រ ។ ជួនកាលពួកគេដើរចូលទៅក្នុងព្រៃជ្រៅ ឬដើរតាមដងទន្លេដែលពួកគេចូលចិត្ត ។

មានគ្រាមួយ ពេលដើរទៅក្នុងព្រៃនោះ *Ema* បានប្រាប់រ៉ាស្មុសថា គាត់ចង់ទទួលបុណ្យជ្រមុជទឹក ។ រ៉ាស្មុសបានញញឹម ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានសូមឲ្យ *Ema* អធិស្ឋានថា តើគួរទទួលបុណ្យជ្រមុជទឹកឬមិនទទួល ។ វាទំនងថា គាត់បានទទួលចម្លើយរបស់គាត់ហើយ !

គាត់បានប្រាប់រ៉ាស្មុសទាំងញញឹមថា « ហើយម៉ាក់ដឹងពីកន្លែងដែលម៉ាក់នឹងទទួលបុណ្យជ្រមុជទឹកហើយ ។ តើកូនអាចទាយដឹងទេ ? »

រ៉ាស្មុសបានគិតពីមេរៀនរបស់ពួកអ្នកផ្សព្វផ្សាយសាសនាស្ដីពីពិធីបុណ្យជ្រមុជទឹក ។ ពួកគេបានលើករូបភាពមួយដែលបង្ហាញពីពេលដែល ព្រះយេស៊ូវគង់នៅជាមួយយ៉ូហាន បាទីស្ទ នៅក្នុងទឹកទន្លេមួយ ។. . .

គាត់បានស្រែកឡើងថា « ជ្រមុជទឹកក្នុងទន្លេ ! គឺទន្លេដែលយើងស្រឡាញ់ » ។

មួយសប្ដាហ៍ក្រោយមក រ៉ាស្មុសបានឈរនៅលើច្រាំងទន្លេជាមួយពួកអ្នកផ្សព្វផ្សាយសាសនា និងមនុស្សមួយចំនួនផ្សេងទៀតមកពីព្រះវិហារ ។ *Ema*





បានទទួលបុណ្យជ្រមុជទឹក ។ គាត់បានលេចកប់ចុះទាំងស្រុងទៅក្នុងទឹក គឺដូចព្រះយេស៊ូវបានធ្វើ ។ ពេលគាត់ក្រោកចេញពីទឹកមកវិញ គាត់បានញញឹម ។ រ៉ាស្មុសចង់ចងចាំពីគ្រានោះរៀងរហូត—ទឹកពណ៌ខៀវ ផ្កាព្រៃពណ៌សនៅក្នុងស្មៅពណ៌បៃតង និងស្នាមញញឹមរបស់ម្ដាយគាត់ ។

ក្រោយមក ពេលមនុស្សគ្រប់គ្នាកំពុងបរិភោគនំឃុកឃីដែលពួកអ្នកផ្សព្វផ្សាយសាសនាបានយកមក រ៉ាស្មុសបានសួរថា « តើការទទួលបុណ្យជ្រមុជទឹករួចហើយមានអារម្មណ៍បែបណា ? »

ម្ដាយគាត់បានប្រាប់គាត់ថា « អារម្មណ៍អស្ចារ្យណាស់ ។ ម៉ាក់ចង់នៅក្នុងទឹកទន្លេនោះរៀងរហូត ។ ម៉ាក់មានអារម្មណ៍ថ្មីស្រឡាង ! » គាត់បានឱបរ៉ាស្មុសយ៉ាងណែន ។

រ៉ាស្មុសបានប្រាប់គាត់ថា « សម្រាប់ថ្ងៃកំណើតកូនលើកក្រោយ កូនចង់ទទួលបុណ្យជ្រមុជទឹក ដូចម៉ាក់ និងព្រះយេស៊ូវដែរ ។ កូនចង់មានអារម្មណ៍ថ្មីស្រឡាងផងដែរ ! » ●

*អ្នកនិពន្ធរស់នៅរដ្ឋតិចសាស ស.រ.អា ។*



ដោយ ប៉ែណា អ៊ី អាបើតូ
ទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធាន
សមាគមសង្គ្រោះទូទៅ

# ខ្ញុំនឹងឃើញគាត់ម្ដងទៀត





ខ្ញុំបានធំឡើងនៅប្រទេសនីខារ៉ាហ្គារ ។ កាលខ្ញុំនៅតូច ខ្ញុំបានធ្វើកិច្ចការនានាជាមួយបងប្រុសរបស់ខ្ញុំ ។ យើងបានដើរទៅសាលារៀនជាមួយគ្នា ។ យើងបានទៅហាងលក់ទំនិញជាមួយគ្នា ។ ពួកយើងទាំងអស់គ្នាមានការផ្សងព្រេងផ្សេងៗនៅក្នុងរានហាលក្រោយផ្ទះរបស់យើង ។ ពួកយើងសប្បាយរីករាយ ។

ក្រោយមក ពេលខ្ញុំអាយុប្រាំបួនឆ្នាំ មានរឿងមួយដ៏ក្រៀមក្រំបានកើតឡើង ។ បងប្រុសរបស់ខ្ញុំបានស្លាប់ដោយសារគ្រោះរញ្ជួយដី ។ នៅគ្រាដំបូង វាពុំមែនជាអារម្មណ៍ពិតទេដែលថា គាត់បានស្លាប់ហើយ ។ ខ្ញុំធ្លាប់ស្រមៃឃើញថា គាត់នឹងមកគោះទ្វារផ្ទះរបស់យើង ។ គាត់នឹងប្រាប់យើងថា គាត់បានទៅទីណាមួយរយៈ ។ ខ្ញុំធ្លាប់សម្លឹងមើលទ្វារផ្ទះយើងដោយបួងសួងឲ្យគាត់មកវិញ ។ ខ្ញុំចង់ឃើញគាត់ម្ដងទៀតខ្លាំងណាស់ ។

យូរៗទៅ ខ្ញុំមានអារម្មណ៍ធូរស្បើយ ។ ខ្ញុំនៅតែនឹកបងប្រុសខ្ញុំ ប៉ុន្តែខ្ញុំអាចមានអារម្មណ៍រីករាយម្ដងទៀត ។

កាលនោះ ខ្ញុំពុំមែនជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវនៃពួកបរិសុទ្ធថ្ងៃចុងក្រោយទេ ។ ប៉ុន្តែខ្ញុំបានធំឡើង ហើយខ្ញុំបានរៀនអំពីសាសនាចក្រ ហើយបានទទួលបុណ្យជ្រមុជទឹក ។ ថ្ងៃមួយ ពេលខ្ញុំកំពុងលាងចាន ។ វាជារដូវកាលបុណ្យអ៊ីស្ទើរ ។ ខ្ញុំបានគិតអំពីការរស់ឡើងវិញ ហើយបានគិតអំពីបងប្រុសរបស់ខ្ញុំ ។

រំពេចនោះ អារម្មណ៍មួយបានផុសឡើងក្នុងចិត្តខ្ញុំ ។ ខ្ញុំបានចាំពីថ្ងៃដែលខ្ញុំសុបិនឃើញបងប្រុសរបស់ខ្ញុំ ។ ខ្ញុំបានដឹងថា វាពុំមែនជារឿងលេងសើចឡើយ ! អារម្មណ៍នោះកើតមកពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីលួងលោមខ្ញុំ និងដឹកនាំខ្ញុំ ។ នៅថ្ងៃណាមួយ បងប្រុសរបស់ខ្ញុំនឹងរស់ឡើងវិញយ៉ាងពិតប្រាកដ ។ ហើយខ្ញុំពិតជាឃើញគាត់ម្ដងទៀត ។

ប្រសិនបើ មនុស្សណាម្នាក់ដែលអ្នកស្រឡាញ់បានស្លាប់ វាមិនអីទេដើម្បីនឹកពួកគេ និងមានអារម្មណ៍កើតទុក្ខ ។ សូមនិយាយជាមួយគ្រួសាររបស់អ្នក និងមនុស្សពេញវ័យ ពេលអ្នកមានអារម្មណ៍ថា ត្រៀមខ្លួនរួចរាល់ ។ សូមអធិស្ឋានទៅកាន់ព្រះវរបិតាសួគ៌អំពីអារម្មណ៍ដែលអ្នកមាន ។ ទ្រង់អាចជួយអ្នកឲ្យទទួលអារម្មណ៍នៃភាពសុខសាន្តម្ដងទៀត ។

មិនថាមានអ្វីកើតឡើងទេ សូមចាំថា ព្រះយេស៊ូវគ្រីស្ទស្រឡាញ់អ្នក ។ នៅបុណ្យអ៊ីស្ទើរ យើងចងចាំពីការពលិកម្មរបស់ទ្រង់សម្រាប់យើង ។ ដោយសារទ្រង់ នោះយើងទាំងអស់គ្នានឹងរស់ឡើងវិញ ហើយយើងអាចរស់នៅជាមួយគ្រួសារយើងជារៀងរហូត ។ ●

## បណ្ណល្បងលោម

សូមកាត់បណ្ណទាំងនេះ ។ អ្នកអាចបត់វាពាក់កណ្ដាល ឬប្រើវាជាវត្ថុសិកចំណាំ ។
ទុកវាក្នុងព្រះគម្ពីររបស់អ្នក ឬកន្លែងផ្សេងទៀត ដើម្បីមើលវា ពេលអ្នកមានអារម្មណ៍កើតទុក្ខ ឯកោ ឬភ័យខ្លាច ។



« ខ្ញុំមិនចោលអ្នករាល់គ្នា
ឲ្យនៅកំព្រាទេ ៖ ខ្ញុំនឹងមក
ឯអ្នករាល់គ្នាវិញ » ។
យ៉ូហាន ១៤:១៨

« ព្រះទ្រង់នឹងជូតអស់ទាំងទឹក
ភ្នែកពីភ្នែកគេចេញ » ។
វិវរណៈ ២១:៤





« ចូរសង្ឃឹមឡើង ហើយចូរកុំខ្លាច
ឡើយ ដ្បិតយើងជាព្រះអម្ចាស់
គង់នៅជាមួយនឹងអ្នក » ។
គោលលទ្ធិ និងសេចក្ដីសញ្ញា ៦៨:៦

# កម្មវិធីបង្ហាញ ហើយនិទានប្រាប់

ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ ។

**រ៉េបេកា ស៊ី អាយុ ៩ ឆ្នាំ ទីក្រុងអារ៉ាហ្គោ ប្រទេសវេណេហ្ស៊ុយអេឡា**






ថ្ងៃមួយពេលយើងចូលជិះឡាន ឡានយើងអត់ដំណើរការទេ ។ យើងបានពិនិត្យមើលម៉ាស៊ីនឡាន ប៉ុន្តែគ្មានប្រយោជន៍អ្វីឡើយ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគួរតែអធិស្ឋាន ដូច្នេះខ្ញុំបានអធិស្ឋាន ។ ពីរបីនាទីក្រោយមក ឡានបានដំណើរការឡើងវិញ ។ ខ្ញុំមានចិត្តរីករាយណាស់ ដែលព្រះវរបិតាសួគ៌អាចជួយខ្ញុំជានិច្ច ។

**ប្រ៊ូកឃ្លីន បី អាយុ ៩ ឆ្នាំ ទីក្រុងឃ្វេស្សាតេណាន់ហ្គោ ប្រទេស ហ្គូតេម៉ាឡា**



ពីរឆ្នាំមុន ក្មេងប្រុសថ្មីម្នាក់បានចូលរួមថ្នាក់រៀនយើងនៅសាលារៀន ។ គាត់មានចិត្តកំណាញ់ចំពោះមនុស្សដទៃ ។ សិស្សក្នុងថ្នាក់ចាប់ផ្តើមមិនចូលចិត្តគាត់ ហើយមានចិត្តកំណាញ់ចំពោះគាត់ ។ វាហាក់ដូចជាធ្វើឲ្យគាត់កើតទុក្ខ ដូច្នេះខ្ញុំពុំបានធ្វើដូចសិស្សដទៃទៀតធ្វើឡើយ ។ មិត្តភក្តិមួយចំនួនរបស់ខ្ញុំបានកត់សម្គាល់ពីរឿងនោះ ហើយបានធ្វើតាមគំរូខ្ញុំ ។ ខ្ញុំជឿថា ប្រសិនបើខ្ញុំធ្វើអ្វីដែលព្រះសព្វព្រះទ័យឲ្យខ្ញុំធ្វើ នោះខ្ញុំនឹងសប្បាយជាង ហើយសុវត្ថិភាពជាង ។ ខ្ញុំជឿថា ប្រសិនបើខ្ញុំមានចិត្តក្លាហាន ហើយនិយាយចេញពីចិត្តខ្ញុំ នោះខ្ញុំនឹងរកឃើញមិត្តភក្តិដែលនឹងចូលចិត្តខ្ញុំ ។

**វ៉ស្តីណា ខេ អាយុ ១១ ឆ្នាំ ទីក្រុងវីលនៀស ប្រទេសលីទុយអានី**



ខ្ញុំចូលចិត្តលេងបាល់ឱបជាមួយក្មេងៗ ហើយបង្រៀនពួកគេនូវជំនាញថ្មីៗ ។ វាគឺជារបៀបមួយដែលខ្ញុំចូលចិត្តដើម្បីបម្រើ ។

**សាខា ខេ អាយុ ១១ ឆ្នាំ ទីក្រុងម៉ូស្គូ ប្រទេសរុស្ស៊ី**

សូមប្រើរូបថតទាំងនេះ
ដើម្បីបំពេញក្នុងតារាងនៅ
ទំព័រ ខ១២–ខ១៣ ។

















សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

# ជូនចំពោះមាតាបិតា

**ក្នុងខែនេះ** ទស្សនាវដ្ដី *ប្រិយមិត្ត* មានរឿង និងសកម្មភាពនានាដើម្បីជួយគ្រួសាររបស់អ្នកសាទរដល់បុណ្យអ៊ីស្ទើរ ។ យើងសង្ឃឹមថា គ្រួសាររបស់អ្នកនឹងគិតដោយរីករាយអំពីបុណ្យអ៊ីស្ទើរពេញមួយខែនេះ !

- « អំណោយដ៏មហិមារបស់ព្រះ » ទំព័រ (ខ២)—សារលិខិតបុណ្យអ៊ីស្ទើរមកពីប្រធាន រ័សុល អិម ណិលសុន
- « ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះរបស់ខ្ញុំ » (ខ៣)—សកម្មភាពផាត់ពណ៌អំពីដង្វាយធួន និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវ
- « ដំណើររឿងនៃបុណ្យអ៊ីស្ទើរ » ទំព័រ (ខ៤–ខ៦)—រចនារូបភាពនៃដំណើររឿងក្នុងព្រះគម្ពីរ
- « ពេលខ្ញុំមករកទ្រង់វិញ » ទំព័រ (ខ៧)—ចម្រៀងដ៏ពិរោះថ្មីមួយអំពីការប្រែចិត្ត
- « អារម្មណ៍ថ្មីស្រឡាង » ទំព័រ (ខ១៨)—ដំណើររឿងមួយស្ដីពីក្មេងប្រុសម្នាក់មកពីប្រទេសអេស្តូនីដែលរៀនពីព្រះយេស៊ូវ
- « ខ្ញុំនឹងឃើញគាត់ម្ដងទៀត » ទំព័រ (ខ២០)—ទីបន្ទាល់របស់ស៊ីស្ទើ រ៉េណា អ៊ី អាបឺតូ ស្ដីពីការរស់ឡើងវិញ

សូមសរសេរសំបុត្រមកពួកយើង ដើម្បីឲ្យយើងដឹងពីរបៀបដែលក្រុមគ្រួសាររបស់អ្នកបានប្រើប្រាស់រឿង និងសកម្មភាពទាំងនេះ ។

សូមឲ្យមានថ្ងៃបុណ្យអ៊ីស្ទើរដ៏មានពរ !

*ប្រិយមិត្ត*

New *Friend*
50 E. North Temple Street,
Room 2393
Salt Lake City, UT 84105 USA
liahona@ldschurch.org



សូមស្វែងរកបាលីអាហូណាដែលលាក់នៅខាងក្នុង !

## មាតិកា

ខ២ សារលិខិតគណៈប្រធានទីមួយ: អំណោយដ៏មហិមារបស់ព្រះ
ខ៤ រឿងក្នុងព្រះគម្ពីរ: ដំណើររឿងនៃបុណ្យអ៊ីស្ទើរ
ខ៧ តន្ត្រី: ពេលខ្ញុំមករកទ្រង់វិញ
ខ៨ ភាពទៀងត្រង់ដ៏ផ្អែមល្ហែម
ខ១០ ពួកសារកនៅជុំវិញពិភពលោក: អែលឌើរបែដណាទៅទស្សនាប្រទេសឥណ្ឌា
ខ១២ ពួកព្យាការី និងពួកសាវករបស់យើង
ខ១៤ អាវធំដែលបាត់
ខ១៦ សួស្ដីមកពីប្រទេសអេស្តូនី !
ខ១៨ អារម្មណ៍ថ្មីស្រឡាង
ខ២០ ខ្ញុំនឹងឃើញគាត់ម្ដងទៀត
ខ២២ កម្មវិធីបង្ហាញ ហើយនិទានប្រាប់
ខ២៣ រូបថតរបស់ពួកព្យាការី និងពួកសាវក

នៅលើក្របទស្សនាវដ្ដី *ប្រិយមិត្ត*
រចនារូបភាពដោយ ប៉ាទ្រីកសៀ ខាស្ដាលេអូ

© 2019 BY INTELLECTUAL RESERVE, INC. ALL RIGHTS RESERVED.

CAMBODIAN
4 02186 04258 2